# ការនិរទេសខ្លួនរបស់ប្រធានាធិបតី

# Aristide

# ការនិរទេសខ្លួនរបស់ប្រធានាធិបតី Aristide

នៅពេលដែលកងកម្លាំងអង្គការសហប្រជាជាតិ សម្លាប់ប្រជាជនហៃទីនៅសំណង់អាណាធិបតេយ្យ Cite Soleil មិត្តភ័ក្រនិងគ្រួសារជាច្រើនបានបិទរូបថតលោកប្រធានាធិបតី Jean Bertand Aristide ដែលបាននិរទេសខ្លួននៅលើរាងកាយរបស់ពួកគេ ។ រូបភាពនោះទទួចយ៉ាងស្ងៀមស្ងាត់ ដែលថាមានវិធីសាស្ត្រផ្សេងទៀតដើម្បីជៀសវាងការកំទេចដោយភាពគ្រោចខឹងខ្លាំងនៅ Port-au-Prince ។ ប្រជាជនក្រីក្រនៃប្រទេសហៃទីកំពុងតែត្រូវបានគេកាប់សម្លាប់ មិនស្ថិតនៅក្រោមអំពើហិង្សានោះដូចដែលយើងព្វទេ ប៉ុន្តែសម្រាប់ជនសកម្មប្រយុទ្ធ ចំពោះការហ៊ានទាមទារឱ្យលោកប្រធានាធិបតីរបស់ពួកគេដែលបានជ្រើសតាំងឱ្យត្រឡប់មកវិញ ។

វាទើបតែកើតឡើងកាលពី១០ឆ្នាំ កន្លងទៅដែលលោកប្រធានាធិបតីគ្លីនតុន បានប្រារព្ធពិធីប្រគល់អំណាចរបស់លោក Aristide "សេរីភាពនៃជ័យជំនះលើការភ័យខ្លាច " ។ ដូច្នេះ តើមានអ្វីបាន ផ្លាស់ប្តូរ? អំពើពុករលួយ? អំពើហិង្សា? អំពើលួចបន្លំ? លោក Aristide មិនមែនជាអ្នកឥតខ្ចោះ នោះទេ ប៉ុន្តែបើទោះណាជាការចោទប្រកាន់ដ៏អាក្រក់បំផុតនេះជាការពិតក៏ដោយ ក៏វាមិនអាក្រក់ស្មើនឹងឃាតករជាអ្នករត់ពន្ធគ្រឿងញៀននិងជាឈ្មួញជួញដូរអាវុធ ដែលបានបណ្តេញលោកAristide ចេញពីតំណែង ហើយរីករាយនិងការកាន់កាប់បន្តដោយមានការជួយជ្រុមជ្រែងយ៉ាងពេញទំហឹងពីរដ្ឋបាលលោកប៊ូស និងអង្គការសហប្រជាជាតិ ។ ការផ្លាស់ប្តូរប្រទេសហៃទីឱ្យធ្លាក់ចូលទៅក្នុងបាតដាល ពីក្រុមអ្នកលេងនិងបានបណ្តេញលោក Aritide ចេញពីតំណែងដោយលេសថា កង្វះខាតនូវ "អភិបាលកិច្ចល្អ" នោះគឺជាលេសមួយដែលអាមេរិក និងអង្គការសហប្រជាជាតិប្រឌិតឡើងតែប៉ុណ្ណោះ ។

កាលពីពីរបីសប្តាហ៍មុន ខ្ញុំបានទៅលេងលោក Aritide នៅទីក្រុង Pretoria ក្នុងប្រទេសអាហ្វ្រិកខាងត្បូងជាកន្លែងដែលលោក Aristide រស់នៅពីការនិរទេសខ្លួនដោយបង្ខំនោះ ។ ខ្ញុំបានសួរលោកថាតើមានអ្វីនៅពីក្រោយពីការធ្លាក់ចេញរបស់លោកជាមួយនឹងទីក្រុងវ៉ាស៊ីនតោន? លោកបានពន្យល់បក

ស្រាយដែលកម្រមានពួនៅក្នុងកិច្ចពិភាក្សានយោបាយនៃប្រទេសហៃទីជាក់ស្តែង លោកបាននិយាយបីដង ថា "ឯកជនភាវូបនីយកម្ម ឯកជនភាវូបនីយកម្ម ហើយនិងឯកជនភាវូបនីយកម្ម" ។

ជម្លោះកាលពីមុនដែលឆ្លងកាត់តាមរយៈកិច្ចប្រជុំជាច្រើនតាំងពីដើមឆ្នាំ ១៩៩៤ គឺជាវេលាដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសហៃទីដែលថា លោក Aristide កម្របានពិភាក្សាណាស់ ។ ប្រជាជនហៃទីបានរស់នៅក្រោមរបបដ៏ឃោរឃៅរបស់ Raoul Cedras ដែលបានផ្តួលរំលំលោក Aridide នៅក្នុងឆ្នាំ ១៩៩១ តាមរយៈការធ្វើរដ្ឋប្រហារដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ លោក Aristide នៅឯទីក្រុងវ៉ាស៊ីនតោន ហើយបើទោះណាជាមានការអំពាវនាវដ៏ប្រជាប្រិយ៍ ចំពោះការវិលត្រឡប់មកវិញរបស់លោកក៏ដោយ ក៏គ្មានមធ្យោបាយណាឱ្យគាត់ចុះចេញពីសភានីតិបញ្ញត្តិដោយគ្មានការគាំទ្រពីកងកម្លាំងប្រដាប់អាវុធបានដែរ ។ ភាពអាម៉ាស់មានការកើនឡើង តាមរយៈការរំលោភបំពានរបស់ Cedras, រដ្ឋបាលលោកគ្លីនតុនបានចរចារជាមួយលោក Aristideថា កងកម្លាំងសហរដ្ឋអាមេរិកនឹងជូនលោកទៅប្រទេសហៃទីវិញ ប្រសិនណាជាលោកយល់ព្រមបោសសំអាតកម្មវិធីសេដ្ឋកិច្ច ដូចដែលបានលើកឡើងក្នុងទិសដៅ "ធ្វើការផ្លាស់ប្តូរប្រទេសហៃទីទាំងស្រុង" ។

លោក Aristide បានយល់ព្រមសងបំណុលដែលបានកើនឡើងក្រោមរបស់ផ្តាច់ការ Duvalier, ជំរុះចោលនូវមន្ត្រីរាជការ បើចំហរប្រទេសហៃទីឱ្យទៅជាប្រទេស " ទីផ្សារសេរី " ហើយនិងកាត់ចេញពាក់កណ្តាលនូវពន្ធគយនាំចូលលើស្រូវ-អង្ករ ។ វាគឺជាការចរចារមួយដ៏ឈឺចាប់បំផុត ប៉ុន្តែលោក Aristide និយាយថា គាត់មានជំរើសយ៉ាងតិចតួចបំផុត ។ "ខ្ញុំត្រូវចាកចេញពីប្រទេសរបស់ខ្ញុំ ហើយប្រទេសរបស់ខ្ញុំគឺជាប្រទេសដ៏ក្រីក្របំផុតនៅក្នុងតំបន់ពាក់កណ្តាលបច្ចឹមប្រទេស ដូច្នេះសួរថា តើអំណាចអ្វីដែលខ្ញុំមាននៅក្នុងពេលនោះ?

ប៉ុន្តែអ្នកចរចារពីទីក្រុងវ៉ាស៊ីនតោនបានទាមទាមនូវសេចក្តីស្នើសុំមួយដែលលោក Aristide មិនអាចទទួលយកបាន នោះគឺការលក់នូវសហគ្រាសរដ្ឋរបស់ប្រទេសហៃទីទាំងអស់ជាបន្ទាន់ រួមទាំងទូរគមនា-គមន៍និងអគ្គិសនីផង ។ លោក Aristide បានជជែកវែកញែកថា ការធ្វើឯកជនភាវូបនីយកម្ម ដោយគ្មានច្បាប់ទម្លាប់អាចផ្លាស់ប្តូរទៅរកភាពផ្តាច់មុខរបស់រដ្ឋធ្លាក់ក្នុងដៃឯកជន ដែលអំណាចគ្រប់គ្រងធ្លាក់ក្នុង

ដៃជនមួយចំនួនតូច អ្នកដែលមានបំផុតនៅក្នុងប្រទេសហៃទីកាន់តែមានឡើង ហើយស្រូបយកទ្រព្យសម្បត្តិជាតិរបស់ខ្លួនដែលកំពុងតែក្រស្រាប់ ។ លោកបាននិយាយយ៉ាងសាមញ្ញថា វាមិនមានអ្វីកើនឡើងនោះទេ បើនិយាយដោយស្មោះត្រង់ទៅមានន័យថា បើពីរបូកនិងពីរវាទៅជាបួន ។ ប៉ុន្តែ គេចង់ឱ្យយើងចុះហត្ថលេខានៅលើឯកសារមួយដែលថា ពីរបូកពីរស្មើនិងប្រាំ ។

លោក Aristide បានសុំឱ្យមានការសម្រុះសម្រួលគ្នាមួយ ជាជាងការលក់នូវស្ថាប័នរដ្ឋ លោកនឹង "ធ្វើប្រជាធិបតេយ្យូបនីយកម្ម " ចំពោះពួកគេ ។ គាត់ឱ្យអត្ថន័យលើចំណុចជាលាយល័ក្ខអក្សរថា ច្បាប់ប្រឆាំងនិងការជឿទុកចិត្តធានាថា ចាប់ពីដំណើរការលក់ត្រូវធ្វើការចែកចាយឡើងវិញដល់អ្នកក្រ ហើយអនុញ្ញាតឱ្យកម្មករធ្វើជាអ្នកម្ចាស់ហ៊ុនដែរ ។ ទីក្រុងវ៉ាស៊ីនតោនមានការរារែក ហើយអត្ថបទចុងក្រោយនៃកិច្ចព្រមព្រៀងនោះបានទទួលយកដោយសហរដ្ឋអាមេរិក ហើយតាមរយៈកិច្ចប្រជុំប្រទេសអ្នកផ្តល់ជំនួយនៅទីក្រុងប៉ារីសអំពាវនាវឱ្យមាន "ប្រជាធិបតេយ្យូបនីយកម្ម" នៅតាមបណ្តាក្រុមហ៊ុនរដ្ឋ ។

ប៉ុន្តែនៅពេលដែលលោក Aristide បានចាប់ផ្តើមអនុវត្តផែនការ វាបែរជាអ្នកជំនាញខាងហិរញ្ញវត្ថុនៅទីក្រុងវ៉ាស៊ីនតោនគិតថា ការចរចារពីការធ្វើប្រជាធិបតេយ្យូបនីយកម្មគឺគ្រាប់តែជាទំនាក់ទំនងសាធារណៈតែប៉ុណ្ណោះ ។ នៅពេលដែលលោក Aristide បានប្រកាសថា គ្មានការលក់ណាមួយនឹងត្រូវធ្វើឡើងឡើយដរាបណារដ្ឋសភាមិនអនុម័តនូវច្បាប់ថ្មីទេនោះ ពេលនោះទីក្រុងវ៉ាស៊ីនតោនបានស្រែកឡើងថា វាមិនយុត្តិធម៌ទេ ។ បន្ទាប់មកលោក Aristide បាននឹកឃើញហើយនិយាយឡើងថា អ្វីដែលបាននឹងកំពុងប៉ុនប៉ងនោះគឺ "រដ្ឋប្រហារសេដ្ឋកិច្ច " ។ "អ្វីដែលលាក់កំបាំងគឺថា គេត្រូវដាក់លោកឱ្យកាន់អំណាចវិញ តែត្រូវតែនៅបញ្ចប់ពីក្រោយឱ្យប្រគល់នូវសហគ្រាសសាធារណៈទៅដល់ពួកគេដោយទទេៗ ។ "តែផ្ទុយមកវិញគាត់បានគំរាមតាមចាប់នរណាដែលធ្វើឯកជនភាវូបនីយកម្ម "។ ទីក្រុងវ៉ាស៊ីនតោន មានការខឹងសម្បាមកលើខ្ញុំយ៉ាងខ្លាំង ។ ពួកគេនិយាយថា ខ្ញុំមិនគោរពនូវពាក្យសម្តីរបស់ខ្ញុំ ប៉ុន្តែពួកគេឯណោះវិញទេ ដែលមិនគោរពពីគោលនយោបាយសេដ្ឋកិច្ចដ៏សាមញ្ញរបស់ពួកយើង ។

ចាប់តាំងពីពេលនោះមក ទំនាក់ទំនងរវាងលោក Aristide ជាមួយនិងទីក្រុងវ៉ាស៊ីនតោនកាន់តែមានការយ៉ាប់យ៉ឺនឡើងៗៈ នៅខណៈនោះទឹកលុយជាង៥០០លានដុល្លាអាមេរិក ដែលបានសន្យាថាផ្តល់ជាជំនួយនិងជាលុយកម្ចីនោះត្រូវបានកាត់ផ្តាច់ទៅវិញ ដែលធ្វើឱ្យរដ្ឋាភិបាលរបស់លោកមានភាពអត់ឃ្លានយ៉ាងខ្លាំង តែផ្ទុយទៅវិញ ទីភ្នាក់ងារអភិវឌ្ឍន៏របស់សហរដ្ឋអាមេរិកបែបជាចំណាយលុយរាប់សិបលាន ដុល្លាឱ្យទៅក្រុមអ្នកប្រឆាំងនិងរដ្ឋាភិបាលទៅវិញ ដែលនេះជាមូលហេតុបណ្តាលឱ្យមានរដ្ឋប្រហារ យោធាមួយបានកើតមានឡើងកាលពីខែកុម្ភៈ ឆ្នាំ ២០០៤ ។

សង្គ្រាមក៏ចេះតែបន្ត ។ នៅថ្ងៃទី ២៣ ខែ មិថុនា លោក Roger Noriege ដែលជាជំនួយការរដ្ឋលេខា-ធិការសំរាប់កិច្ចការពាក់កណ្តាលបច្ចឹមប្រទេស បានអំពាវនាវឱ្យកងកម្លាំងអង្គការសហប្រជាជាតិ " កាន់តែមានតួនាទីសកម្មឡើង "ក្នុងការបណ្តេញក្រុមដែលគាំទ្រលោក Aristide ។ ជាក់ស្តែង មិនត្រឹមតែ លោក Aristide នោះទេ ដែលត្រូវគេធ្វើបាបនោះ ប៉ុន្តែពួកគេថែមទាំងដាក់ទោសនិងធ្វើទារុណកម្មអ្នកជិតខាងរបស់លោកទៀតផង មិនថាអ្នកគាំទ្រលោកឬមិនគាំទ្រលោកនោះឡើយ ។ ឧទាហរណ៏ ដូចជានៅថ្ងៃទី ៦ ខែ កក្កដា កងកម្លាំងរបស់អង្គការសហប្រជាជាតិចំនួន៣០០នាក់បានវាយលុយCite Soleil បិទអស់នូវច្រកចេញចូល ហើយក៏បានធ្វើការបាញ់ផ្លោងចេញពីរថពាសដែក ។ អង្គការសហប្រជាជាតិសារភាពថា ការវាយប្រហារនោះបានសម្លាប់មនុស្សចំនួន ៥នាក់ ប៉ុន្តែតាមសំដីរបស់អ្នកស្រុក ដែលរស់នៅកន្លែងដែលបានវាយប្រហារនោះនិយាយថា អ្នកស្លាប់គឺមិនតិចជាង ២០នាក់ឡើយ ។ លោក Joseph Guyler Delva អ្នកឆ្លើយឆ្លងពិតមាន Reuters ឱ្យដឹងថា "គាត់បានឃើញសាកសព ៧ នាក់ នៅក្នុងផ្ទះមួយ " រួមទាំងទារក២នាក់ និងស្ត្រីចំណាស់ម្នាក់ក្នុងវ័យប្រហែលជា៦០ឆ្នាំ " ។ លោក Ali Besnaci ប្រធានអង្គការគ្រូពេទ្យគ្មានព្រំដែន (Medecins Sans Frontieres-MSF)នៅហៃទីបានអះ អាងបន្ថែមថា នៅថ្ងៃដែលមានការឡោមព័ទ្ធនោះ មានមនុស្សចំនួន២៥នាក់ បានមកគ្លីនិក MSF ដោយមានទទួលរងរបួលពីការបាញ់ប្រហារនោះផង បីភាគបួនក្នុងចំណោមអ្នកទាំងនោះ គឺស្ត្រីនិងកុមារ ។

ទោះបីជាមានការវាយប្រហារបែបនេះក៏ដោយ ប្រជាជនហៃទីនៅតែឈរនៅតាមដងផ្លូវ ហើយបដិសេធមិនព្រមទទួលយកការបោះឆ្នោតដែលមានបានគ្រោងធ្វើការបោកបញ្ឆោតនោះឡើយដោយប្រឆាំងទៅនឹងឯកជនភាពូបនីយកម្ម និងកាន់លើកឡើងនូវផ្ទាំងរូបភាពនៃប្រធានាធិបតេយ្យរបស់ពួកគេ ។

លោក Noriega បានថ្លែងថា ដូចដែលអ្នកឯកទេសរបស់ទីក្រុងវ៉ាស៊ីនតោនមិនអាចវាស់ស្ទង់បាននូវលទ្ធភាពដែលលោក Aristide អាចច្រានចោលនូវដំបូន្មានរបស់ពួកខ្លួនមួយទសវត្សកន្លងមកហើយ នោះហើយថ្ងៃនេះពួកគេមិនអាចទទួលយកបាននូវអ្នកគាំទ្រដ៏ក្រៃក្ររបស់លោកអាចជាតំណាងនូវកិច្ចព្រមព្រៀងរបស់គេដោយផ្ទាល់ ប្រាកដណាស់ លោក Aristide ត្រូវតែការពារពួកគេដោយភាពអាចិ កំបាំង ។ យើងជឿជាក់ថា ប្រជាជនរបស់លោកកំពុងតែទទួលការណែនាំដោយផ្ទាល់និងដោយប្រយោលតាមរយៈអ្នកដង្ហែតាមលោកពីប្រទេសអាហ្វ្រិកខាងត្បូង ។

លោក Aritide អះអាងថា គ្មានអំណាចអ្វីខ្លាំងជាងអំណាចប្រជាជននោះទេ "ពួកគេមានប្រាជ្ញាវាងវៃប៉ិនប្រសប់ហើយនិងមានសេចក្តីអង់អាចក្លាហាន "។ ពួកគេដឹងយ៉ាងច្បាស់ថា ពីរបូកនិងពីរមិនមែនប្រាំនោះទេ ។

# សេដ្ឋកិច្ចចក្រពត្តិ

## តើវិបត្តិនៃគំរោងអ្នកសកលនិយម ជំរុញសហរដ្ឋអាមេរិកឱ្យឈាន
## ទៅរកឯកតោភាគីនិយមដោយរបៀបណា?

# សេដ្ឋកិច្ចចក្រពត្តិ

## តើវិបត្តិនៃគំរោងអ្នកសកលនិយម ជំរុញសហរដ្ឋអាមេរិកឱ្យឈានទៅរកឯកតោភាគីនិយមដោយរបៀបណា?

ដោយលោក Walden Bello

អង្គការពាណិជ្ជកម្មពិភពលោកបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ។ ក្រោមលទ្ធផលនៃការចរចាររយៈពេល ៨ ឆ្នាំ អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានបង្កើតឡើងប្រៀបដូចជាត្បូងមិនទាន់ច្នៃនៃការគ្រប់គ្រងសេដ្ឋកិច្ចសកលក្នុងយុគសម័យសកលភាវូបនីយកម្ម ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មប្រហែល ២០ ដែលគាំទ្រការកកើតឡើងនៃអង្គការពាណិជ្ជកម្មពិភពលោក គឺជាការបង្កើតឡើងនូវច្បាប់ទម្លាប់ពហុភាគី ដែលដាក់ប្រទេសមានអំណាច និងប្រទេសទន់ខ្សោយឱ្យនៅក្រោមគោលការណ៍រួមមួយនៃច្បាប់ទាំងនោះ ក្រោមការអនុវត្តន៏វិធានការដ៏មានប្រសិទ្ធិភាព។ នៅក្នុងអង្គការពាណិជ្ជកម្ម ពិភពលោក គឺត្រូវបានគេអះអាងថា ប្រទេសមហាអំណាចដូចជា សហរដ្ឋអាមេរិច និងប្រទេសដ៏ទន់ខ្សោយបំផុត ដូចជា រ៉ាវ៉ាន់ដា មានចំនួនសម្លេងឆ្នោតដូចគ្នា : គឺមួយសម្លេង ។

## វិបត្តិគំរោងនៃអ្នកសកលនិយម

បច្ចុប្បន្ននេះ ជោគជ័យដែលទទួលបានកាលពីប៉ុន្មានឆ្នាំមុន គឺបាត់អស់ហើយ ។ នៅពេលការប្រជុំគណៈរដ្ឋមន្ត្រីលើកទី ៥ របស់អង្គការពាណិជ្ជកម្មពិភពលោក ខិតចូលមកដល់ អង្គការនេះស្ថិតជាប់គាំងក្នុងសំណាញ់ ។ កិច្ចព្រមព្រៀងថ្មីមួយលើ វិស័យកសិកម្មគ្មាននរណាមើលឃើញឡើយ ដោយសារសហរដ្ឋអាមេរិច និងសហគមន៍អឺរ៉ុប ខំប្រឹងការពារយ៉ាងខ្លាំងក្លា នូវការជួយឧបត្ថម្ភធនរាប់សិបលានដុល្លា ដល់ប្រជាជនរបស់គេ ។ ទីក្រុងប្រ៊ុសសែល (ប្រទេសប៊ែលស៊ិក) កំពុងតែជិត បង្កើតនូវល័ក្ខខ័ណ្ឌដាក់ទណ្ឌកម្មលើទីក្រុងវ៉ាស៊ីងតោន ដោយសារតែទីក្រុងនេះមិនយកពន្ធក្រុមហ៊ុននាំចេញនានាដែលត្រូវ គេរកឃើញថា មានការរំលោភលើច្បាប់ទម្លាប់ នានារបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ខណៈពេលនោះដែរ ទីក្រុង វ៉ាស៊ីងតោន បានគំរាមប្តឹងអង្គការពាណិជ្ជកម្មពិភពលោកប្រឆាំងនឹងសហគមន៍អឺរ៉ុប ឱ្យផ្អាកម្ហូបអាហារ GMO ។

ប្រទេសកំពុងអភិឌ្ឍន៍មួយចំនួនដែលធ្លាប់តែសង្ឃឹមថា អង្គការពាណិជ្ជកម្មពិភពលោក នឹងធ្វើឱ្យមានសមធមិលើផ្នែកពាណិជ្ជកម្មក្នុងពិភពលោកកើតឡើងនោះបានយល់ព្រមជាឯកច្ឆន្ទថា អ្វីដែលពួកគេទទួលបានពីការចូលជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោកនោះ គឺជាការខាតបង់ មិនមែនជាផលចំណេញទេ ។

ជំនួសឱ្យការប្រកាសអំពីការប្រជុំថ្មីដើម្បី ជជែកលើការធ្វើពាណិជ្ជកម្មសេរីភាវូបនីយកម្មសកល ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅទីក្រុងកង់គូន ទំនងជានឹងប្រកាស ពីភាពជាប់គាំង ។

តើមានអ្វីបានកើតឡើង? និយាយឱ្យខ្លី គឺចក្រពត្តិ ។ វាបែរចេញជាលទ្ធផលថា សកលភាវូបនីយកម្ម និងឯកតោភាគីនិយមរបស់សហរដ្ឋអាមេរិច គឺជារឿងផ្សេងគ្នា ។ តែមុនតំបូង យើងពិនិត្យមើលលើការកត់សំគាល់ខ្លះៗលើសកលភាវូប-នីយកម្ម និងគំរោងអ្នកសកលភាវូបនីយកម្ម ។

សកលភាវូបនីយកម្ម គឺជាការពន្លឿនសមាហរ័ណកម្មនៃដើមទុន ផលិតផល និងទីផ្សារនានាជាលក្ខណៈសកល ។ វាគឺជា ដំណើរការដែលជំរុញដោយហេតុផលនៃការរកប្រាក់ចំណេញ របស់សាជីវកម្មនានា ។ សកលភាវូបនីយកម្មត្រូវបានផ្តល់ និយមន័យដោយមនោគមវិជ្ជានៃអនុត្តរភាពសេរីនិយមបែបថ្មី ដែលផ្តោតទៅលើ "ការបើកចំហដោយសេរីផ្នែកទីផ្សារ " តាមរយៈឯកជនភាវូបនីយកម្ម ការកែប្រែប្រពន្ធ័ច្បាប់ (អនិយត្តកម្ម) និងសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្ម ។ និយាយ ឱ្យងាយយល់ មនោគមវិជ្ជាសេរីនិយមបែបថ្មីមានពីរទម្រង់ គឺទម្រង់ "រឹង" តាមបែប Thatcher-Reagan និងទម្រង់ "ទន់" តាមបែប Blair-Soros "សកលភាវូបនីយកម្ម" និង "សុវត្ថិភាពពេញលេញ " ។ ប៉ុន្តែ នៅពីក្រោមយុទ្ធសាស្ត្រទាំងពីរនេះ គឺ ការបណ្តោយទៅតាមកំលាំងទីផ្សារ និងការដកចេញ ឬកាត់បន្ថយបន្តិចម្តងៗ នូវឧបសគ្គនានាដែលកម្មករ រដ្ឋាភិបាល និងសង្គម បានដាក់លើក្រុមហ៊ុនចំរុះជាតិសាសន៍នានា ។

## ព្រឹត្តិការណ៍សំខាន់បីនៃវិបត្តិសកលភាវូបនីយកម្ម

មានព្រឹត្តិការណ៍សំខាន់ៗបី នៅក្នុងវិបត្តិយ៉ាងជ្រៅនៃគំរោងអ្នកសកលភាវូបនីយកម្ម ។ ព្រឹត្តិការណ៍ទីមួយគឺ វិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ ១៩៩៧ ។ ព្រឹត្តិការណ៍នេះ ស្ថិតនៅត្រង់មោទនភាពនៃប្រទេស "កូនខ្លា" របស់អាស៊ីខាងកើត ដែលបានបង្ហាញឱ្យឃើញថា គន្លឹះសំខាន់មួយនៃសកលភាវូបនីយកម្ម-ការធ្វើសេរីភាវូបនីយកម្មលើបញ្ជីដើមទុនមូលធន ដើម្បីលើកកំពស់លំហូរដើមទុនឱ្យមានលក្ខណៈងាយស្រួលជាង ជាពិសេសហិរញ្ញវត្ថុ ឬក៏ដើម ទុនដែលប្រថុយដែលអាចបង្ករអស្ថេរភាពយ៉ាងខ្លាំងនាពេលអនាគត។ ព្រឹត្តការណ៍នេះត្រូវបានបង្ហាញ ឃើញយ៉ាងច្បាស់ តែក្នុងពេលប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ ដែលមនុស្ស ១ លាននាក់ នៅប្រទេសថៃ និង២១ លាននាក់ នៅប្រទេសឥណ្ឌូនេស៊ីត្រូវ បានរុញច្រានឱ្យរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ។

វិបត្តិហិរញ្ញវត្ថុនៅអាស៊ីគឺជា "ស្ពាលីនក្រាត" នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (៥) ដែលជាទីភ្នាក់ងារមួយឈានមុខគេលើពិភពលោកក្នុងការជំរុញនូវសេរីភាវូបនីយកម្មលើលំហូរដើមទុន ។ កំណត់ត្រារបស់មូលនិធិនេះ គឺជាសហគ្រាសដែល ប្រកបដោយមហិច្ឆិតា ដែលជំរុញឱ្យសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ប្រមាណ ១០០ ប្រទេស ឱ្យស្ថិតនៅក្រោម ឥទ្ធិពល "កំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ" ត្រូវបានរកឃើញថា ជាតំរូវការចាំបាច់របស់មូលនិធិនេះ ។ កម្មវិធីកំណែទម្រង់ ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានតាក់តែងឡើងដើម្បីពន្លឿនការធ្វើអនិយត្តកម្មសេរីភាវូបនីយកម្មលើពាណិជ្ជកម្ម និងឯកជន ភាវូបនីយកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ស្ទើរតែគ្រប់ទីកន្លែង កម្មវិធីនេះនាំឱ្យសេដ្ឋកិច្ចក្នុង ប្រទេសមិនរីកចំរើន ហើយភាពក្រីក្រ និងវិសមភាពមានការកើនឡើង ។

មួយរយៈខ្លី ក្រោយពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ី បញ្ញវ័ន្តសំខាន់ៗដែលតែងតែការពារគំរូនៃក្រុមទីផ្សារសេរីនិយមបែបថ្មីបានចាប់ផ្តើមចេញមុខមក ក្នុងនោះ Jeffrey Sachs ដែលត្រូវបានកត់សំគាល់ពីអតីតកាលចំពោះការតស៊ូមតិរបស់គាត់លើ "ទីផ្សារសេរី" ដែលជាការតក់ស្លុតមួយលើការស្រោចស្រង់សេដ្ឋកិច្ចនៅអឺរ៉ុបខាងកើតនាដើមទសវត្សឆ្នាំ ១៩៩០) លោក Joseph Stiglitz អតីតប្រធានសេដ្ឋវិទូធនាគារពិភពលោក លោកសាស្ត្រាចារ្យ ាងជិសហ ពហាមិាតិ បង្រៀននៅសាកល វិទ្យាល័យកូឡុំប៊ី ។ បេក្ខជនសំខាន់ទាំងបីនេះ បានអំពាវនាវឱ្យមានការត្រួតត្រាជាសកលលើលំហូរមូលធនហើយ ហិរញ្ញិក George Soros បានថ្កោលទោសពីកង្វះខាតនៃការត្រួតត្រានានាលើប្រព័ន្ធហិរញ្ញវត្ថុសកលដែលធ្លាប់បានធ្វើឱ្យ គាត់ល្បីល្បាញ ។

ព្រឹត្តការណ៍សំខាន់ទីពីរ នៃវិបត្តិគំរោងអ្នកសកលភាវូបនីយមកម្មគឺ ការបរាជ័យនៃការប្រជុំគណៈរដ្ឋមន្ត្រីលើកទី ៣ របស់អង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុងស៊ៀតថល សហរដ្ឋអាមេរិកកាលពីខែធ្នូឆ្នាំ ១៩៩៩ ។ ទីក្រុង ស៊ៀតថល គឺជា ចំណុចប្រសព្វស្លាប់រស់របស់ចរន្តបីនៃភាពទោមនស្ស និងវិវាទដែលបានកើនឡើងមួយ រយៈមកហើយៈ

- បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បានអាក់អន់ចិត្តចំពោះអសមធម៌ នៃកិច្ចព្រមព្រៀងនានាក្នុងកិច្ចប្រជុំតុមូល យ៉ូរ៉ាហ្គាយ (Uragay Round) ដែលពួកគេគិតថាត្រូវបានបង្ខំឱ្យចុះហត្ថលេខាក្នុងឆ្នាំ ១៩៩៥ ។
- អ្នកជំទាស់ប្រឆាំងទៅនឹងអង្គការពាណិជ្ជកម្មពិភពលោកជាច្រើន បានផុសឡើងទូទាំងពិភពលោកពីគ្រប់មជ្ឈដ្ឋាន តាំងពីសង្គមស៊ីវិល កសិករ អ្នកនេសាទ សហជីពកម្មករ អ្នកបរិស្ថានលើពិភពលោក ។ល។ ដោយលើកឡើងពី ការគំរាមកំហែងលើផ្នែកសុខុមាលភាព

និងលើវិស័យនីមួយៗនៅក្នុងកិច្ចព្រមព្រៀងជាច្រើនរបស់ខ្លួន អង្គការ ពាណិជ្ជកម្មពិភពលោក អាចប្របាច់បញ្ចូលសង្គមស៊ីវិលក្នុងពិភពលោក ឱ្យប្រឆាំងទៅនឹងអង្គការនេះ ។

- វិវាទពាណិជ្ជកម្មដែលនៅមិនទាន់បានដោះស្រាយរវាងសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ជាពិសេសវិស័យកសិកម្ម ដែលលាក់បាំង (ពីកំហុស) ដោយកិច្ចព្រមព្រៀងនាកិច្ចប្រជុំតុមូលនៅយូរ៉ាហ្គាយ ។

កត្តាទាំងបីនេះ រួមគ្នាបង្កើតឱ្យមានការផ្ទុះឡើងនៅទីក្រុងសៀតថល ។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើការប្រឆាំង តវ៉ានឹងសេចក្តីប្រកាសរបស់លោកខាងជើង ។ នៅមណ្ឌលធ្វើសន្និបាតនាទីក្រុងសៀតថល មានមនុស្ស ៥០,០០០នាក់ បានប្រមូលផ្តុំគ្នាយ៉ាងសកម្មនៅតាមដងផ្លូវ ហើយភាពខុសគ្នាទាំងនេះ បានបង្កាមិនឱ្យសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ធ្វើសកម្មភាពដើម្បីស្រោចស្រង់ការប្រជុំគណៈរដ្ឋមន្ត្រីឡើងវិញបានឡើយ ។ ក្នុងខណៈពេលបង្ហាញ ឱ្យឃើញយ៉ាងច្បាស់ បន្ទាប់ពីការបរាជ័យនៃកិច្ចប្រជុំនៅសៀតថល លោក Stephen Byer រដ្ឋលេខាធិការអង់គ្លេសបានចាប់យកខ្លឹមសារនៃ វិបត្តិនោះថា "អង្គការពាណិជ្ជកម្មពិភពលោក នឹងមិនអាចបន្តធ្វើការនៅក្នុងទ្រង់ទ្រាយរបស់ខ្លួន នាពេលបច្ចុប្បន្ននេះបានទេ គឺត្រូវតែមានការកែប្រែមូលដ្ឋានគ្រឹះយ៉ាងឆាប់រហ័ស ដើម្បីឱ្យអង្គការនេះអាចផ្តល់តាមសេចក្តីត្រូវការ និងសេចក្តីប្រាថ្នា របស់សមាជិកទាំង ១៣៤ របស់ខ្លួន ។"

ព្រឹត្តិការណ៍សំខាន់ទីបីនៃវិបត្តិ គឺការដួលរលំនៃទីផ្សារភាគហ៊ុន និងការបញ្ចប់នៃយុគសម័យរីកចំរើនរបស់គ្លីនតុន ។ វាមិន គ្រាន់តែជាការបែកពពុះដូចទឹកយ៉ាងឆាប់រហ័សប៉ុណ្ណោះទេ តែវាជាការអះអាងឡើងវិញដ៏គ្រោតគ្រាតនៃវិបត្តិរបស់ពួក មូលធននិយមនូវការផលិតដ៏ច្រើនលើសលុបហួសពីតំរូវការ ដែលជាការស្តែងអោយឃើញយ៉ាងសំខាន់ គឺទំហំច្រើនហួសពី សមត្ថភាពប្រើប្រាស់ ។ មុនពេលការប៉ះទង្គិចកើតឡើង ប្រាក់ចំណេញរបស់សាជីវកម្មនៅសហរដ្ឋអាមេរិចគ្មានការកើន ឡើងទេ តាំងពីឆ្នាំ១៩៩៧ ។ ការប៉ះទង្គិចនេះ គឺទាក់ទងនឹងភាពហួសពីសមត្ថភាពដែលកើតមាននៅក្នុងវិស័យ ឧស្សាហកម្ម ឧទាហរណ៍ ដែលឃើញយ៉ាងច្បាស់ គឺក្នុងវិស័យទូរគមនាគមន៍ដែលត្រឹមតែ២.៥ភាគរយ នៃសមត្ថភាព រក្សាទុកទាំងមូលត្រូវបានប្រើប្រាស់ ។ ភាពនៅទ្រឹងនៃសេដ្ឋកិច្ចនេះបាននាំឱ្យដើមទុនត្រូវប្តូរទៅជាវិស័យហិរញ្ញវត្ថុ បណ្តាលឱ្យមានភាពមិននឹងនរនៃការកើនឡើងនូវតំលៃភាគហ៊ុន ។ ប៉ុន្តែ តាំងពីប្រាក់ចំណេញនៅក្នុងវិស័យហិរញ្ញវត្ថុ មិនអាចចេញឆ្ងាយពីផលប្រយោជន៍នៃសេដ្ឋកិច្ចពិតប្រាកដការដួលរលំនៃតំលៃភាគហ៊ុន គឺមិនអាចចៀសរួចឡើយ ។ ព្រឹត្តិការណ៍នេះ បានកើតឡើងនៅខែមីនា ឆ្នាំ២០០១ ដែលនាំទៅរកការពន្យារនូវភាពនៅទ្រឹងមួយកន្លែង និងការចាប់ ផ្តើមនៃអតិផរណាសាច់ប្រាក់។

## សេដ្ឋកិច្ចថ្មីរបស់ GEORGE W BUSH

វិបត្តិនៃសកលភាវូបនីយកម្ម សេរីនិយមបែបថ្មី និងការផលិតច្រើនហួសតំរូវការ ផ្តល់នូវបរិបទដើម្បីស្វែងយល់ពីគោលនយោបាយសេដ្ឋកិច្ចនៃរដ្ឋបាលរបស់លោកប៊ូស ហើយចំណុចដែលគួរឱ្យកត់សំគាល់នោះគឺការជំរុញនូវឯកតោភាគីនិយម ។ គំរោងអ្នកសកលភាវូបនីយកម្មសាជីវកម្ម បានបង្ហាញនូវចំណាប់អារម្មណ៍រួមរបស់វរជនមូលធននិយមក្នុងពិភពលោក ក្នុងការពង្រីកសេដ្ឋកិច្ចពិភពលោក និងការពឹងផ្អែកជាមូលដ្ឋានគ្រឹះរបស់ពួកគេលើគ្នាទៅវិញទៅមក ។ ទោះជាយ៉ាងណាក៏ ដោយ គំរោងនេះមិនបានលុបបំបាត់នូវការប្រកួតប្រជែងរវាងវរជនរបស់ប្រទេសនីមួយៗឡើយ ។ ការពិតក្រុមវរជនដែលគ្រប់គ្រងនៅសហរដ្ឋអាមេរិក និងអឺរ៉ុប មានបក្សពួកផ្សេងៗដែលជាក្រុមលក្ខណៈជាតិនិយម និងជាប់ទាក់ទងគ្នាទៅវិញទៅមកដើម្បីការរស់រានមានជីវិត និងភាពរុងរឿងដល់ប្រទេសជាតិរបស់ពួកគេដូចជាឧស្សាហកម្មយោធាដែលមានលក្ខណៈស្មុគស្មាញនៅសហរដ្ឋអាមេរិក ។ មែនហើយ តាំងពីទសវត្សឆ្នាំ៨០ មានការរើបំរះដ៏មុតស្រួចមួយរវាងក្រុម វរជនអ្នកគ្រប់គ្រងដែលគិតគូរសង្កត់ធ្ងន់តែលើផលប្រយោជន៍របស់វណ្ណៈមូលធននិយមក្នុងពិភពលោកជាធំ និងក្រុមជាតិនិយម ដែលចង់ធ្វើឱ្យប្រាកដថា ផលប្រយោជន៍របស់សាជីវកម្មសហរដ្ឋអាមេរិក គឺជារឿងចំបងបំផុត ។

លោក Robert Brenner បានលើកឡើងថា គោលនយោបាយនានារបស់លោកប៊ីល គ្លីនតុន និងរដ្ឋលេខាធិការរតនាគារ Robert Rubin បានធ្វើការបញ្ជាក់យ៉ាងច្បាស់ លើការពង្រីកសេដ្ឋកិច្ចពិភពលោកជាមូលដ្ឋានគ្រឹះនៃភាពរុងរឿងរបស់វណ្ណៈ មូលធនពិភពលោក ។ ឧទាហរណ៍ នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ ពួកគេបានជំរុញគោលនយោបាយប្រាក់ដុល្លារឹងមាំ មួយដើម្បីសម្រួលដល់ការស្រោចស្រង់សេដ្ឋកិច្ចជប៉ុន និងអាឡឺម៉ង់ ធ្វើដូចនេះប្រទេសទាំងពីរនេះអាចផ្តល់ទីផ្សារសម្រាប់ ទំនិញ និងសេវាកម្មនានារបស់សហរដ្ឋអាមេរិក។ ម្យ៉ាងវិញទៀតកាលពីរដ្ឋបាលជាតិនិយមមុនរបស់លោក Reagan បាន អនុវត្តន៏គោលនយោបាយ ប្រាក់ដុល្លាទន់ខ្សោយ ដើម្បីយកចំណេញនូវការប្រកួតប្រជែងសំរាប់សេដ្ឋកិច្ចសហរដ្ឋអាមេរិក ក្រោមការខាតបង់នៃ សេដ្ឋកិច្ចជប៉ុន និងអាឡឺម៉ង់។ ជាមួយរដ្ឋបាល George W Bush ពិភពលោកយើងងាកទៅរក គោលនយោបាយប្រាក់ដុល្លាទន់ខ្សោយ និងនយោបាយផ្សេងៗទៀត ដែលមានគោលបំណងស្រោចស្រង់សេដ្ឋកិច្ច សហរដ្ឋអាមេរិកក្រោមការខាតបង់នៃសេដ្ឋកិច្ចប្រទេសផ្សេងៗទៀត ។ លក្ខណៈមួយចំនួននៃយុទ្ធសាស្ត្រនេះគួរតែលើកយកមក បង្ហាញ:

- នយោបាយសេដ្ឋកិច្ចរបស់ប៊ូស មានការប្រុងប្រយ័ត្នណាស់ពីដំណើរការសកលភាវូបនីយកម្ម ដែលដំណើរការនេះ មិនមែននៅក្រោមការគ្រប់គ្រងដោយរដ្ឋណាមួយនៃសហរដ្ឋអាមេរិកនោះដើម្បីធានាថា ដំណើរការនេះមិនធ្វើឱ្យ សាយភាយអំណាចសេដ្ឋកិច្ចសហរដ្ឋអាមេរិកឡើយ ។ ការអនុញ្ញាតឱ្យទីផ្សារ តែមួយមុខជំរុញ

សកលភាវូបនីយ-កម្មអាចបណ្តាលឱ្យសាជីវកម្មសំខាន់ៗរបស់អាមេរិកក្លាយជាជន រងគ្រោះដោយសកលភាវូបនីយកម្ម ។ ហេតុ ដូច្នេះ ក្រៅពីការឃោសនាទីផ្សារសេរី យើងនៅមានក្រុមមួយដែលជាអ្នកការពារយ៉ាងខ្លាំងក្លាលើការធ្វើពាណិជ្ជ កម្មការវិនិយោគ និងការគ្រប់គ្រងលើកិច្ចសន្យានានារបស់រដ្ឋាភិបាល ។ វាហាក់ដូចជាបាវចនានៃពួកអ្នកគាំទ្រ លោកប៊ូស គឺការការពារយ៉ាងរឹងមាំសំរាប់ ទីផ្សារសាជីវកម្មរបស់សហរដ្ឋអាមេរិក និងទីផ្សារសេរីសំរាប់សាជីវ-កម្មទាំងនេះនៅប្រទេសដទៃទៀតលើពិភពលោក ។

- រដ្ឋបាលលោកប៊ូសប្រុងប្រយ័ត្នណាស់ ចំពោះពហុតោភាគីនិយម ជាវិធីមួយនៃការគ្រប់គ្រង សេដ្ឋកិច្ចពិភពលោក ពីព្រោះពហុតោភាគីនិយមអាចលើកស្ទួយដល់ផលប្រយោជន៍របស់វណ្ណៈមូលធនទូទៅ ដែលជារឿយៗ វាអាច ផ្ទុយនឹងផលប្រយោជន៍ជាក់លាក់របស់សាជីវកម្មសហរដ្ឋអាមេរិក ។ ការការពារផល ប្រយោជន៍របស់ក្រុម លោកប៊ូស ដែលកាន់តែកើនឡើងនូវការខ្វែងគំនិតគ្នាចំពោះអង្គការពាណិជ្ជកម្មពិភពលោក គឺកើតមកពីការពិត ដែលថា សហរដ្ឋអាមេរិកបានបាត់បង់នូវការគ្រប់គ្រងមួយចំនួននៅអង្គការពាណិជ្ជកម្មពិភពលោក ការគ្រប់គ្រង ដែលអាចប៉ះពាល់ដល់ដើមទុនរបស់សហរដ្ឋអាមេរិក តែបំរើផលប្រយោជន៍នៃមូលធននិយមពិភពលោកជារួម ។
- សម្រាប់ក្រុមមនុស្សលោកប៊ូស អំណាចយុទ្ធសាស្ត្រគឺជាទម្រង់ដ៏ខ្ពស់បំផុតនៃអំណាច ។

កំលាំងសេដ្ឋកិច្ច គឺជាមធ្យោបាយដើម្បីសំរេចអំណាចយុទ្ធសាស្ត្រ ។ រឿងនេះទាក់ទងនឹងការពិតដែលថា នៅក្រោមការគ្រប់គ្រងរបស់លោកប៊ូស ក្រុមដែលមានឥទ្ធិពលនៃវរជនគ្រប់គ្រង គឺការស្ថាបនាឧស្សាហកម្មយោធាដែលទទួលបានជោគជ័យលើសង្គ្រាមត្រជាក់ ។ វិវាទរវាងអ្នកសកលភាវូបនីយកម្មនិយម និងអ្នកឯតោភាគីនិយម (មិនមែនអ្នកជាតិនិយម) នៅលើអ័ក្សនេះត្រូវបានបង្ហាញលើយុទ្ធសាស្ត្រឆ្ពោះទៅរកប្រទេសចិន ។ យុទ្ធសាស្ត្ររបស់អ្នកសកលភាវូបនីយកម្ម គឺសង្កត់ធ្ងន់លើការទាក់ទងជាមួយប្រទេសចិន ដោយពួកគេមើលឃើញពីសារៈសំខាន់ជាអាទិភាពថា ប្រទេសនេះ ជាកន្លែងសំរាប់ការវិនិយោគ និងជាទីផ្សារសម្រាប់ដើមទុនសហរដ្ឋអាមេរិក។ តែចំពោះពួកអ្នកជាតិនិយមវិញ បែរជា មើលឃើញ ប្រទេសចិនជាសត្រូវយុទ្ធសាស្ត្រសំខាន់មួយ ហើយពួកគេចង់ទប់ស្កាត់ជាជាងជួយប្រទេសនេះ ឱ្យមានការ រីកចំរើន ។

បើសិនជាទាំងនេះត្រូវយល់ឃើញថា ជាកន្លែងសំរាប់ធ្វើសកម្មភាព ដូច្នេះកត្តាសំខាន់ៗនៃគោលនយោបាយសេដ្ឋកិច្ចសហរដ្ឋអាមេរិកបច្ចុប្បន្នទាំងប៉ុន្មានខាងក្រោមនេះ អាចធ្វើឱ្យយើងយល់បាន៖

- **សម្រេចបាននូវការគ្រប់គ្រងលើប្រេងឥន្ធនៈនៅមជ្ឈឹមបូពា៌:**

ទោះបីជាសហរដ្ឋអាមេរិកគ្មានការនឿយហត់ក្នុង ការធ្វើសង្គ្រាមដែលមានគោលបំណងគ្រប់គ្រង និងឈ្លានពានប្រទេសអ៊ីរ៉ាក់ ការគ្រប់គ្រងប្រេង គឺជាគោល បំណងចំបងនៅក្នុងបញ្ជីរបស់អាមេរិក ។ ការប្រកួតប្រជែងពីសំណាក់សហគមន៍អឺរ៉ុបជាមួយអាមេរិក គឺជាទស្សនៈវិស័យចំបងនៃទំនាក់ទំនងឆ្លងមហាសមុទ្រអាត្លង់ទិច ដូច្នេះក្រៅពីគោលនយោបាយគ្រប់គ្រងប្រេងឥន្ធនៈនៅមជ្ឈឹមបូពា៌ មួយចំណែកគឺគ្រប់គ្រងអឺរ៉ុប ។ ក៏ប៉ុន្តែ គោលដៅយុទ្ធសាស្ត្រខ្លាំងជាងគេនោះ គឺបង្ការ នូវធនធានប្រេងនៅតំបន់នេះ ដើម្បីត្រួតត្រាមិនឱ្យប្រទេសចិន (ដែលជាប្រទេសធំតែក្រីក្រ) ក្នុងការទទួល បាននូវធនធានទាំងនេះយកទៅប្រើក្នុងឧស្សាហកម្មរបស់ចិន ព្រោះគេយល់ឃើញថា ប្រទេសចិនជាសត្រូវ យុទ្ធសាស្ត្ររបស់អាមេរិក ។

- **ការការពារនិយមយ៉ាងគឃ្លើនលើបញ្ហាពាណិជ្ជកម្ម និងវិនិយោគទុនៈ**

សហរដ្ឋអាមេរិកបានបង្កើតច្បាប់ជាបន្ត បន្ទាប់ដើម្បីការពារពាណិជ្ជកម្ម និងវិនិយោគរបស់ខ្លួន ។ បញ្ហាមួយដ៏ឃោរឃៅបំផុតនោះគឺធ្វើឱ្យការចរចារនានានៅអង្គការពាណិជ្ជកម្មពិភពលោកលើបញ្ហា សំខាន់បំផុត គឺសុខភាពសាធារណៈនោះទាល់ច្រក ។ ក្នុងនាមនៃការបញ្ចុះបញ្ចូលរបស់ក្រុមហ៊ុនថ្នាំពេទ្យ ដ៏មានអំណាច សហរដ្ឋអាមេរិកទប់ស្កាត់យ៉ាងខ្លាំងក្លាលើការ បាត់បង់នៃសិទ្ធិប៉ាតង់(ប្រកាសនីយប័ត្រកម្ម) លើឱសថព្យាបាល ជំងឺតែបីប្រភេទប៉ុណ្ណោះ ។ ក្នុងខណៈពេល ដែលសហរដ្ឋអាមេរិកហាក់ដូចជាមានឆន្ទៈល្អឥតខ្ចោះ ក្នុងការមើលឃើញនូវការចរចារនានារបស់អង្គការ ពាណិជ្ជកម្មពិភពលោកដំណើរល្អនិងដោះស្រាយបញ្ហាទាំងឡាយ នៅទីក្រុងវ៉ាស៊ីងតោនបាន និងកំពុងយកចិត្ត ទុកដាក់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ឬពហុភាគីជាមួយបណ្តាប្រទេសមួយ ចំនួន ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃតំបន់អាមេរិក (FTAA) មុនពេលសហគមន៍អឺរ៉ុបចុះហត្ថលេខាស្រដៀងគ្នាជាមួយបណ្តា ប្រទេសទាំងនេះ ។ តាមពិត ឈ្មោះថា "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី" គឺជាការ ហៅខុសទេ ពីព្រោះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងនេះ គឺជាកិច្ចព្រមព្រៀងដែលមានការអនុគ្រោះ (ជ្រើសរើសប្រទេស ដើម្បីធ្វើពាណិជ្ជកម្មជាមួយ តាមការចូលចិត្តរបស់អាមេរិក) ។

- **ការបញ្ចូលការពិចារណាយុទ្ធសាស្ត្រក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា:**

នៅក្នុងសន្ទរកថាមួយនាពេលថ្មីៗ នេះ លោក Roobert Zoellick អ្នកតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិកបានថ្លែងយ៉ាងច្បាស់ថា "ប្រទេស ដែលស្វែងរកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយសហរដ្ឋអាមេរិក ត្រូវតែឆ្លងកាត់លក្ខណៈដែលបាន កំណត់

ហើយកិច្ចព្រមព្រៀងអាច ធ្វើទៅបាន គឺប្រទេសទាំងនោះមិនត្រឹមតែលក្ខណៈសម្បត្តិផ្នែកពាណិជ្ជកម្ម និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ត្រូវមានលក្ខណៈសម្បត្តិពិសេសផ្សេងៗទៀត ។ យ៉ាងហោចណាស់ប្រទេសទាំងនេះ ត្រូវតែសហការជាមួយអាមេរិចលើគោលនយោបាយការបរទេស និងគោលបំណងរក្សាសន្តិសុខជាតិរបស់ អាមេរិច ចំណុចនេះជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យទាំង១៣ ដែលនឹងដឹកនាំអាមេរិចក្នុងការជ្រើសរើសដៃគូរ ដែលមានសក្តានុពលសំរាប់ធ្វើពាណិជ្ជកម្មសេរី (FTAA) ជាមួយខ្លួន ។ ប្រទេសញូសេឡេន ប្រហែលជាប្រទេសមួយដែលបានប្តេជ្ញាធ្វើពាណិជ្ជកម្មសេរីបំផុត មិនត្រូវបានផ្តល់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយអាមេរិកឡើយ ពីព្រោះប្រទេសនេះមានគោលនយោបាយ ដែលបង្ការមិនឱ្យកប៉ាល់ដឹកអាវុធ នុយក្លេអ៊ែរចូលចតក្នុងផែណាមួយនៃប្រទេសនេះ ដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកយល់ថា គោលនយោបាយ នេះ គឺសំដៅចំពោះ កប៉ាល់របស់សហរដ្ឋអាមេរិក ។

- **ការប្រើតំលៃប្រាក់ដុល្លាដើម្បីជំរុញការប្រជែងសេដ្ឋកិច្ចឧស្សាហកម្មដើម្បីទទួលយកតំលៃ ដោយហេតុនេះធ្វើឱ្យសេដ្ឋកិច្ចសហរដ្ឋអាមេរិកទទួលបានការប្រកួតប្រជែង:**
  នៅខណៈពេលរដ្ឋបាលលោកប៊ូស បានបដិសេធ នូវនយោបាយ Beggar-Thy-Neighbor នោះពាណិជ្ជកម្មបន្ទាន់របស់សហរដ្ឋអាមេរិកបានសំលឹងមើលថា:
  ការខិតខំប្រឹងប្រែងដើម្បីស្រោចស្រង់សេដ្ឋកិច្ចអាមេរិក ក្រោមការខាតបង់នៃសេដ្ឋកិច្ចសហគមន៍អឺរ៉ុប និង ស្ថាប័នសេដ្ឋកិច្ចរបស់ប្រទេសដទៃទៀត ។
- **ការសំរបសំរួលយ៉ាងគឃ្លើននៃទីភ្នាក់ងារពហុភាគី ដើម្បីជំរុញឱ្យមូលធនអាមេរិកទទួលផលប្រយោជន៍:**
  ខណៈពេលដែលការសំរបសំរួលនេះ
  ប្រហែលជាមិនងាយស្រួលនឹងទទួលបានទេនៅក្នុងអង្គការពាណិជ្ជកម្ម
  ពិភពលោកដោយសារតែសំពាធពីសហគមន៍អឺរ៉ុបនោះ ការសំរបសំរួលនេះវានឹងងាយស្រួលធ្វើជាងតាមរយៈធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ព្រោះការគ្រប់គ្រងរបស់អាមេរិកនៅតាមស្ថាប័នទាំងនេះមានប្រសិទ្ធិភាពខ្ពស់ ។ តួយ៉ាងដូចជាការគ្រប់គ្រងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានស្នើឱ្យមានយន្តការដើម្បីធ្វើកំណែទម្រង់ប្រកបដោយប្រសិទ្ធិភាពលើបំណុល (Sovereign Debt Restructuring Mechanism) ដែលនឹងធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍ធ្វើកំណែទម្រង់ឡើងវិញនូវបំណុលរបស់ខ្លួន ដែលផ្តល់ឱ្យ ពួកគេនូវការការពារពីសំណាក់ប្រទេសម្ចាស់បំណុល ។ ទោះបីនេះជាយន្តការដ៏ទន់ខ្សោយមួយក៏ដោយ ក៏រតនាគារជាតិអាមេរិកបានជំទាស់លើយន្តការនេះ

ដើម្បីផលប្រយោជន៍ធនាគារមួយចំនួនរបស់អាមេរិក
ទោះបីជាមានការគាំទ្រយ៉ាងច្រើនពីរដ្ឋាភិបាលនានាក្នុងសហគមន៍អឺរ៉ុបក៏ដោយ ។

**សេដ្ឋកិច្ច និងនយោបាយដែលហួសពីសមត្ថភាព**

ការពិភាក្សាណាក៏ដោយ អំពីលទ្ធផលនៃគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋបាលលោកប៊ូស ត្រូវតែយកមកគិតពិចារណា ទាំងស្ថានភាពសេដ្ឋកិច្ចអាមេរិកព្រមទាំងសេដ្ឋកិច្ចពិភពលោក និងស្ថានភាពយុទ្ធសាស្ត្រក្នុងទ្រង់ទ្រាយធំ។ មូលដ្ឋានគ្រឹះ មួយសម្រាប់ឱ្យចក្រពត្តិគ្រប់គ្រងបានជោគជ័យ គឺការពង្រីកសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចពិភពលោក បង្ការការពន្យាពេលនៃ អតិផរណា និងភាពជាប់គាំងដែលអាចកើតមានដែលទំនងជាធ្វើឱ្យសន្ទុះនៃការប្រកួតប្រជែងអន្តរមូលធនកើនឡើង ។ ដោយគ្មានក្នុងក្របខណ្ឌច្បាប់ក្នុងការគ្រប់គ្រងរបស់ចក្រពត្តិ គឺភ្ជាប់មកជាមួយនូវអស្ថេរភាព ។

ឧទាហរណ៍ ចក្រពត្តិរ៉ូម៉ាំងដោះស្រាយបញ្ហាដែលត្រូវតាមច្បាប់របស់ខ្លួនតាមរយៈនយោបាយ មិនមែនប្រើកំលាំងយោធា ទេ ។ ចក្រពត្តិនេះបានពង្រីកជនជាតិរ៉ូម៉ាំងរហូតដល់ក្រុមអ្នកកាន់អំណាច និងប្រជាជនដែលមិនមែនជាទាសករនៅគ្រប់ ពេល និងគ្រប់ទីកន្លែងក្នុងចក្រភព ។ នយោបាយប្រជាជនរួមជាមួយទស្សនៈវិស័យនៃចក្រពត្តិនេះ ផ្តល់នូវសុខសន្តិភាព និងភាពរុងរឿងសំរាប់ប្រជាជនទាំងអស់ ហើយបានបង្កើតនូវកត្តាសីលធិមអរូបិយយ៉ាងសំខាន់ ហៅថាភាពស្របច្បាប់ យើងមិនចាំបាច់និយាយថា ការពង្រីកនៃសញ្ជាតិរបស់ប្រជាជនគ្មានតួនាទីទេនៅក្នុងការបញ្ជារបស់ចក្រពត្តិអាមេរិក។ ការពិតសញ្ជាតិប្រជាជនអាមេរិក គឺទុកឱ្យមនុស្សភាគតិចបំផុតនៃពិភពលោក វាគឺជាការចូលទៅរស់នៅក្នុងប្រទេសមួយ ដែលត្រួតត្រាយ៉ាងតឹងរឹងចំពោះមនុស្សគ្រប់រូប ។ អត្រាប្រជាជនបន្ទាប់បន្សំ (អ្នកដែលចូលទៅរស់នៅអាមេរិក) មិនត្រូវ បានរាប់បញ្ចូលទេ ប៉ុន្តែប្រជាជនទាំងនេះទទួលការឆែកឆេរជាញឹកញាប់ដោយការប្រើកំលាំងទ័ព រឺត្រូវគំរាមដោយ កំលាំងទ័ពពីសំណាក់រដ្ឋាភិបាល រឺត្រួតត្រាដោយប្រព័ន្ធច្បាប់ទំលាប់ពិភពលោក រឺច្បាប់តំបន់ និងស្ថាប័នផ្សេងៗ ដូចជា អង្គការពាណិជ្ជកម្មពិភពលោក ប្រព័ន្ធ Bretton Woods (ដែលមានធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុ) អង្គការ ណាតូ ដែលត្រូវបានប្រើប្រាស់យ៉ាងចំហរដើម្បីបំរើផលប្រយោជន៍នៃមណ្ឌលចក្រពត្តិនេះ។

ទោះបីជាការពង្រីកសញ្ជាតិ ប្រជាជនសកលលោកមិនមែនជាឧបករណ៍ ដែលត្រូវប្រើនៅក្នុងការពង្រីកចក្រពត្តិរបស់ អាមេរិកក៏ដោយ ក៏ក្នុងកំឡុងពេលតស៊ូរបស់ខ្លួនជាមួយពួកកុម្មុយនីស្តនិយមក្រោយសង្គ្រាមលោកលើកទី២ ទីក្រុង

វ៉ាស៊ីងតោនបានលើកឡើងនូវរូបមន្តនយោបាយមួយ ដើម្បីឱ្យការក្តោបក្តាប់ពិភពលោករបស់អាមេរិកអោយក្លាយជារឿង ស្របច្បាប់ ។ ធាតុផ្សំពីរយ៉ាងនៃរូបមន្តនេះ គឺពហុភាគីនិយមដែលដើរតួនាទីជាប្រព័ន្ធគ្រប់គ្រងពិភពលោក និងប្រជា- ធិបតេយ្យសេរី ។

ដូចដែលលោក Frances Fitzgerald បានសង្កេតនៅក្នុងសៀវភៅ “Fire in the Lake” ការសន្យានៃការពង្រីកលទ្ធិប្រជាធិបតេយ្យសេរី គឺជាឧត្តមគតិដ៏មានឥទ្ធិពលដែលបានបំពេញបន្ថែមដល់កងទ័ពអាមេរិកនៅក្នុងសង្គ្រាមត្រជាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះលទ្ធិប្រជាធិបតេយ្យសេរីប្រភេទវ៉ាស៊ីងតោន រឺប្រភេទលោកខាងលិចគឺកំពុងតែមានបញ្ហានៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលលទ្ធិនេះបានកាត់បន្ថយមកត្រឹមតែសំបកខាងក្រៅនៃរបបគ្រប់គ្រងផ្តាច់ការ ដូចជាក្នុងប្រទេសហ្វីលីពីន ប្រទេសប៉ាគីស្ថានមុនរបបលោក Musharra និងទូទាំងទ្វីបអាមេរិកឡាទីន ។ ការពិត លទ្ធិប្រជាធិបតេយ្យសេរីនៅអាមេរិកបានប្រែទៅជាមិនសូវប្រជាធិបតេយ្យ និងមិនសូវសេរី ។ ប្រាកដណាស់ថាប្រទេស មួយចំនួននៅក្នុងលោកកំពុងអភិវឌ្ឍន៍ មើលឃើញប្រជាធិបតេយ្យសេរីជាប្រព័ន្ធមួយដែលដំណើរការ និងពុករលួយ ក្រោមទំរង់នៃទឹកប្រាក់របស់សាជីវកម្ម ។

ប្រជាជនរបស់លោកប៊ូស មិនចាប់អារម្មណ៍នឹងការបង្កើតនូវសន្តិភាពសំរាប់ជនរ៉ូមាំងថ្មីឡើយ ។ អ្វីដែលគេចង់បាននោះគឺ សន្តិភាពអាមេរិក ដែលភាគច្រើននៃប្រជាជននៅក្រោមបង្គាប់ ដូចជាជនជាតិអារ៉ាប់ត្រូវស្ថិតក្រោមការត្រួតត្រាដោយ អំណាច និងកំលាំងទព័របស់អាមេរិក នៅខណៈពេលដែលក្រុមផ្សេងទៀតដូចជា រដ្ឋាភិបាលហ្វីលីពីនត្រូវបានទិញក្បាល ដោយទឹកប្រាក់ ។ ជាមួយនឹងគោលដៅគ្មានសីលធម៌ ដែលចងភ្ជាប់មនុស្សភាគច្រើននៃពិភពលោកទៅនឹងមណ្ឌលចក្រពត្តិ វិធីនៃការគ្រប់គ្រងរបស់ចក្រពត្តិនេះអាចញ៉ាំងឱ្យរឿងតែមួយគត់កើតឡើងគឺ ក្រុមអ្នកតស៊ូ ។

បញ្ហាដ៏ធំរបស់ឯកតោភាគីនិយម គឺភាពហួសពីសមត្ថភាព រឺក៏ការផ្ទុះផ្គងខុសរវាងគោលដៅរបស់សហរដ្ឋអាមេរិក និងធន ធានដែលត្រូវការប្រើដើម្បីសំរេចគោលដៅទាំងនេះ ។ ភាពហួសពីសមត្ថភាព គឺមានទំនាក់ទំនងគ្នាបានសេចក្តីថា នៅក្នុង កំរិតដ៏ខ្លាំងក្លាមួយ វានឹងក្លាយជាមុខងារមួយនៃក្រុមអ្នកតស៊ូ ។ ការពិត អំណាចដែលហួសពីសមត្ថភាពអាចក្លាយជា លក្ខខណ្ឌដ៏អាក្រក់ ទោះបីជាអំណាចយោធារបស់អាមេរិកកើនឡើងយ៉ាងជាក់លាក់ក៏ដោយ នៅពេលដែលក្រុមតស៊ូប្រឆាំងនឹងអំណាចនេះមានការកើនឡើងក្នុងកំរិតមួយដ៏សម្បើម ។ ក្នុងចំណោមសន្ទស្សន៍សំខាន់៧នៃភាពហួសពីសមត្ថភាព ដែលគួរកត់សំគាល់មានដូចខាងក្រោម :

- ការអុចអាលនូវទស្សនៈរបស់ជនជាតិអារ៉ាប់ និងឥស្លាមនៅមជ្ឈឹមបូព៌ា អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍នាំឱ្យ មានគុណប្រយោជន៍យ៉ាងច្រើនចំពោះជនឥស្លាមនិយម ដែលនោះគឺជាអ្វីដែលអូសាម៉ាប៊ីនឡាឌេនបានសង្ឃឹម ទុកតាំងពីដំបូង ។
- ការបរាជ័យនៃបណ្តាញអាត្លង់ទិកក្នុងសង្គ្រាមត្រជាក់ និងការលេចឡើងនៃបណ្តាញក្រុមអ្នកប្រឆាំងថ្មីមួយ ដោយមានប្រទេសអាឡឺម៉ង់ និងបារាំងជាអ្នកដើរតួយ៉ាងសំខាន់ ។
- ដំណើរការទៅមុខបន្តិចម្តងនៃអំណាចរបស់ចលនាសង្គមស៊ីវិលពិភពលោក ប្រឆាំងនឹងឯកតោភាគីនិយម យោធានិយមនឹងអនុវត្តន៍សេដ្ឋសាស្ត្ររបស់អាមេរិកនៅក្នុងការបង្ហាញយ៉ាងសំខាន់បំផុតនាពេលថ្មីៗនេះ គឺចលនាតស៊ូប្រឆាំងនឹងសង្គ្រាមក្នុងពិភពលោក ។
- ការចូលកាន់អំណាចនៃចលនាប្រឆាំងនឹងពួកសេរីបែបថ្មី ចលនាប្រឆាំងនឹងអាមេរិកនៅក្បែរនឹងទីក្រុងវ៉ាស៊ីនតោនផ្ទាល់ ដូចជាប្រទេសប្រេស៊ីល វេណេហ្ស៊ុយអេឡា នឹងអេក្វាឌ័រ នៅពេលរដ្ឋបាលលោកប៊ូសជាប់ដៃ រវល់ជាមួយនឹងមជ្ឈិមបូព៌ាប្រទេស ។
- ការកើនឡើងនូវផលប៉ះពាល់អវិជ្ជមាននៃរបបយោធានិយមលើសេដ្ឋកិច្ចអាមេរិក ដោយសារចំណាយលើផ្នែកយោធាត្រូវពឹងផ្អែកលើឱនភាព (ចំណាយលើសចំណូល) នៃចំណាយ ហើយឱនភាពនៃការចំណាយកាន់ តែពឹងផ្អែកខ្លាំងឡើងលើការផ្តល់ហិរញ្ញវត្ថុពីបរទេស ដែលបង្កើតឱ្យមានភាពតានតឹង និងការលំបាក ខ្លាំងឡើងៗ ជាមួយសេដ្ឋកិច្ចមួយដែលកំពុងតែប្រឈមមុខជាមួយនឹងការជាប់គាំង ។

សរុបសេចក្តីមក គំរោងអ្នកសកលភាវូបនីយកម្មកំពុងស្ថិតក្នុងវិបត្តិ ។ ថាតើ គំរោងនេះអាចវិលទៅរកសភាពដើម ដោយសារប្រធានាធិបតីប្រជាធិបតេយ្យ វីសាធារណរដ្ឋសេរីមិនគួរត្រូវបានបដិសេធទេ ជាពិសេសដោយសារតែមានសំលេងអ្នកសកលភាវូបនីយកម្មដ៏មានឥទ្ធិពលនៅក្នុងសហគមពាណិជ្ជកម្មអាមេរិក-ក្នុងចំណោមនោះលោក George Soros ដែលកំពុងតែស្រែកប្រឆាំងនឹងការដាក់ចេញនូវឯកតោភាគីនិយមរបស់រដ្ឋបាលលោកប៊ូស ។ ទោះយ៉ាងណាក៏ដោយឯកតោភាគី និយមនេះមិនទំនងជានឹងកើតមានឡើង នឹងចូលមកគ្រប់គ្រងពិភពលោកនាពេលខាងមុខនេះទេ ។

និយាយឱ្យខ្លី យើងបានឈានចូលក្នុងប្រវត្តិសាស្ត្រដែលប្រកបដោយការភាន់ច្រឡំ ដែលកំនត់ដោយវិបត្តិសេដ្ឋកិច្ចដែលអូសបន្លាយការសាយភាយនៃក្រុមអ្នកតស៊ូជាសកល ការកើតមានឡើងវិញនូវតុល្យភាពនៃអំណាចក្នុងចំនោមប្រទេសសំខាន់ៗ និងការផុសឡើងវិញនៃភាពផ្ទុយគ្នាយ៉ាងខ្លាំងនៃអន្ត-ចក្រពត្តិ ។

យើងត្រូវតែមានការគោរពមួយសំរាប់អំណាច របស់សហរដ្ឋអាមេរិក ប៉ុន្តែយើងមិនត្រូវវាយតំលៃអំណាចនេះខ្ពស់ហួសពេកទេ ។ មានសញ្ញាដែលបង្ហាញឱ្យយើងឃើញ ថាសហរដ្ឋអាមេរិកបានធ្វើអ្វីៗជាច្រើនដែលហួសពីសមត្ថភាពរបស់ប្រទេសនេះយ៉ាងខ្លាំង ហើយជាអ្វីដែលបានបង្ហាញថាជាកំលាំងដ៏រឹងមាំ ការពិតអាចជាភាពទន់ខ្សោយ បើសិនជាយើងគិតតាមរបៀបយុទ្ធសាស្រ្តវិញនោះ ។

ដកស្រង់ចេញមកពីសៀវភៅ Silence War The US’ economic and ideological occupation of Iraq ការបោះពុម្ពផ្សាយរបស់អង្គការ Focus on The Global South ខែមករា ២០០៥

# ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់

# តើសហរដ្ឋអាមេរិកប្រើសកលភាវូបនីយកម្ម

# បែបណាដើម្បីបោកប្រាស់

# ប្រាក់រាប់ពាន់កោដលានដុល្លារពីប្រទេសក្រីក្រ

# ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់ តើសហរដ្ឋអាមេរិក ប្រើសកលភាវូបនីយកម្មបែបណាដើម្បីបោកប្រាស់ ប្រាក់រាប់ពាន់កោដលាន ដុល្លា ពីប្រទេសក្រីក្រ?

ថ្ងៃសុក្រ ទី៣១ ខែធ្នូ ឆ្នាំ ២០០៤
http://www.democracynow.org/article.pl?sid=04/12/31/1546207

យើងចំណាយពេលមួយម៉ោងជាមួយលោក John Perkins អតីតជាសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងសហគមន៍ធនាគារអន្តរជាតិ ។ ក្នុងសៀវភៅរបស់គាត់និយាយពី ***ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់*** គាត់បានបង្ហាញថា ក្នុងនាមជាអ្នកឯកទេសដែលបានទទួលប្រាក់បៀវត្សន៍ខ្ពស់ គាត់បានជួយឱ្យសហរដ្ឋអាមេរិក បោកប្រាស់ប្រទេសក្រីក្រនៅជុំវិញពិភពលោក ដោយយកប្រាក់រាប់ពាន់កោដលានដុល្លារ ឱ្យប្រទេសទាំងនោះខ្ចីយ៉ាងច្រើន ដែលធ្វើឱ្យពួកគេមិនអាចសងវិញបាន បន្ទាប់មកក៏គ្រប់គ្រងលើសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះតែម្តង ។

John Perkins ពណ៌នាខ្លួនគាត់ថា គាត់ជាអតីតសេដ្ឋវិទូម្នាក់ ជាអ្នកឯកទេសដែលទទួលបានបៀវត្តន៍ដ៏ខ្ពស់ ហើយបានបោកប្រាស់ប្រទេសនានានៅលើពិភពលោក ដើម្បីយកលុយរាប់ពាន់លានដុល្លា ។

កាលពី ២០ឆ្នាំមុន Perkins បានចាប់ផ្តើមសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា **មនសិការរបស់អ្នកវាយលុកសេដ្ឋកិច្ច** ។

លោក Perkins សរសេរថា "សៀវភៅនេះគឺសរសេរឡើងដើម្បីជូនដល់ប្រធានាធិបតីនៃប្រទេសពីរ បុរសដែលធ្លាប់ជាភ្ញៀវ ហើយខ្ញុំបានគោរពនិងគិតអំពីចិត្តល្អរបស់ពួកគេ គឺលោក Jaime Roldós ប្រធានាធិបតីប្រទេសអេក្វាឌ័រ និងលោក Omar Torrijos ប្រធានាធិបតីប្រទេសប៉ាណាម៉ា ។ បុរសទាំងពីរទើបតែទទួលមរណៈភាពនៅក្នុងការធ្លាក់យន្តហោះដ៏សាហាវមួយ ។ ការស្លាប់របស់ពួកគេមិនមែនជាគ្រោះថ្នាក់ដោយចៃដន្យទេ ។ ពួកគេទាំងពីរគឺត្រូវបានធ្វើឃាតដោយសារតែពួកគេបានប្រឆាំងនឹងផលប្រយោជន៍របស់សារជីវកម្មរដ្ឋាភិបាល និងប្រធានធនាគារដែលមានគោលបំណងចង់ក្លាយជាចក្រពត្តិនៅលើពិភពលោក ។ យើងជាអ្នកវាយលុកសេដ្ឋកិច្ចបានបរាជ័យក្នុងការធ្វើឱ្យ Roldos និង

Torrijos មកចូលក្រុមជាមួយយើង ហើយពួកអ្នកវាយលុកមួយប្រភេទទៀតគឺ ក្រុម ស៊ី-អាយ-អេ (CIA-sanctioned jackals) ដែលពួកគេតែងតែនៅពីក្រោយខ្នងពួកយើង ហើយពួកគេក៏បានលូកដៃចូល ។

John Perkins សរសេរសៀវភៅនេះបន្តទៀត "ខ្ញុំត្រូវបានបញ្ចុះបញ្ចូលឱ្យឈប់សរសេរសៀវភៅនេះ ។ ខ្ញុំបានចាប់ផ្តើមសរសេរបួនដងទៀតក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ ។ ក្នុងមួយលើកៗ ការសំរេចចិត្តចាប់ផ្តើមសរសេររបស់ខ្ញុំ ត្រូវរងនូវឥទ្ធិពលពីព្រឹត្តិការណ៍នានាលើពិភពលោកៈ ការឈ្លានពានរបស់សហរដ្ឋអាមេរិកលើប្រទេសប៉ាណាម៉ានៅឆ្នាំ ១៩៨០ សង្គ្រាមឈូងសមុទ្រលើកទីមួយ សង្គ្រាមនៅប្រទេសសូម៉ាលី និងការរីកដុះដាលរបស់ក្រុម អូសាម៉ា-ប៊ីនឡាដេន ។ ទោះជាយ៉ាងណាក៏ដោយ ការគំរាមគំហែងនិងការសូកប៉ាន់ តែងតែធ្វើឱ្យខ្ញុំជឿនិងបញ្ឈប់ការសរសេរ ។"

ប៉ុន្តែនៅទីបំផុត John Perkins ក៏បានបោះពុម្ពផ្សាយរឿងរ៉ាវរបស់គាត់ ។ សៀវភៅនេះមានចំណងជើងថា *ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* ។ John Perkins ចូលរួមជាមួយយើងម្តងទៀត នៅស្ថានីយ៍ Firehouse របស់យើងដើម្បីធ្វើការជជែករយៈពេលវែង ។

- ពីឆ្នាំ ១៩៧១ ដល់ ១៩៨១ John Perkins បានធ្វើការឱ្យក្រុមហ៊ុនផ្តល់ប្រឹក្សាអន្តរជាតិ Chas T. Main ដែលគាត់បានពណ៌នាខ្លួនឯងថាជា "អ្នកវាយលុកសេដ្ឋកិច្ច " ។ គាត់គឺជាអ្នកនិពន្ធសៀវភៅថ្មីមួយឈ្មោះថា ***ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់*** (Confessions of an Economic Hit Man) ។

*អត្ថបទនេះ គឺគេអាចរកបានដោយមិនបាច់ចំណាយប្រាក់ឡើយ ទោះជាយ៉ាងណាក៏ដោយ កាធ្វើវិភាគទានបានជួយពួកយើងក្នុងការសរសេរនូវចំណងជើងនៅក្នុងការផ្សាយតាមទូទស្សន៍របស់យើង សំរាប់មនុស្សថ្លង់និងមនុស្សដែលពិបាកក្នុងការស្តាប់ ។ សូមថ្លែងអំណរគុណសំរាប់ការវិភាគទានដ៏សប្បុរសរបស់លោកអ្នក ។*

AMY GOODMAN : លោក John Perkins ចូលរួមជាមួយពួកយើងនៅក្នុងស្ថានីយ៍ Firehouse រយៈពេលមួយម៉ោង ។ សូមស្វាគមន៍មកកាន់កម្មវិធីលទ្ធិប្រជាធិបតេយ្យក្នុងពេលបច្ចុប្បន្ន (Democracy Now) ។

JOHN PERKINS: អរគុណ Amy ។ វាអស្ចារ្យណាស់ដែលខ្ញុំបានមកទីនេះ ។

AMY GOODMAN : រឿងដែលអ្នកបានប្រាប់ដល់ពួកយើង គឺជារឿងមួយដ៏អស្ចារ្យ ។ សូមស្វាគមន៍មកកាន់វិទ្យុនិងទូទស្សន៍ដែលគ្មានការថតកម្មវិធីទុកដើម្បីធ្វើការចាក់ផ្សាយ ។ ពួកយើងមិនត្រឹមតែផ្តល់ដល់លោកអ្នកនូវផ្នែកដ៏

សំខាន់នៃឯកសារនោះប៉ុណ្ណោះទេ គឺយើងនឹងផ្តល់នូវរឿងរ៉ាវទាំងមូលសំរាប់លោកអ្នក ។ ដូចនេះ ពួកយើងនឹងចំណាយពេលមួយម៉ោងនិយាយអំពីជីវិតលោក ។

JOHN PERKINS: នេះគឺជាឱកាសដ៏វិសេសវិសាល !

AMY GOODMAN: --ប៉ះពាល់មនុស្សរាប់លាននៅលើពិភពលោក។ ប្រពន្ធ័ដែលលោកបានចូលរួម និងសៀវភៅ *ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ច* គឺជាភាពដ៏អស្ចារ្យមួយ ដែលផ្តល់ដល់ពួកយើងនូវការរៀបរាប់យ៉ាងក្បោះក្បាយពីអ្វីដែលលោកបានធ្វើ ។ ដូច្នេះ ហេតុអ្វីបានជាលោកមិនចាប់ផ្តើមពីដំបូង ។ ប្រហែលជាមិនមែនតាំងពីកន្លែងដែលលោកកើតនោះទេ ប៉ុន្តែតើលោកត្រូវបានគេជ្រើសរើសដំបូងដោយភ្នាក់ងារសន្តិសុខជាតិ (National Security Agency) ដែលធំជាងភ្នាក់ងារ ស៊ី-អាយ-អេ និងបន្ទាប់មក គឺជ្រើសរើសដោយក្រុមហ៊ុនផ្តល់ប្រឹក្សាអន្តរជាតិ Chas T. Main ដោយរបៀបណា ។

JOHN PERKINS : បាទ វាបានកើតឡើងនៅចុងទសវត្សឆ្នាំ ១៩៦០ គឺនៅឆ្នាំ ១៩៦៨ ។ ខ្ញុំគឺជានិស្សិតនៅសាលាពាណិជ្ជកម្មមួយ ហើយខ្ញុំត្រូវបានជ្រើសរើសដោយភ្នាក់ងារសន្តិសុខជាតិ ។ ពួកគេបានធ្វើការសាកល្បងខ្ញុំដោយឆ្លងកាត់ដំណាក់កាលជាច្រើន រួមមានការធ្វើតេស្តលើបុគ្គលិកលក្ខណៈ និងការធ្វើតេស្តលើភាពប៉ិនប្រសព្វកុហកដើម្បីស៊ើប-ការណ៍ គឺជាការសាកល្បងគ្រប់ជ្រុងជ្រោយបំផុត ។ ហើយនៅក្នុងដំណើរការនេះ ពួកគេបានរកឃើញថា ខ្ញុំគឺជាបុគ្គលដែលសាកសមបំផុតដើម្បីធ្វើជាអ្នកវាយលុកសេដ្ឋកិច្ចម្នាក់ ។ ខ្ញុំនៅរៀននៅឯសាលាពាណិជ្ជកម្មនៅឡើយនាពេលនោះ ពួកគេក៏បានរកឃើញចំណុចខ្សោយមួយចំនួនពីអត្តចរិតរបស់ខ្ញុំ ។ ខ្ញុំគិតថា ខ្ញុំមានចំណុចខ្សោយដែលជារឿងធម្មតានៅក្នុងវប្បធម៌របស់យើង គឺជាថ្នាំដ៏ខ្លាំងក្លាទាំងបីនៅក្នុងវប្បធម៌យើង : លុយ អំណាច និងសិច ។ ពួកគេបានរកឃើញចំណុចខ្សោយទាំងបីនេះរបស់ខ្ញុំ ។ នៅក្នុងសៀវភៅរបស់ខ្ញុំ មានសរសេរច្រើនណាស់អំពីជីវប្រវត្តិរបស់ខ្ញុំដែលនាំទៅរកវត្ថុទាំងបីនោះ ។ ក្រោយមកពួកគេបានជំរុញខ្ញុំឱ្យទៅធ្វើការនៅ Peace Corps[1] ។ ខ្ញុំបានទៅរស់នៅប្រទេសអេក្វាឌ័ររយៈពេលបីឆ្នាំក្នុងនាមជាអ្នកស្ម័គ្រចិត្តឱ្យ Peace Corps ជាមួយនិងជនជាតិភាគតិចនៅទីនោះ ដែលបច្ចុប្បន្ននេះពួកគេកំពុងធ្វើសង្គ្រាមជាមួយក្រុមហ៊ុនប្រេងមួយចំនួន ។ បន្ទាប់មក ពួកយើងបានចាប់ផ្តើមដំណើរការ ហើយខ្ញុំទទួលបានជោគជ័យនៅពេលហ្វឹកហាត់ការងារនេះ ។ នៅខណៈដែលខ្ញុំរស់នៅប្រទេសអេក្វាឌ័រ ធ្វើការឱ្យ Peace Corps អគ្គនាយករងក្រុមហ៊ុនផ្តល់ប្រឹក្សាឯកជនមួយនៅបូស្តុន ដែលធ្វើការយ៉ាងជិតស្និតជាមួយភ្នាក់ងារសន្តិសុខជាតិ និងសហគមន៍អ្នកវៃឆ្លាតដទៃទៀត បានមកប្រទេសអេក្វាឌ័រហើយបានបន្តដំណើរការជ្រើសរើសខ្ញុំ ។ ពេលដែលខ្ញុំចាកចេញពី Peace Corps គាត់បានជ្រើសរើសខ្ញុំឱ្យធ្វើការ ។ ខ្ញុំបានទៅធ្វើការឱ្យក្រុមហ៊ុនរបស់គាត់នៅបូស្តុន គឺក្រុមហ៊ុន

[1] Peace Corps explain

Chas T. Main ហើយខ្ញុំបានឆ្លងកាត់វគ្គបណ្តុះបណ្តាលតឹងរឹងជាច្រើន ដែលក្នុងពេលនោះខ្ញុំបានជួបជាមួយស្ត្រីដ៏អស្ចារ្យម្នាក់ដែលបានពណ៌នាយ៉ាងក្បោះក្បាយនៅក្នុងសៀវភៅរបស់ខ្ញុំ ។ នាងឈ្មោះ Claudine ។ នាងគឺជាមនុស្សដ៏ប៉ិនប្រសប់ មោះមុត និងទាក់ទាញចិត្តបំផុត ហើយនាងបានទាក់ខ្ញុំជាប់ ។ នាងដឹងយ៉ាងប្រាកដ ថាត្រូវទាក់ខ្ញុំដោយវិធីណា ។ នាងទទួលបានផលប្រយោជន៍ជាច្រើនអំពីការសាកល្បងទាំងឡាយដែលខ្ញុំបានឆ្លងកាត់ ហើយនាងដឹងពីចំណុចខ្សោយទាំងឡាយរបស់ខ្ញុំ ។ នាងបានចាប់យកចំណុចខ្សោយទាំងនោះ នាងគឺជាមនុស្សដំបូងបង្អស់ដែលបានទាក់ទាញខ្ញុំឱ្យក្លាយទៅជាអ្នកវាយលុកសេដ្ឋកិច្ច ហើយក្នុងពេលជាមួយគ្នានោះដែរ នាងបានព្រមានខ្ញុំថា នេះគឺជាការធ្វើជំនួញដ៏ក្រខ្វក់មួយ ហើយអ្នកឯងត្រូវតែមានការប្តេជ្ញាចិត្តពេញទំហឹងលើការងារនោះ បើមិនដូចនោះទេ អ្នកឯងមិនគួរទទួលយកការងារដំបូងរបស់អ្នកដែលត្រូវធ្វើនៅប្រទេសឥណ្ឌូនេស៊ីទេ ។

AMY GOODMAN: ឥឡូវនេះ មនុស្សជាច្រើនឆ្ងល់ថា តើអ្នកវាយលុកសេដ្ឋកិច្ចរូបនេះកំពុងតែនិយាយអំពីអ្វី? សូមលោកធ្វើការបកស្រាយ ។

JOHN PERKINS: ការពិត កាលពី ៣០-៤០ឆ្នាំ កន្លងទៅនេះ ពួកយើងដែលជាអ្នកវាយលុកសេដ្ឋកិច្ចបានបង្កើតនូវចក្រពត្តិសកលដ៏ធំជាងគេបង្អស់នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ ពួកយើងធ្វើដូច្នេះបានដោយល្អ មានវិធីសាស្ត្រជាច្រើនដើម្បីធ្វើការងារចក្រពត្តិទាំងនេះ ប៉ុន្តែជាទូទៅគឺយើងកំណត់នូវប្រទេសក្រីក្រណាមួយដែលមានធនធាន ដែលពួកយើងចង់បាន ។ ជារឿយៗ នៅសម័យនេះគឺធនធានប្រេង ឬក៏ការជីកប្រឡាយក្នុងករណីប្រទេសប៉ាណាម៉ា ។ ទោះក្នុងករណីណាក៏ដោយ ពួកយើងធ្វើដំណើរទៅប្រទេសនោះ ហើយរៀបចំផ្តល់ប្រាក់កម្ចីដ៏ច្រើនឱ្យប្រទេសនេះតាមរយៈសហគមន៍ផ្តល់ប្រាក់កម្ចីអន្តរជាតិ ដែលជាធម្មតាគឺធនាគារពិភពលោកជាអ្នកដឹកនាំដំណើរការនេះ ។ អញ្ចឹងបើយើងនិយាយថា យើងផ្តល់ប្រាក់កម្ចីមួយពាន់លានដុល្លាដល់ប្រទេសក្រីក្រមួយនេះ ល័ក្ខខណ្ឌមួយក្នុងចំណោមល័ក្ខខណ្ឌនានានៃប្រាក់កម្ចីនោះគឺថា ប្រមាណ ៩០% នៃការប្រាក់នោះ ត្រូវតែត្រឡប់ទៅកាន់សហរដ្ឋអាមេរិកវិញ ទៅតាមរយៈសាជីវកម្មធំណាមួយរបស់យើង ហើយករណីដែលយើងបានឮថ្មីៗនេះគឺក្រុមហ៊ុន Bechtels ក្រុមហ៊ុន Halliburtons ។ សាជីវកម្មធំៗទាំងនោះនឹងបញ្ចូលនៅក្នុងប្រទេសក្រីក្រនោះ រោងចក្រធំៗ មហាវិថីធំៗ កំពង់ផែ ឬក៏សួនឧស្សាហកម្ម (ទីប្រជុំតំបន់ឧស្សាហកម្ម) គំរោងធំៗលើហេដ្ឋារចនាសម្ព័ន្ធនានា ដែលជាមូលដ្ឋាន គឺបំរើផលប្រយោជន៍ដល់អ្នកមាននៅក្នុងប្រទេសនោះ ។ ប្រជាជនក្រីក្រ និងវណ្ណៈមធ្យមនៅក្នុងប្រទេសនេះត្រូវរងទុក្ខវេទនា ពួកគេមិនបានទទួលផលប្រយោជន៍ពីប្រាក់កម្ចីទាំងនេះទេ ពួកគេមិនបានទទួលផលប្រយោជន៍ពីគំរោងទាំងនេះឡើយ ។ ការពិត សេវាកម្មជាមូលដ្ឋាននៅក្នុងសង្គមត្រូវបានកាត់បន្ថយនៅក្នុងដំណើរការសងបំណុល ។ ឥឡូវនេះ អ្វីដែលកើតឡើង គឺប្រទេសក្រីក្រជំពាក់បំណុលដែលពួកគេគ្មានលទ្ធភាពសងវិញបាន ។ ឧទាហរណ៍ ប្រទេសអេក្វាឌ័រនាពេលបច្ចុប្បន្ន ។ ជាលទ្ធផល

របស់ក្រុមអ្នកវាយលុកសេដ្ឋកិច្ច ប្រទេសអេក្វាឌ័រមានបំណុលដែលស្មើនឹង ៥០% នៃថវិកាជាតិទាំងមូល ។ ប្រទេសនេះគ្មានលទ្ធភាពណាមួយដែលអាចសងបំណុលរួចទេ ដែលវាដូចទឹងករណីរបស់ប្រទេសក្រីក្រដទៃទៀត ។ ដូច្នេះឥឡូវនេះពួកយើង (អ្នកវាយលុកសេដ្ឋកិច្ច) ត្រឡប់ទៅប្រទេសទាំងនោះវិញ ហើយនិយាយថា មើលចុះប្រទេសអ្នកបានខ្ចីប្រាក់ពីពួកយើង ហើយអ្នកជំពាក់ពួកយើង មិនអាចសងបំណុលពួកយើងរួចឡើយ ដូច្នេះត្រូវលក់ប្រេងរបស់អ្នកឱ្យក្រុមហ៊ុនពួកយើងក្នុងតំលៃមួយថោកជាទីបំផុត ។ ក្នុងករណីប្រទេសជាច្រើន ដូចជាប្រទេសអេក្វាឌ័រដែលជាឧទាហរណ៍ដ៏ល្អ សំណើរដែលលើកឡើងនេះមានន័យថា ពួកគេត្រូវបំផ្លាញព្រៃឈើសំរាប់ទប់ទឹកភ្លៀងរបស់ពួកគេ និងបំផ្លាញវប្បធម៌ជនជាតិភាគតិចរបស់ពួកគេ ។ ទាំងនេះគឺជាអ្វីដែលពួកយើងកំពុងតែធ្វើនៅជុំវិញពិភពលោកនាពេលបច្ចុប្បន្ន ហើយពួកយើងនៅតែបន្តធ្វើទៀត គឺវាបានចាប់ផ្តើមក្នុងរយៈយ៉ាងខ្លីបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ។ យុទ្ធសាស្ត្រត្រូវបានបង្កើតឡើង ហើយរីកលូតលាស់តាមកាលវេលារហូតមកដល់សព្វថ្ងៃនេះគឺវាបានឈានដល់ទំហំយ៉ាងធំក្រៃលែង ហើយមានកន្លែងជាច្រើននៅលើពិភពលោកដែលពួកយើងធ្វើការគ្រប់គ្រងលើធនធាននានា ។

AMY GOODMAN: លោក John Perkins និយាយអំពីបទពិសោធន៍របស់លោកនៅប្រទេសប៉ាណាម៉ា ។ លោកមានឱកាសបានជួបជាមួយមេដឹកនាំប្រទេសប៉ាណាម៉ាមុនពេលគាត់ត្រូវបានគេសម្លាប់ គឺលោក Omar Torrijos ។ តើលោកបានជួបគាត់ដោយវិធីណា ហើយវាយ៉ាងម៉េចដែរ?

JOHN PERKINS: ប្រទេសប៉ាណាម៉ា គឺជាប្រទេសមួយយ៉ាងសំខាន់ក្រៃលែងក្នុងចំណោមប្រទេសក្រីក្រជាច្រើនដែរ ហើយលោក Omar Torrijos គឺជាប្រធានាធិបតីនៅពេលនោះ ។ លោកដឹកនាំប្រទេសដោយដើរតាមរបបគ្រប់គ្រងមួយដែលមានអ្នកផ្តាច់ការមួយក្រុមតូចដឹកនាំ ដែលជារបបអាយ៉ងរបសសហរដ្ឋអាមេរិកដែលគេបានរៀបចំ បែបនេះតាំងពី ៥០ឆ្នាំ មុន យើងនឹងកាន់កាប់ប្រទេសនេះ ។ លោក Omar Torrijos គឺជាមនុស្សដំបូងបង្អស់ដែលបានបំបែកវដ្តនៃការកាន់កាប់របស់អាមេរិកនេះ ហើយលោកគឺជាប្រធានាធិបតីដែលមានប្រជាប្រិយភាពបំផុត ។ គាត់មានភាពល្បីល្បាញនៅតាមបណ្តាប្រទេសជាច្រើនលើពិភពលោក ។ មានមនុស្សជាច្រើនជឿជាក់ថា គាត់គួរតែបានទទួលពានរង្វាន់ណូបែលសន្តិភាព គាត់ប្រហែលជានឹងមិនស្លាប់ ឬត្រូវគេសម្លាប់នោះទេ ។ គាត់បានការពារមនុស្សដែលត្រូវគេគាបសង្កត់នៅគ្រប់កន្លែងលើពិភពលោក ។ សហរដ្ឋអាមេរិកក្នុងពេលនោះ គឺជំនាន់រដ្ឋបាល លោក Carter ប្រធានាធិបតីរូបនេះកំពុងចរចារលើសន្ធិសញ្ញាធ្វើព្រែកជីកថ្មីជាមួយលោក Torrijos ហើយនៅទីបំផុត សន្ធិសញ្ញានោះក៏ធ្វើទៅបាន ។ ក៏ប៉ុន្តែសន្ធិសញ្ញានេះបណ្តាលឱ្យមានការជ្រួលច្របល់យ៉ាងខ្លាំងក្លានៅក្នុងប្រទេសពួកយើង (អាមេរិក) ។ ការពិតសន្ធិសញ្ញានេះត្រូវបានឆ្លងកាត់សភាដោយមានការបោះឆ្នោត ហើយមានសម្លេងឆ្នោតឈ្នះតែមួយប៉ុណ្ណោះ នៅពេលធ្វើសច្ចាបន័លើព្រែកជីកនេះ ។ ដូចនេះយើងដែលជាអ្នកវាយលុកសេដ្ឋកិច្ចបានរង់ចាំមើលពីក្រោយដំណើរការនេះ ឬ

ថា តើយើងត្រូវធ្វើយ៉ាងណាដើម្បីយកឈ្នះប្រទេសប៉ាណាម៉ាដោយមិនខ្វល់អំពីអ្វីដែលបានកើតឡើងចំពោះសន្ធិសញ្ញាព្រែកជីកនេះឡើយ ។ ខ្ញុំបានទៅប្រទេសនេះ មុនពេលសន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ ១៩៧២ ខ្ញុំបានព្យាយាមធ្វើឱ្យ Torrijos ចាប់អារម្មណ៍ គឺខ្ញុំបានព្យាយាមចាប់គាត់ឱ្យជាប់តាមវិធីដែលយើងតែងតែប្រើសំរាប់ទាក់ទាញអ្នកដទៃទៀត ។ លោកបានរៀបចំឱ្យខ្ញុំទៅជួបនៅបង់កាឡូឯកជនមួយ ហើយការជជែកគ្នានាពេលនោះ គឺមាននិយាយយ៉ាងក្បោះក្បាយនៅក្នុងសៀវភៅរបស់ខ្ញុំ ។ ប៉ុន្តែអ្វីដែលគាត់និយាយមកកាន់ខ្ញុំគឺថា មើលចុះខ្ញុំដឹងច្បាស់នូវល្បែងដែលអ្នកទាំងអស់គ្នាកំពុងលេងនេះ ហើយខ្ញុំដឹងថា អ្នកទាំងអស់គ្នាកំពុងតែព្យាយាមធ្វើអ្វីនៅទីនេះ ។ អ្នកកំពុងតែព្យាយាមដើម្បីឱ្យពួកយើងទទួលយកបំណុលដ៏សម្បើម ។ អ្នកកំពុងតែព្យាយាមធ្វើឱ្យពួកយើងពឹងផ្អែកទាំងស្រុងទៅលើអ្នក ហើយលោកព្យាយាមធ្វើឱ្យខ្ញុំក្លាយជាមនុស្សពុករលួយ ។ ខ្ញុំដឹងថា នេះជាល្បែងអ្វី ហើយខ្ញុំមិនលេងវាទេ ។ ខ្ញុំមិនត្រូវការលុយទាំងនេះទេ ខ្ញុំមិនយកទ្រព្យសម្បត្តិទាំងនេះធ្វើជារបស់ផ្ទាល់ខ្លួនរបស់ខ្ញុំពីការធ្វើបែបនេះទេ ។ ខ្ញុំចង់ជួយប្រជាជនក្រីក្ររបស់ខ្ញុំ ។ ខ្ញុំចង់ឱ្យពួកអ្នកជួយកសាងគំរោងនានាដែលអ្នកត្រូវសាងសង់ដូច ដែលអ្នកបានសាងសង់នៅក្នុងប្រទេសផ្សេងៗទៀត ប៉ុន្តែខ្ញុំចង់ឱ្យអ្នកបង្កើតវាសំរាប់ប្រជាជនក្រីក្ររបស់ពួកយើង មិនមែនសំរាប់ប្រជាជនមាននៅក្នុងប្រទេសនោះទេ ។ ហើយគាត់បានបន្តថា បើសិនជាលោកធ្វើមែន ខ្ញុំនឹងធ្វើឱ្យប្រាកដថា លោក និងក្រុមហ៊ុនរបស់លោកនឹងមានការងារធ្វើច្រើននៅក្នុងប្រទេសនេះ ។ ការងារល្អដែលអ្នកនឹងជួយដល់ប្រជាជនរបស់ពួកយើង ។ ខ្ញុំបានប្រឆាំងយ៉ាងខ្លាំងទៅនឹងចំណុចនេះ ក្នុងនាមខ្ញុំជាអ្នកវាយលុកសេដ្ឋកិច្ច ខ្ញុំត្រូវធ្វើយ៉ាងណាឱ្យគាត់នៅក្រោមការត្រួតត្រារបស់ពួកយើង ។ ខ្ញុំត្រូវតែទាក់ទាញគាត់ ។ ប៉ុន្តែ ក្នុងនាមជាដៃគូរក្រុមហ៊ុន និងជាសេដ្ឋវិទូយ៉ាងសំខាន់នៅក្រុមហ៊ុន ខ្ញុំចង់ឱ្យក្រុមហ៊ុនមានការងារធ្វើដែរ ហើយក្នុងករណីនេះវាជាក់ស្តែងខ្លាំងណាស់ ដែលថាអ្នកវាយលុកសេដ្ឋកិច្ចនឹងមិនបានអាចចូលទៅជិត Torrijos បានឡើយ ដូចនេះខ្ញុំយល់ព្រមតាមគាត់ ។ ក៏ប៉ុន្តែ ក្នុងពេលនោះខ្ញុំមានអារម្មណ៍ខ្វល់ខ្វាយខ្លាំងណាស់ដោយសារខ្ញុំបានដឹងថា ប្រពន្ធ័នេះគឺបង្កើតឡើងក្រោមការប៉ាន់ស្មាន ដែលថាអ្នកដឹកនាំជាច្រើនដូចជា Torrijos គឺអាចសូកប៉ាន់បាន ហើយមនុស្សប្រភេទនេះមាននៅស្ទើរគ្រប់ទីកន្លែងលើពិភពលោក ។ នៅពេលមានអ្នកដឹកនាំណាម្នាក់ក្រោកឈរឡើងប្រឆាំងនឹងប្រពន្ធ័នេះដូចជា Torrijos កំពុងតែធ្វើ វាមិនត្រឹមតែជាការគំរាមគំហែងដល់ប្រទេសប៉ាណាម៉ាប៉ុណ្ណោះទេ គឺថាយើងមិនអាចរកផ្លូវធ្វើអ្វីបានឡើយនៅទីនោះ ក៏ប៉ុន្តែវាអាចជាការបង្កើតឱ្យមានឧទាហរណ៍ដ៏អាក្រក់សំរាប់មនុស្សផ្សេងទៀតនៅក្នុងពិភពលោកមើលឃើញ ព្រោះនៅពេលដែលមានមេដឹកនាំណាមួយក្រោកឈរឡើងនោះ នឹងមានមេដឹកនាំម្នាក់ទៀតងើបឈរឡើងដែរ ដូចជា ប្រធានាធិបតីប្រទេសអេក្វាឌ័រនាពេលនោះ Jaime Roldos ។ ពួកគេទាំងពីរក្រោកឈរឡើងប្រឆាំងនឹងរដ្ឋាភិបាលអាមេរិក ។ ពួកគេទាំងពីរបានក្រោកឈរឡើងប្រឆាំងនឹងក្រុមហ៊ុនប្រេង និងអ្នកវាយលុកសេដ្ឋកិច្ច ហើយនោះគឺជាក្តីកង្វល់ដ៏ធំមួយសំរាប់ខ្ញុំ ។ ខ្ញុំដឹងនៅក្នុងចិត្តរបស់ខ្ញុំថា ប្រសិនបើរឿងនេះនៅតែបន្ត វានឹងមានរឿងអ្វីមួយកើតឡើង ។ វាជាការពិត

ណាស់ បុរសទាំងពីរនេះត្រូវបានគេធ្វើឃាដដោយក្រុមមនុស្សដែលយើងហៅថា jackals (ពួកឆ្កែព្រៃ) ក្រុមដាក់ទ័ណ្ឌកម្មដោយការពិឃាដ ស៊ី-អាយ-អេ ។

AMY GOODMAN: យើងកំពុងតែសន្ទនាជាមួយលោក John Perkins អ្នកនិពន្ធសៀវភៅ **ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ច** ។ ការសន្ទនាវាំងលោក ជាមួយលោក Omar Torrijos ដូចជាគាត់ឆ្លងកាត់ប្រវត្តិសាស្ត្រការសន្ទនារបស់លោក គឺនៅក្នុងទស្សវត្សឆ្នាំ ១៩៧០ ។ ប៉ុន្តែបើសិនជាយើងនិយាយពីអ្វីដែលកើតឡើងនៅក្នុងប្រទេសហ្គាតាម៉ាឡា ការទម្លាក់មេដឹកនាំដែលត្រូវបានបោះឆ្នោតជ្រើសរើសជាលក្ខណៈប្រជាធិបតេយ្យ គឺលោក Arbenz ដោយ ក្រុម United Fruit និងក្រុម ស៊ី-អាយ-អេ ដែលនៅពីក្រោយខ្នងរឿងនេះនៅឆ្នាំ ១៩៥៤ ហើយលោកបានស្ដាបនាការសន្ទនាអំពីក្រុមហ៊ុនប្រេង Zapata របស់លោក George Bush ដែលជាចៃដន្យគ្រប់គ្រងលើក្រុមហ៊ុន United Brands ដែលពីមុនគឺជាក្រុមហ៊ុន United Fruit ហើយបន្ទាប់មកគាត់និយាយអំពីការឱ្យក្រុមហ៊ុនរបស់លោកធ្វើអាជីវកម្ម លោក Omar Torrijos និយាយថា គាត់ជឿជាក់ថាជប៉ុននឹងផ្ដល់ប្រាក់ដើម្បីសាងសង់ព្រែកជីកនេះ ទោះបីជាត្រូវបញ្ជូនឱ្យក្រុមហ៊ុនលោកក៏ដោយ ។ លោក Omar Torrijos និយាយថា "ពួកគេផ្ដល់ថវិកាពួកគេនឹងធ្វើការសាងសង់" ហើយលោកសរសេរថា" វាបាញ់ឆ្ពោះមកលើខ្ញុំ ក្រុមហ៊ុន Bechtel នឹងត្រូវចាកចេញដោយការឈឺចាប់បំផុត ។ ការងារសាងសង់ដែលធំបំផុតនៅក្នុងប្រវត្តិសាស្ត្រនាពេលថ្មីៗនេះ ។ លោក Omar Torrijos បានឈប់មួយរយៈ ។ ប្រធានរបសក្រុមហ៊ុន Bechtel គឺលោក George Schultz, ដែលជារដ្ឋលេខាធិការរតនាគាររបស់រដ្ឋបាល លោក Nixon ។ លោកអាចស្រមៃមើលពីឥទ្ធិពលដែលគាត់មាន និងភាពល្បីល្បាញខាងការឆេវឆាវរបស់គាត់ ។ ក្រុមហ៊ុន Bechtel ត្រូវទទួលរងអំរែកយ៉ាងធ្ងន់ពីលោក Nixon ក្រុមហ៊ុន Ford និងក្រុមគូកនរបស់លោកប៊ូស ។ ខ្ញុំត្រូវបានគេប្រាប់ថា ក្រុមគ្រួសាររបស់ Bechtel ជាអ្នកជួយសង្គ្រោះដល់គណបក្សសាធារណរដ្ឋ ។ លោកបានលើកឡើងអំពីក្រុមហ៊ុនសាជីវកម្ម ការនាំមកជាមួយគ្នានៃរដ្ឋាភិបាល និងអំណាចសាជីវកម្ម ។

JOHN PERKINS : បាទ ការពិត វាអាក្រក់ណាស់ ។ នៅពេលនោះ លោក George Schultz គឺជាប្រធានក្រុមហ៊ុន Bechtel ។ លោក Casper Weinberger គឺជានាយកខាងផ្ដល់ប្រឹក្សារបស់ក្រុមហ៊ុន ដែលលោកគឺជាមន្ត្រីជាន់ខ្ពស់មួយរូបនៅក្នុងសាជីវកម្មនេះ ។ ពួកគេបានប្រឆាំងនឹងលោក Torrijos មិនត្រឹមតែលើការផ្ទេរព្រែកជីកទៅប្រទេសប៉ាណាម៉ាប៉ុណ្ណោះទេ ប៉ុន្តែប្រហែលជាសំខាន់ជាងនេះទៅទៀតនោះគឺ ដោយសារតែ Torrijos បានធ្វើការចរចារយ៉ាងសកម្មជាមួយជប៉ុនក្នុងការសាងសង់ព្រែកជីកលំដាប់ទឹកសមុទ្រថ្មី ។ ដូចលោកដឹងហើយថា ព្រែកជីកបច្ចុប្បន្ននេះ គឺពឹងផ្អែកទៅលើសន្ទះផ្លូវទឹក ហើយនាវាធំៗលើពិភពលោកមិនអាចឆ្លងកាត់បានឡើយ ។ ដូចនេះគំនិត នោះគឺការសាងសង់ព្រែកជីកលំដាប់ទឹកសមុទ្រដែលនាវាទំហំណាក៏អាចឆ្លងកាត់បាន ហើយជប៉ុនបានសុំផ្ដល់ថវិកាលើការសាងសង់នេះ ។

ប៉ុន្តែបើពួកគេផ្តល់ថវិកាលើការសាងសង់នោះ មានន័យថា ជប៉ុននឹងប្រើក្រុមហ៊ុនសាងសង់ក្រុមហ៊ុនវិស្វកម្មរបស់ពួកគេ ដើម្បីធ្វើការសាងសង់ជាមិនខាន ។ ក្រុមហ៊ុន Bechtel ខឹងសម្បារយ៉ាងខ្លាំងក្នុងរឿងនេះ ។ ពួកគេពិតជាមិនអាចអត់ទ្រាំមើលឃើញគំនិត/រឿងនេះកើតឡើងបានឡើយ ។ ពួកយើងបានដឹងពីរឿងនេះយ៉ាងច្បាស់ ហើយយើងត្រូវតែឈ្នះ លើលោក Torrijos ។ ឥឡូវនេះ ---

AMY GOODMAN: បន្ទាប់មក ដូចដែលលោកបានលើកឡើង Schultz បានក្លាយទៅជារដ្ឋលេខានៅក្រោមរដ្ឋបាលលោក Reagan, ហើយលោក Casper Weinberger ក្លាយទៅជារដ្ឋលេខាធិការការពារជាតិនៅក្រោមរដ្ឋបាលលោក Reagan ។ លោកដឹងទេ ពួកគេគឺជាក្បាលម៉ាស៊ីនរបស់សាជីវកម្ម Bechtel?

JOHN PERKINS: បាទ ត្រូវហើយ ។ លោក Carter បានធ្វើការចរចារលើសន្ធិសញ្ញា ហើយក្រោយមកបានចាញ់ការបោះឆ្នោត មូលហេតុមួយភាគដោយសារតែសន្ធិសញ្ញានេះ ហើយភាគខ្លះទៀតដោយសារតែអ្វីដែលបានកើតឡើងនៅប្រទេសអ៊ីរ៉ង់ ដែលនោះគឺជារឿងមួយផ្សេងទៀតដែលខ្ញុំបានចូលរួម ។ បន្ទាប់មក នៅពេលដែលលោក Reagan បានក្លាយជាប្រធានាធិបតី Schultz បានដូរចេញពីប្រធានក្រុមហ៊ុន Bechtel ហើយក្លាយទៅជារដ្ឋលេខាធិកា ហើយលោក Weinberger ដូរចេញពីប្រធានផ្នែកផ្តល់ប្រឹក្សារបស់ក្រុមហ៊ុន Bechtel ទៅជារដ្ឋលេខាធិការការពាជាតិ ។ ពួកគេត្រឡប់ទៅប្រទេសប៉ាណាម៉ាវិញ ហើយនិយាយជាមួយលោក Omar OK ឥឡូវនេះ យើងត្រូវនិយាយគ្នាម្តងទៀត ពួកយើងត្រូវការលើកយកបញ្ហាព្រែកជីកឱ្យមកនិយាយវិញ យើងត្រូវការឱ្យមូលដ្ឋានទ័ពយើងមកតាំងនៅក្នុងតំបន់ព្រែកជីកនេះ ហើយសំខាន់ជាងអ្វីៗទាំងអស់ ពួកយើងត្រូវការឱ្យលោកឈប់និយាយជាមួយពួកជប៉ុន ។ លោក Torrijos បានឆ្លើយថាទេ ។ ប្រទេសខ្ញុំគឺជាប្រទេសដែលមានអធិបតេយ្យភាព ។ ខ្ញុំមិនប្រឆាំងនឹងសហរដ្ឋអាមេរិកទេ ។ ខ្ញុំមិនមែនជាអ្នកសង្គមនិយមទេ ខ្ញុំមិនមែនជាអ្នកកុម្មុយនីសទេ ខ្ញុំមិនចូលខាងប្រទេសគុយបា ឬប្រទេសរុស្ស៊ី ឬប្រទេសចិនទេ និយាយឱ្យខ្លីគឺខ្ញុំក្រោកឈរឡើងដើម្បីការពារសិទ្ធិរបស់ប្រជាជនខ្ញុំ ។ ពួកយើងមានសិទ្ធិធ្វើការចរចារជាមួយអ្នកណាក៏ដោយឱ្យតែអាចធ្វើព្រែកជីកមានគុណភាពល្អឱ្យពួកយើង ។ ខ្ញុំមានសិទ្ធិចរចាជាមួយជប៉ុន ។ គាត់បានក្រោកឈរទាំងកំហឹង ហើយក្នុងកំឡុងពីរបីខែក្រោយមក យន្តហោះរបស់គាត់បុកជាមួយភ្នំមួយ យន្តហោះនោះផ្ទុះហើយបុកនឹងភ្នំដោយមានភស្តុតាងយ៉ាងច្បាស់ណាស់ថា យន្តហោះនោះផ្ទុះដោយសារតែម៉ាញេមួយដែលត្រូវបានហុចទៅឱ្យគាត់ជាមនុស្សចុងក្រោយ ដែលក្នុងនោះមានផ្ទុកទៅដោយរំសេវផ្ទុះ ។ វាគ្មានសំណួរនៅក្នុងគំនិតរបស់ខ្ញុំទេ ហើយក៏ដូចជានៅគំនិតរបស់មនុស្សជាច្រើននៅលើពិភពលោកដែរ នេះគឺជា jackals ក្រុមដាក់ទ័ណ្ឌកម្មដោយការពិឃាដ ស៊ី-អាយ-អេ ។ ខ្ញុំបានឃើញក្រុមនេះធ្វើអំពើបែបនេះនៅប្រទេសជាច្រើនមកហើយ ។ ប៉ុន្មានខែមុន មុនរឿងនេះកើតឡើង ក្រុមនេះបានធ្វើរឿងដូចគ្នានេះដែរចំពោះលោក Jaime Roldos ដែលជាប្រធានាធិបតីរបស់ប្រទេស

អេក្វាឌ័រ ដែលលោកគឺជាប្រធានាធិបតីដែលជ្រើសតាំងតាមរយៈការបោះឆ្នោតបែបប្រជាធិបតេយ្យ តំបូងក្នុងពេលប៉ុន្មានទសវត្សនេះ ត្រូវបានជំនួសដោយក្រុមមេបញ្ជាការទាហ៊ានដែលធ្វើរដ្ឋប្រហារដណ្តើមអំណាច ។ លោកជាប្រធានាធិបតីដែលត្រូវបានជ្រើសតាំងជាលក្ខណៈប្រជាធិបតេយ្យ ហើយលោកបានក្រោកឈរឡើងប្រឆាំងនឹងក្រុមហ៊ុនប្រេងរបស់អាមេរិក ។ យើងដែលជាអ្នកវាយលុកសេដ្ឋកិច្ចមិនអាចចូលទៅជិតគាត់បានឡើយ ហើយឧទ្ធម្ភាគចក្ររបស់គាត់បានផ្ទុះនៅទីនោះទៀតផង ។

AMY GOODMAN: ហេតុអ្វី បានជាគាត់ក្រោកឈរឡើងប្រឆាំងនឹងក្រុមហ៊ុនប្រេងរបស់អាមេរិក?

JONH PERKINS: ជាថ្មីម្តងទៀត គឺដោយសារតែលោកជាប្រធានាធិតីដែលដឹកនាំប្រទេសតាមលទ្ធិប្រជាធិបតេយ្យនៅប្រទេសអេក្វាឌ័រក្នុងប៉ុន្មានទសវត្សនេះ ។ លោកដឹកនាំប្រទេសតាមទំរង់អធិបតេយ្យភាពសំរាប់ប្រទេសរបស់លោក ហើយបើសិនជាមានប្រេងនៅក្នុងប្រទេសអេក្វាឌ័រ នាពេលនោះលោកនិយាយថា ជនជាតិអេក្វាឌ័រត្រូវតែជាអ្នកដែលទទួលបានផលប្រយោជន៍ពីប្រេងនេះ ។ នៅពេលដែលលោកបានក្លាយជាប្រធានាធិបតី លោកចាប់ផ្តើមធ្វើការណែនាំរឿងទាំងនេះ ។ លោកបានបង្កើតច្បាប់ Hydrocarbons Act (លោកហៅច្បាប់នោះដូច្នេះ) ដែលជាសំខាន់ គឺជាច្បាប់លើប្រេងឥន្ទនៈដែលនឹងធ្វើឱ្យប្រាកដថា ប្រសិនបើមានប្រេងដឹកចេញពីប្រទេសអេក្វាឌ័រ ភាគច្រើននៃថវិកាដែលបានមកពីប្រេងនោះនឹងធ្លាក់ទៅប្រជាជនរបស់លោក ។ ក្រុមហ៊ុនប្រេងទាំងនេះ នឹងទទួលបាននូវការផ្តល់លុយឱ្យដ៏សមរម្យមួយ ។ ក៏ប៉ុន្តែថវិកាភាគច្រើនត្រូវតែបានទៅប្រជាជនរបស់លោក ។ លោកបានបង្កើតនូវបញ្ហាមួយដែលក្រុមហ៊ុនប្រេងទាំងឡាយមិនអាចទទួលយកបាន ពីព្រោះនៅគ្រប់ទីកន្លែងនៅលើពិភពលោក ពួកគេបានកេងប្រវ័ញ្ចពីប្រទេសទាំងនេះ ហើយនៅតែធ្វើរហូតដល់ពេលនេះ ។ Roldos និយាយថា ខ្ញុំនឹងមិនអនុញ្ញាតឱ្យរឿងនេះកើតឡើងនៅក្នុងប្រទេសរបស់ខ្ញុំទេ ។ ក្រុមហ៊ុនប្រេងមិនអាចឈរមើលរឿងនោះបានឡើយ មិនមែនត្រឹមដោយសារតែប្រទេសអេក្វាឌ័រទេ ប៉ុន្តែម្តងទៀត គឺដោយសារតែបញ្ហាដែលនឹងត្រូវបង្កើតឡើង ។ ហើយ Roldos និង Torrijos គឺជាដៃគូរនឹងគ្នា ។ ក្នុងពេលជាមួយគ្នា ពួកគេគាំទ្រគ្នាទៅវិញទៅមក ហើយពួកគេទាំងពីរត្រូវតែទៅ ។ ពួកគេទាំងពីរបានទៅមែន ។

AMY GOODMAN: តើនៅពេលនោះអ្នកមានគំនិតដូចម្តេចដែរ? ខ្ញុំមានន័យថា អ្នកនៅតែបន្តធ្វើការងារនេះតទៅទៀត ?

JONH PERKINS: វាគឺជាចំណុចដ៏សំខាន់ក្រៃលែងសំរាប់ខ្ញុំដែលគ្រប់ការងាររបស់ខ្ញុំ ដូចដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅ សម្បជញ្ញៈរបស់ខ្ញុំត្រូវបានហែកហួរ ។ សំរាប់ខ្ញុំ រឿងនេះគឺជាផ្នែកដ៏សំខាន់មួយនៃរឿងរ៉ាវជីវិតផ្ទាល់ខ្លួន

របស់ខ្ញុំ ។ ខ្ញុំគិតថា ខ្លួនឯងគឺជាមនុស្សល្អម្នាក់ ។ ខ្ញុំបានចំរើនវ័យឡើង ៣០០ឆ្នាំ ជាជនជាតិ Civinist អាមេរិកាំង នៅ Vermont និង Hapshire ។ ខ្ញុំកើតចេញមកពីក្រុមគ្រួសារដែលមានប្រវត្តិស្នេហាជាតិ ។ ខ្ញុំចំរើនវ័យឡើងនៅក្នុងគ្រួសារសាធារណរដ្ឋដ៏តឹងរឹង អភិរក្សនិយមខ្លាំងណាស់ ។ ខ្ញុំប្រកាន់នូវតំលៃដ៏តឹងរឹង ខ្ញុំស្មោះត្រង់នឹងប្រទេសរបស់ខ្ញុំណាស់ ។ ហើយ---

AMY GOODMAN: ជនជំនាន់ក្រោយរបស់ **Tome Paine** និង **Ehan Alleen**?

JOHN PERKINS: ត្រឹមត្រូវហើយ ។ ពួកគេគឺជាសាច់ញាតិឆ្ងាយរបស់ខ្ញុំ ។ ឪពុកម្តាយខ្ញុំបានទម្លាប់ខ្ញុំទៅក្នុងប្រវត្តិសាស្ត្រអាមេរិក និងក្នុងតំលៃបិតានៃការកសាងប្រទេសរបស់យើង ។ ជីវិត សេរីភាព និងការស្វែងរកនូវសុភមង្គលសំរាប់មនុស្សគ្រប់រូប ។ ខ្ញុំមានជំនឿខ្លាំងណាស់លើគំនិតទាំងអស់នេះ ។ ហើយក្នុងពេលដូចគ្នានេះខ្ញុំមានការទាក់ចិត្តទៅនឹងទឹកប្រាក់ អំណាច និងសិច ។ របស់ទាំងអស់នេះបានមកដល់ផ្លូវជីវិតរបស់ខ្ញុំ ហើយខ្ញុំកំពុងតែធ្វើការងារដែលទទួលនូវការអង្អែលខ្នងពីសំណាក់ប្រធានរបស់ធនាគារពិភពលោក **Robert MacNamara** ។ ខ្ញុំជាប្រធានសេដ្ឋកិច្ចវិទូនៃក្រុមហ៊ុនផ្តល់ប្រឹក្សាដ៏ធំមួយនៅបូស្តុន ។ ខ្ញុំមានមនុស្ស ៥០ នាក់ ធ្វើការឱ្យខ្ញុំដែលពួកគេសុទ្ធតែមានសញ្ញាប័ត្រអនុបណ្ឌិត បណ្ឌិត ។ ខ្ញុំកំពុងតែធ្វើការដែលមុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ចនៅក្នុងមហាវិទ្យាល័យបានបង្រៀនខ្ញុំថាវាគឺជាការងារល្អដែលត្រូវធ្វើ ។ វាគឺជារឿងកុហកទាំងអស់ ។

AMY GOODMAN: ហេតុអ្វីបានជាមានមនុស្សតែប៉ុន្មាននាក់ ដឹងឮអំពីក្រុមហ៊ុននេះ-Main?

JOHN PERKINS: ក្រុមហ៊ុនយើងគឺជាក្រុមហ៊ុនដ៏ស្ងៀមស្ងាត់មួយ ។ យើងមានបុគ្គលិកជំនាញប្រមាណ ២,០០០នាក់ ដែលនេះមិនមែនជាក្រុមហ៊ុនតូចទេ ។ យើងគឺជាក្រុមហ៊ុនដែលកាន់កាប់យ៉ាងប្រុងប្រយត្ន័ មានន័យថា យើងគឺជាម្ចាស់ ហើយវាដូចគ្នានឹងភាពជាដៃគូរ ។ ប្រហែលជា ៥% នៃពួកយើង (បុគ្គលិកទាំងអស់) គឺជាម្ចាស់ក្រុមហ៊ុន ដូច្នេះយើងមិនចាំបាច់បង្ហាញនូវសៀវភៅនានារបស់យើងទៅ S.E.C ឬនរណាផ្សេងឡើយ ។ យើងគឺជាក្រុមហ៊ុនមួយដ៏ឯកជនស្ងៀមស្ងាត់ ហើយយើងកំពុងបំរើផលប្រយោជន៍ឱ្យពួកចក្រពត្តិ ។ ក្រុមហ៊ុននេះមិនមានរូបរាងទៀតទេ ។ នៅដើមទសវត្ស ១៩៨០ ដៃគូរនានាបានលក់ហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនវិស្វកម្មសំណង់ដ៏ធំមួយ ហេតុដូចនេះ ក្រុមហ៊ុននោះក៏បាត់ស្រមោលនៅពេលនោះ ។ ខ្ញុំគិតថានៅពេលនេះ យើងហាក់ដូចជាកំពុងឈានទៅរកចំណុចក្តៅ ។ ក៏ប៉ុន្តែវា គឺជាចេតនា ។ យើងទាំងអស់គ្នាត្រូវបានហាមប្រាមយ៉ាងតឹងរឹងមិនឱ្យជួបនិយាយជាមួយនឹងបណ្តាញសាពតិមានទេ។ ក្នុងពេលមួយនោះខ្ញុំបានធ្វើល្មើសនឹងបទបញ្ញត្តិ ។ ខ្ញុំបានសរសេររឿងព្រេកជីកប៉ាណាម៉ាសំរាប់ឱ្យ Boston Globe ហើយខ្ញុំត្រូវទទួលទណ្ឌកម្មនៅក្នុងក្រុមហ៊ុន ។ ដូច្នេះ វាគឺជាចេតនាដែលយើងត្រូវតែបិទមាត់ ។

AMY GOODMAN: យើងត្រូវតែសំរាកបន្តិច ។ នៅពេលយើងត្រឡប់មកវិញ ខ្ញុំពិតជាចង់សួរលោកអំពី Robert MacNamara ។ លោកនិយាយអំពីក្រុមហ៊ុនសាជីវកម្ម វាប្រាកដណាស់ដែលគាត់ជាអ្នកតំណាង តាំងពីក្លាយពីនាយកគ្រប់គ្រងប្រតិបត្តិ-CEOរបស់ក្រុមហ៊ុន Ford ទៅជារដ្ឋលេខាធិការក្រសួងការពារជាតិ ហើយចុងក្រោយគាត់ជាប្រធានធនាគារពិភពលោក ហើយថា តើតួនាទីខុសៗគ្នានោះវាមានផលប៉ះពាល់យ៉ាងណា ហើយថាតើតួនាទីទាំងនោះវាមានលក្ខណៈប្រហាក់ប្រហែលគ្នាអ្វីខ្លះ លោកបានជជែកថា ពីរដ្ឋលេខាធិការក្រសួងការពារជាតិទៅជាប្រធានធនាគារពិភពលោក គឺគាត់ធ្វើការងារសឹងតែដូចគ្នា ។ យើងកំពុងតែនិយាយជាមួយលោក John Perkins ដែលជាអ្នកនិពន្ធសៀវភៅ*ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* ។ ប្រសិនបើលោកអ្នកចង់បានឯកសារមួយច្បាប់ពីការសន្ទនានេះ សូមបើកគេហទំព័ររបស់យើងគឺ democracynow.org ។ យើងនឹងត្រឡប់មកវិញជាមួយនិងលោកអ្នកក្នុងពេលបន្តិចទៀតនេះ ។

AMY GOODMAN: យើងបន្តការសន្ទនាជាមួយលោក John Perkins សៀវភៅរបស់គាត់មានចំណងជើងថា *ការសារភាពរបស់អ្នកវាយលុកម្នាក់* ។ គាត់ចូលរួមជាមួយយើងនៅស្ថានីយ៍ Firehouse នៅទីនេះក្នុងសហគមន៍ទូរ-ទស្សន៍កណ្តាលទីក្រុង តែប៉ុន្មានផ្លូវពីកន្លែងដែលអាគារមណ្ឌលពាណិជ្ជកម្មពិភពលោកធ្លាប់តែតាំងនៅ ពីជាន់ផ្ទាល់ដី ហើយយើងនឹងជជែកអំពីផលប៉ះពាល់ពីព្រឹត្តិការណ៍ថ្ងៃ ១១ ខែកញ្ញា និងថាតើមុខងារវាដើរតួអ្វីខ្លះនៅក្នុងការសរសេរសៀវភៅរបស់លោក John Perkins ។ ប៉ុន្តែមុននឹងយើងជជែកពីបញ្ហានេះ លោកសរសេរពីគាត់គឺលោក Robert MacNamara ។ សូមនិយាយពីតួនាទីរបស់គាត់ពីអគ្គនាយកក្រុមហ៊ុន Ford ទៅជារដ្ឋលេខាធិការក្រសួងការពារជាតិ និង ទៅកាន់នៅធនាគារពិភពលោក ។

JOHN PERKINS: អឺ...Amy ខ្ញុំគិតថាអ្វីដែលយើងមាននៅទីនេះ គឺជាពិភពលោកនៃចក្រពត្តិដែលត្រូវបានគ្រប់គ្រងដោយមនុស្សមួយក្រុមតូចបំផុតដែលខ្ញុំហៅថាក្រុមហ៊ុនសាជីវកម្ម ហើយក្រុមនេះគឺជាក្បាលម៉ាស៊ីននៃក្រុមហ៊ុនសាជីវកម្មធំៗ ធនាគារធំៗ និងរដ្ឋាភិបាល ហើយពួកគេទំនងជាមនុស្សតែមួយ ។ តើលោកដឹងទេ ពួកគេលោតរំលងខ្សែបន្ទាត់ទាំងនេះ ហើយលោក MacNamara គឺជាឧទាហរណ៍យ៉ាងសំខាន់ចំពោះរឿងនេះ ។ គាត់ធ្លាប់ជាអគ្គនាយកក្រុមហ៊ុន Ford បន្ទាប់មកគាត់បានក្លាយជារដ្ឋលេខាធិការក្រសួងការពារជាតិនៅក្រោមរដ្ឋបាល លោក Kenneddy និងលោក Johnson ហើយក្រោយមកលោកក្លាយជាអគ្គនាយកនៃធនាគារពិភពលោក ។ នៅក្នុងមុខតំណែងទាំងបីនេះ ការងារសំខាន់របស់គាត់គឺដើម្បីលើកកំពស់ពាណិជ្ជកម្មរបស់អាមេរិក ផ្សព្វផ្សាយក្រុមហ៊ុនសាជីវកម្មនាំយកនូវផលប្រយោជន៍ផ្សេងៗត្រឡប់មកវិញដើម្បីធ្វើកេងប្រវ័ញ្ចពិភពលោក ។ លោករស់នៅក្នុងរបបប្រជាធិបតេយ្យក្រោមរដ្ឋបាលលោក Kenneddy និងលោក Johnson ។ បច្ចុប្បន្ននេះ យើងមានលោក Dick Cheney ដែលជារួម

គឺមានសមាសភាពដូចគ្នា ។ យើងធ្លាប់មានលោក George Schultz នៅក្រោមការគ្រប់គ្រងរបស់អតីតប្រធានាធិបតីប៊ូស ។ ដូច្នេះប្រធានាធិបតី ប៊ូស ទាំងពីរ មានមនុស្សប្រភេទធ្វើការដូចគ្នា ។ នៅមានលោកស្រី Condoleezza Rice ទៀត ។ នៅក្នុងរដ្ឋបាលមួយៗមានមនុស្សបែបនេះនៅពាសពេញ ។ ក៏ប៉ុន្តែវាមិនមែនតែ ជាបញ្ហារបស់គណបក្សសាធារណរដ្ឋប៉ុណ្ណោះទេ ។ វាគឺជាបញ្ហាទ្វេរភាគី ។ បញ្ហានេះវាឆ្លងកាត់ខ្សែបន្ទាត់ទាំងអស់ ហើយលោក MacNamara គឺជាឧទាហរណ៍យ៉ាងល្អចំពោះបញ្ហានោះ ។ ខ្ញុំគិតថា នៅក្នុងពេលជាមួយគ្នានោះ លោក MacNamara គឺជាមនុស្សម្នាក់ដ៏សំខាន់បំផុតក្នុងចំណោមមនុស្សជាច្រើនទៀត បើនិយាយពីការកំណត់គ្រោងការ សេដ្ឋកិច្ចថ្មី ជាអ្វីដែលលោកហៅថា ការគ្រប់គ្រងយ៉ាងគឃ្លើន វាពិតជាគឃ្លើនមែនបើនិយាយពីការចេញទៅក្រៅសហរដ្ឋអាមេរិក ហើយកាន់កាប់ពិភពលោក និងប្រមូលយកផលប្រយោជន៍មកដាក់ជារបស់យើងដូចអ្វីដែលយើងមានសព្វថ្ងៃនេះ ក្នុងចំណោមសេដ្ឋកិច្ចដ៏ធំមហិមា ចំនួន ១០០ នៅក្នុងពិភពលោក សេដ្ឋកិច្ចដ៏ធំមហិមា ៥២ ជាក្រុមហ៊ុនសាជីវកម្ម ហើយក្នុងចំណោមនោះ (៥២) មាន ៤៧ គឺជាក្រុមហ៊ុនសាជីវកម្មរបស់អាមេរិក ហើយវាមិនជាប្រទេសទេតែវាគឺជាក្រុមហ៊ុនសាជីវកម្ម ។ នៅសហរដ្ឋអាមេរិក អត្រាប្រជាជនយើងគឺមានត្រឹមតែ ៥% នៃអត្រាប្រជាជនទូទាំងពិភពលោក ដែលពង្រីកខ្លួនប្រៀបដូចជាត្រីមឹកយក្សមួយ ហើយបឺតជញ្ជក់និងស្រូបយកធនធាន ២៥% ឬច្រើនជាងនេះពីពិភពលោក ។ ក៏ប៉ុន្តែប្រជាជនអាមេរិកមិនប្រាកដជា ៥% នៃអត្រាប្រជាជនលើពិភពលោកទេ ។ អត្រាប្រជាជនអាមេរិក ១% ជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិច្រើនជាងប្រជាជនអាមេរិក ៩០% មាន ។ ដូច្នេះ គឺចំនួន ១% នេះហើយដែលជាក្រុមហ៊ុនសាជីវកម្មបឺតជញ្ជក់យកផលកំរៃ ហើយពួកយើងទាំងអស់គ្នាដែលនៅសល់គឺជាអ្នកជួយឧបត្ថម្ភដល់ពួកគេតាមរយៈការបង់ពន្ធនានារបស់យើង តាមរយៈការទិញទំនិញប្រើប្រាស់តាមរយៈភាពស្ងៀមស្ងាត់របស់យើង និងតាមរយៈការដើរតាមប្រព័ន្ធនេះ ។ ដូចជារូបខ្ញុំជាដើមដែលជាអ្នកវាយលុកសេដ្ឋកិច្ច ខ្ញុំតែងតែដើរតាមប្រព័ន្ធនេះ ។ ខ្ញុំបានធ្វើលើសពីការដើរតាមប្រព័ន្ធនេះទៅទៀត ដោយខ្ញុំបានលើកតំកើងប្រពន្ធ័នេះផងដែរ ។ ក៏ប៉ុន្តែ ខ្ញុំបានធ្វើវាយ៉ាងស្របច្បាប់ហើយខ្ញុំក៏បានធ្វើដូច្នេះនៅខណៈពេលនោះដែរ ខ្ញុំត្រូវបានអង្អែលខ្នងដោយពួកមនុស្សទាំងអស់នោះ ដែលខ្ញុំត្រូវបានបង្រៀនឱ្យស្ញើចសរសើរចំពោះពួកគេ ។

AMY GOODMAN: ដូច្នេះលោកធ្វើការឱ្យក្រុមហ៊ុនផ្តល់ប្រឹក្សាអន្តរជាតិដែលហៅថា Main នៅទីក្រុងបូស្តុន ។ លោកបានក្លាយជាប្រធានសេដ្ឋកិច្ចវិទូនៅទីនោះ មានមនុស្ស ២.០០០ នាក់ ត្រូវបានជួលឱ្យធ្វើការទីនោះ ហើយធ្វើការងារយ៉ាងជិតស្និទ្ធជាមួយវិជ្ជាស្ថានហិរញ្ញវត្ថុអន្តរជាតិដូចជាធនាគារពិភពលោកជាដើម ។ លោកចាប់ផ្តើមសរសេរសៀវភៅរបស់លោកនៅប្រទេសឥណ្ឌូនេស៊ី ។ សូមលោករៀបរាប់ពីការហ្វឹកហ្វឺនរបស់លោកនៅទីនោះម្តង និងអ្វីដែលលោកព្យាយាមធ្វើដើម្បីទទួលបានជោគជ័យ ។

JOHN PERKINS: នៅប្រទេសឥណ្ឌូនេស៊ីគឺនៅឆ្នាំ ១៩៧០-១៩៧១ នៅតំបន់នោះ ។ យើងដឹងថា នៅចំណុចនេះ ប្រទេសវៀតណាម គឺនឹងធ្វើដំណើរទៅហើយ ។ យើងក៏នឹងចាញ់នៅប្រទេសវៀតណាម ។

AMY GOODMAN: នៅកណ្តាលសង្គ្រាម ។

JOHN PERKINS: មែនហើយ នៅកណ្តាលសង្គ្រាម ។ ប៉ុន្តែត្រង់ចំណុចនេះ មនុស្សដែលធ្វើការនៅខាងលើបានដឹងថា យើងនឹងចាញ់ទោះបើជាពួកគេមិនព្រមទទួលក៏ដោយ ។ ពួកគេបានដឹងច្បាស់ ។ ដូច្នេះជាមួយទ្រឹស្តីដូមីណូបានអនុវត្តន៍ គឺថាបើឥណ្ឌូនេស៊ីធ្វើបាន ប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍នឹងធ្វើបានដូចជាដូមីណូ ប្រទេសមួយម្តងៗ (មួយក្នុងពេលមួយ) ។ ប្រទេសឥណ្ឌូនេស៊ីត្រូវបានមើលឃើញថាជាគន្លឹះមួយសំរាប់បញ្ឈប់ដំណើរការនោះ ។ យើងមិនចង់ឱ្យលទ្ធិកុម្មុយនីសនិយមចូលទៅទីនោះទេ ។ នៅប្រទេសឥណ្ឌូនេស៊ីក៏ប្រទះឃើញមានប្រេងច្រើនដែរ ហើយយើងត្រូវការ ឬចង់បាន ដែលប្រទេសនេះមានប្រជាជនកាន់សាសនាមូស្លីមច្រើនជាងគេបំផុតនៅលើពិភពលោក ។ ដូច្នេះ ប្រសិនបើយើងអាចយកឈ្នះលើប្រទេសឥណ្ឌូនេស៊ីបាន ហើយយកប្រទេសនេះធ្វើជាទាសករនៅក្នុងកណ្តាប់ដៃរបស់យើងបាន យើងនឹងបានសំរេចបានជោគជ័យជាច្រើន ។ ដូច្នេះ ខ្ញុំត្រូវបានគេបញ្ជូនឱ្យទៅទីនោះដើម្បីធ្វើឱ្យរឿងរ៉ាវទាំងនេះកើតឡើង ដើម្បីរៀបចំប្រាក់កម្ចីយ៉ាងច្រើនដល់ប្រទេសឥណ្ឌូនេស៊ី ហើយឱ្យប្រទេសនេះសាងសង់ប្រព័ន្ធអគ្គិសនីដ៏ធំមួយ ឬប្រព័ន្ធអគ្គិសនីធំៗជាច្រើនទៀត ដែលនឹងបំរើផលប្រយោជន៍ដល់ប្រជាជនឥណ្ឌូនេស៊ីដែលមានទ្រព្យសម្បត្តិច្រើន (អ្នកមាន) -- មិនបានជួយអ្នកក្រីក្រទេនិងធ្វើអតិផរណានៃការព្យាករណ៍ ដូច្នេះយើងអាចសាងសង់ប្រព័ន្ធអគ្គិសនីនេះកាន់តែធំ ធំហួសពីការស្មាន និងការគិតរបស់មនុស្ស ថាប្រទេសមួយ កោះមួយដូចជាកោះចាវ៉ាមានមនុស្សរស់នៅយ៉ាងច្រើនបំផុតនៃសំណង់គេហដ្ឋាននៅលើពិភពលោកនោះ ប៉ុន្តែយើងបានសាងសង់ប្រព័ន្ធអគ្គិសនីដ៏ធំនេះ ហើយវាពិតជាបានបំរើផលប្រយោជន៍ដល់ឧស្សាហកម្មនៅក្នុងប្រទេសនេះ ប៉ុន្តែវាមិនបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនឡើយ ។ ស្របពេលជាមួយគ្នានោះ យើងដាក់ប្រទេសឥណ្ឌូនេស៊ីឱ្យជំពាក់បំណុលយ៉ាងច្រើនសម្បើមរបស់ពួកយើង បំណុលដែលប្រទេសនេះពិបាកនឹងមានពេលដោះខ្លួនចេញរួច ដូច្នេះនឹងវាក្លាយជាផ្នែកមួយនៃចក្រពត្តិរបស់យើង ។

AMY GOODMAN: គាំទ្រ ស៊ូហាតូ មេដឹកនាំផ្តាច់ការអស់រយៈពេលជាច្រើនឆ្នាំ ។

JOHN PERKINS: ត្រឹមត្រូវហើយ ។ ទិដ្ឋភាពដែលគួរឱ្យចាប់អារម្មណ៍នៃរឿងរ៉ាវទាំងមូលនោះគឺនៅពេលនោះដែលខ្ញុំចូលរួមជាមួយក្រុមមួយដែលមានមនុស្ស ១១នាក់ ហើយមនុស្ស ១០នាក់ ទៀតនៅក្នុងក្រុមនោះមិនបានដឹងទាល់តែសោះថា យើងកំពុងធ្វើការងាររបស់អ្នកវាយលុកសេដ្ឋកិច្ច ។ ពួកគេជាវិស្វករ ។ ពួកគេគូរប្លង់ខ្សែបញ្ជូនសារ

ប្រពន្ធ័ប្រេងឥន្ទនៈដើម្បីនាំយកប្រេងឥន្ទនៈទៅដាក់ក្នុងរោងចក្រនានា ។ ពួកគេបានគូរប្លង់រោងចក្រ រោងចក្រដ៏ធំ ខ្សែចែកចាយនានា ។ ពួកគេជាវិស្វករ ។ ខ្ញុំជាអ្នកធ្វើការព្យាករណ៍ ។ ខ្ញុំគឺជាអ្នកដែលបាននិយាយថា សេចក្តីត្រូវការខាងអគ្គិសនីនឹងកើនឡើង ១៧% ក្នុងមួយឆ្នាំសំរាប់រយៈពេល ២០ ឆ្នាំ ដែលវាមិនដែលព្ធសោះ ប៉ុន្តែខ្ញុំធ្វើវា នេះជាការងាររបស់ខ្ញុំ ខ្ញុំត្រូវធ្វើអតិផរណាលើតួលេខទាំងនេះឱ្យកាន់តែច្រើនតាមដែលខ្ញុំអាចធ្វើទៅបាន ។ ខ្ញុំចង់មានន័យថា នោះជាតួលេខយ៉ាងច្រើននៅពេលយើងដាក់បញ្ចូលវាប្រចាំឆ្នាំ ។ ពួកគេបានត្រឹមតែដើរទៅជាមួយនឹងយើង ។ លោកដឹងទេថា សំរាប់ពួកគេវាជារឿងដែលអស្ចារ្យ ។ ពួកគេបានធ្វើការគូរប្លង់ប្រពន្ធ័ដ៏ធំ និងអស្ចារ្យនេះ វាជាការសុបិន្តរបស់វិស្វករ ។

AMY GOODMAN: លោកពិតជាបានទៅជំនួសបុរសម្នាក់នៅឥណ្ឌូនេស៊ី ដែលបានព្រមានលោកមិនឱ្យធ្វើការព្យាករណ៍ទាំងនេះលើសេដ្ឋកិច្ចដែលលោកមិនអាចជួយគាំទ្រ ។ វាជាល្បែងបោកប្រាស់មួយ ។ លោកដឹងទេ វាគ្រាន់តែជាការព្យាករណ៍ដែលលោកដាក់ចេញទៅ ហើយលោកនិយាយថា លោកមានការជឿជាក់លើការព្យារកណ៍នេះថា វានឹងជាករណីមួយ ពីព្រោះវានឹងបំផ្លាញប្រទេសនេះ ។ ប៉ុន្តែបុរសម្នាក់នោះត្រូវបានគេដកចេញ ។

JOHN PERKINS: មែនហើយ លោក Howard Parder បានចូលនិវត្តន៍ពីក្រុមហ៊ុនប្រព័ន្ធអគ្គិសនីអង់គ្លេសថ្មី (New English Electric System) ដោយសារតែការទទួលខុសត្រូវក្នុងការព្យាករណ៍ ការព្យាករណ៍នូវតំរូវការអគ្គិសនី ។ គាត់គឺជាបុរសដ៏ជូចត់បំផុត គាត់បានឃើញអ្វីដែលកំពុងកើតឡើង ប៉ុន្តែគាត់នៅតែជាបុរសដ៏ជូចត់ដដែល ហើយគ្មាននរណាម្នាក់ដែលអាចត្រូវរ៉ូវគ្នាល្អជាមួយ Howard ឡើយ ។ វាគឺជាការងាររបស់ខ្ញុំ គឺធ្វើការព្យាករណ៍សេដ្ឋកិច្ចរបស់ប្រទេសមួយ ។ ការងាររបស់គាត់ពេលនោះគឺធ្វើការព្យាករណ៍ពីតំរូវការប្រពន្ធ័អគ្គិសនីនៅក្នុងប្រទេសមួយ ។ ប៉ុន្តែការព្យាករណ៍ទាំងពីរនេះមានការទាក់ទងគ្នាយ៉ាងជិតស្និត ដូច្នេះប្រសិនបើខ្ញុំធ្វើការព្យាករណ៍ថា កំណើនលើវិស័យសេដ្ឋកិច្ចរបស់ប្រទេសនឹងឡើងដល់ ១៧% ឬ ១៨% ដូច្នេះការទទួលខុសត្រូវលើការព្យាករណ៍ពីអគ្គិសនីរបស់គាត់ត្រូវតែចេញមកប្រហាក់ប្រហែលគ្នា តែគាត់បានប្រាប់ខ្ញុំថា *ខ្ញុំនឹងមិនដើរតាមប្រពន្ធ័នេះទេ ។ នេះគឺជាឧបាយកលមួយ ។ លោកកំពុងតែត្រូវបានទិញក្បាលដោយប្រព័ន្ធនេះហើយ ។ ទាំងអស់នេះគឺដោយសារតែភាពលោភលន់ ហើយខ្ញុំនឹងមិនដើរតាមប្រពន្ធ័នេះទេ* ។ ក្នុងលក្ខណៈមួយវាធ្វើឱ្យខ្ញុំរួចខ្លួន ។ ខ្ញុំមានអារម្មណ៍ធូរស្រាលខ្លាំងណាស់ ។ នៅត្រង់ចំណុចមួយ ខ្ញុំមានការភ្ញាក់ខ្លួន យី! ខ្ញុំអាចធ្វើអ្វីដែលអ្នកហ្វឹកហ្វឺនបានបង្រៀនខ្ញុំឱ្យធ្វើ និងអ្វីដែល Claudine បានប្រាប់ខ្ញុំថា ខ្ញុំត្រូវតែធ្វើហើយរឿងនេះ វាបានលេចឡើងជាមួយនឹងការទទួលខុសត្រូវលើព្យាករណ៍អគ្គិសនីយ៉ាងខ្ពស់ទាំងនេះ ប៉ុន្តែមនសិកាខ្ញុំ គឺកាន់តែច្បាស់ដោយសារ Harward មិនយកចិត្តទុកដាក់លើការព្យាករណ៍ទាំងនោះទៀតឡើយ ។ គាត់នឹងបញ្ចេញនូវការទទួលខុសត្រូវលើការព្យាករណ៍លើអគ្គិសនីដែលមានកំរិតទាបជាង

ដូច្នេះ យើងពិតជានឹងមិនបោកប្រាស់ប្រទេសនោះទេ ។ ប្រាកដណាស់ថា បន្ទាប់មកពេលខ្ញុំត្រឡប់មកបូស្តុនវិញ ខ្ញុំបានឃើញថា ចៅហ្វាយរបស់ខ្ញុំបានបណ្តេញ Harward ចោល ហើយហៅខ្ញុំចូលទៅក្នុងការិយាល័យរបស់គាត់ ហើយប្រាប់ខ្ញុំថា Harward មិនបានបំពេញតួនាទីរបស់ខ្លួន ។ គាត់ (Harward) មានការព្យាករណ៍ដែលទាបគួរឱ្យអស់សំណើច ដូចនេះយើងបណ្តេញគាត់ចេញ ។ យើងនឹងឱ្យលោកធ្វើការងាររបស់គាត់ (Harward) ព្រមទាំងការងាររបស់លោកផ្ទាល់ ។ យើងនឹងលើកតំកើងលោកជាប្រធាននាយកដ្ឋាន ។ លោកកំពុងតែក្លាយជាអ្នកមាន ។ តើលោកដឹងទេ ដា ដា ដា ដា ។ ប៉ុន្តែ លោកត្រូវតែបញ្ចេញនូវការព្យាករណ៍ទាំងអស់ដែលយើងកំពុងតែចង់បានពីគាត់ (Harward) យើងដឹងថា លោកអាចធ្វើបាន ពីព្រោះលោកបានធ្វើវារួចហើយ សំរាប់វិស័យសេដ្ឋកិច្ចរបស់ប្រទេសនោះ ។

AMY GOODMAN: ចុះប្រទេសអ៊ីរ៉ង់វិញ យ៉ាងម៉េចដែរ?

JOHN PERKINS: អឺ.. នៅពេលនោះប្រទេសអ៊ីរ៉ង់ស្ថិតក្រោមការដឹកនាំរបស់ព្រះមហាក្សត្រ Shah ។ អ៊ីរ៉ង់ គឺជាប្រទេសដែលអ្នកវាយលុកសេដ្ឋកិច្ចចាប់ផ្តើមធ្វើការងារ ព្រោះនៅដើមទសវត្ស ១៩៥0 ប្រទេសអ៊ីរ៉ង់បានបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ជ្រើសរើសបុរសម្នាក់ឈ្មោះ Mossadeq ធ្វើជានាយករដ្ឋមន្រ្តីដំបូងបង្អស់ ។ គាត់បានកាន់ដំណែងនេះ--ខ្ញុំជឿថា គាត់ជាបុរសនិមិត្តរូបរបស់ទស្សនាវដ្តី Time នៅក្នុងឆ្នាំនោះ ១៩៥១ ។ គាត់ត្រូវបានប្រជាជនចាត់ទុកជាអ្នកដឹកនាំនៃក្តីសង្ឃឹមរបស់មជ្ឈឹមបូពា តាមការពិតគឺក្តីសង្ឃឹមរបស់ពិភពលោកទាំងមូលនៃមេដឹកនាំដែលជ្រើសរើសដោយលទ្ធិប្រជាធិតេយ្យ ។ ប៉ុន្តែភ្លាមៗ បន្ទាប់ពីគាត់បានចូលកាន់អំណាច គាត់ក្រោកឈរឡើងប្រឆាំងនឹងក្រុមហ៊ុនប្រេងឥន្ធនៈ ។ គឺជាស្រមោលមុនដែលក្រោយមកត្រូវបានធ្វើតាមដោយ Roldos និង Toorijos ។ គាត់ពិតជាបានក្រោកឈរឡើងដើម្បីប្រជាជនរបស់គាត់មែន ។ គាត់បាននិយាយ ជាពិសេសចំពោះក្រុមហ៊ុនប្រេងឥន្ធនៈរបស់ចក្រភពអង់គ្លេសថា ប្រសិនបើអ្នកមកទីនេះ អ្នកត្រូវផ្តល់នូវចំណែកយ៉ាងយុត្តិធម៌ដល់ប្រជាជនរបស់យើង ។ ក្រុមហ៊ុនប្រេងឥន្ធនៈមានការអាក់អន់ចិត្តយ៉ាងខ្លាំង ដូច្នេះសហរដ្ឋអាមេរិកបានធ្វើការសំរេចចិត្តថានឹងលូកដៃចូល ហើយធ្វើអ្វីមួយចំពោះរឿងនេះ ។ នៅពេលនោះ យើងមានការតក់ស្លុតនឹងសង្រ្គាមអាវុធនុយក្លេអ៊ែ ។ ប្រទេសរុស្ស៊ីជាសត្រូវក្រោយសង្រ្គាមលោកលើកទីពីរហើយអ៊ីរ៉ង់ គឺនៅជាប់នឹងព្រំប្រទល់រុស្ស៊ី ។ ដូច្នេះ យើងមិនហ៊ានបញ្ជូនទាហ៊ានទៅកំចាត់ Mossadeq ទេ ម្យ៉ាងទៀតគាត់ជាប្រធានាធិបតីដែលជ្រើសតាំងដោយប្រជាធិបតេយ្យ ត្រូវបានចាត់ទុកជាអ្នកដឹកនាំគំរូ ប៉ុន្តែយើងបានសំរេចចិត្តហើយថាយើងត្រូវតែកំចាត់គាត់ចោល ព្រោះគាត់កំពុងតែរារាំងដំណើរការក្រុមហ៊ុនប្រេងឥន្ធនៈ ។ ជំនួសឱ្យការបញ្ជូនកងទ័ព យើងបានបញ្ជូន Kermit Roosevelt ដែលជាភ្នាក់ងារ ស៊ី-អាយ-អេ ម្នាក់ដែលជាចៅប្រុសរបស់លោក Teddy ហើយយើងបានបញ្ជូនគាត់ទៅជាមួយនឹងប្រាក់ ២-៣ លានដុល្លា ហើយគាត់បានចាត់ចែងបង្កើតឱ្យមានភាពចលាចល ការតវ៉ា ការវិនាសអន្តរាយ និងធ្វើឱ្យរឿងធំឱ្យក្លាយជារឿងតូច គាត់បានផ្តល់រំលំ

នាយករដ្ឋមន្ត្រី Mossadeq ហើយនាំ Shah មកកាន់អំណាចវិញ ។ យើងទាំងអស់គ្នាបានដឹងអំពី Shah ។ ដូច្នេះខ្ញុំបានត្រឡប់មកប្រទេសនេះវិញ កន្លែងដែលអ្នកវាយលុកសេដ្ឋកិច្ចបានចាប់ផ្តើមធ្វើការ ។ ម្យ៉ាងវិញទៀត មេរៀនមួយក្នុងចំណោមមេរៀនជាច្រើនដែលយើងបានសិក្សាពី Kermit Rossevelt គឺគាត់ជាភ្នាក់ងារ ស៊ី-អាយ-អេ ម្នាក់របស់មន្ត្រីរដ្ឋាភិបាល ។ បើសិនជាគេរកឃើញពីអត្តសញ្ញាណរបស់គាត់ រដ្ឋាភិបាលនឹងត្រូវស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ។ ដូច្នេះ មិនយូរប៉ុន្មាន ក៏មានសេចក្តីសំរេចមួយថា អ្នកវាយលុកសេដ្ឋកិច្ចត្រូវតែបានជួលដោយក្រុមហ៊ុនឯកជន ។ NSA និងស៊ី-អាយ-អេ អាចស្គាល់សញ្ញាណពួកយើង អាចរៀបចំការសាកល្បងគ្រប់បែបយ៉ាងមកលើពួកយើង អាចទាក់យើងបាន ប៉ុន្តែនៅទីបញ្ចប់ យើងត្រូវតែធ្វើការឱ្យក្រុមហ៊ុនឯកជន ដូច្នេះហើយប្រសិនបើ យើងត្រូវបានចាប់ខ្លួនបាន វានឹងធ្វើឱ្យរាំងស្ទះដល់ភាពលោភលន់របស់សាជីវកម្មជាជាងគោលនយោបាយរបស់រដ្ឋាភិបាល ។

AMY GOODMAN: អាចប្រកែកបាន ។ ដូច្នេះ Kermit Roosevelt ចាកចេញពីប្រទេសអ៊ីរ៉ង់ នៅពេលដែល Mossadeq ធ្លាក់ពីតំណែងក្នុងឆ្នាំ ១៩៥៣ ដែលនៅបន្តប្រាប់ប្រជាជនអ៊ីរ៉ង់អស់រយៈពេល ៥0 ឆ្នាំ បន្តមកទៀតចំពោះអត្តចរិតរបស់ពួកគេមកលើសហរដ្ឋអាមេរិក ក៏ប៉ុន្តែមានប្រជាជនអាមេរិកតិចតួចប៉ុណ្ណោះដែលដឹងពីបញ្ហានេះ ។ ចេញពីប្រទេសអ៊ីរ៉ង់ គាត់ត្រូវបានផ្តល់ការងារមួយនៅប្រទេសហ្គាតាម៉ាឡាមួយឆ្នាំក្រោយមក ដើម្បីជួយដល់ការផ្តួលរំលំលោក Arbenz ដោយបងប្អូនប្រុសរបស់ Dulles តែគាត់បដិសេធន៍ ។ ប៉ុន្តែរឿងនោះវានៅតែកើតឡើង ។ នៅឆ្នាំបន្ទាប់ រដ្ឋប្រហារបន្ទាប់គឺត្រូវបានផ្តួលរំលំដោយ United Fruit និងក្រុម ស៊ី-អាយ-អេ របស់ Arbenz នៅប្រទេសហ្គាតាម៉ាឡា ដូច្នេះគំរូនេះបានផ្តើមអនុវត្តន៍ ។

JOHN PERKINS: គំរូបានចាប់ផ្តើម និងបានបន្តការលូតលាស់យ៉ាងសម្បើម ។ នៅពេលដែលខ្ញុំបានទៅដល់អ៊ីរ៉ង់នៅដើមទសវត្សឆ្នាំ១៩៧0 បន្ទាប់ពីប្រទេសឥណ្ឌូនេស៊ី កិច្ចការបន្ទាប់របស់ខ្ញុំគឺទៅកាន់ប្រទេសប៉ាណាម៉ា ហើយបន្ទាប់គឺត្រឡប់មកគឺអ៊ីរ៉ង់វិញ ។ ខ្ញុំបានធ្វើការក្រោមការដឹកនាំរបស់ Shah និង--

AMY GOODMAN: នៅពេលលោកនិយាយថា អ្នករាល់គ្នាដឹងនូវអ្វីដែលបានកើតឡើងនៅទីនោះ ខ្ញុំមិនចាត់ទុកវាជាបានការទេ ។ អ្វីដែលបានកើតឡើងនៅអ៊ីរ៉ង់នៅក្រោមការដឹកនាំរបស់ Shah តើលោកអាចនិយាយពី SAVAK បានទេ?

JOHN PERKINS: មែនហើយ ។ នៅក្នុងសៀវភៅ ខ្ញុំបានធ្វើការពណ៌នាពីកិច្ចប្រជុំដែលខ្ញុំបានជួបជាមួយទីប្រឹក្សាជាន់ខ្ពស់ម្នាក់របស់ Shah ដែលបានទទួលរងទារុណកម្មពី SAVAK ហើយងាកទៅប្រឆាំងនឹង Shah ។ ប្រទេសអ៊ីរ៉ង់ជាប្រទេសសំខាន់សំរាប់យើង ។ ទីតាំងរបស់វាសំខាន់ណាស់ព្រោះវាជាប់នឹងព្រំប្រទល់ប្រទេសរុស្ស៊ី ។ ប្រទេសនេះមានប្រេងច្រើនទៀតផង ហើយយើងត្រូវការគ្រប់គ្រប់ប្រេង ។ យើងត្រូវការគ្រប់គ្រងប្រេងទាំងអស់នៅមជ្ឈិម

បូព៌ាយ៉ាងខ្លាំង ។ យើងមើលឃើញថា Shah គឺជាមនុស្សតែម្នាក់ដែលអាចធ្វើឱ្យរឿងដែលយើងចង់ធ្វើកើតឡើង ។ ក្រុមគ្រួសាររបស់ Shah លោកដឹងទេ ផែនការនោះគឺថា គ្រួសារ Shah នឹងអាចជួយយើងឱ្យកាន់កាប់ប្រទេសផ្សេងទៀតដែលនៅសេសសល់នៅមជ្ឈិមបូព៌ាបានរាប់បញ្ចូលទាំងស៊ីរីយ៉ា និងអ៊ីរ៉ាក់ ហើយយើងទាំងអស់គ្នាដឹងថាមានសង្គ្រាមកើតឡើងរវាង អ៊ីរ៉ាក់ និងអ៊ីរ៉ង់នាពេលក្រោយមក ។ ប៉ុន្តែចាប់តាំងពីតំបូងបង្អស់ យើងមានគំនិតចង់ក្លាយជាសម្ពន្ធ័មិត្តជាមួយនឹងគ្រួសារShah ។ យើងធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើបានដើម្បីគាំទ្រលោកដល់ការឡើងកាន់អំណាច ។ ទន្ទឹមនឹងនោះយើងបានដឹងថា លោកមានថវិកាយ៉ាងច្រើនដែលបានមកពីប្រេងឥន្ធនៈ ដូច្នេះហើយក្រុមហ៊ុនរបស់យើងនឹងទទួលបានផលប្រយោជន៍យ៉ាងច្រើនសម្បើម ។ ជាថ្មីម្តងទៀត ក្រុមហ៊ុនវិស្វកម្មទាំងឡាយ ដែលយើងបាននិយាយពីមុនមករួមទាំងក្រុមហ៊ុនរបស់ខ្លួនខ្ញុំផ្ទាល់ គឺក្រុមហ៊ុន Charles T. Main, Bechtel និង Halliburton និងក្រុមហ៊ុនផ្សេងទៀតដែលនៅក្នុងប្រទេសអ៊ីរ៉ង់ដើម្បីកសាងទីក្រុងនានា ស្ថាបនារោងចក្រដ៏ខ្លាំងក្លា ស្ថាបនាផ្លូវធំៗ ដែលពួកគេកាន់តែមានទៅៗ និងបង្កើតឱ្យមានអ្នកកាន់សាសនាម៉ូស្លីមយ៉ាងច្រើននៅជុំវិញពិភពលោក ប្រជាជនអ៊ីរ៉ង់មិនមែនជាជនជាតិអារ៉ាប់ទេ ប៉ុន្តែពួកគេកាន់សាសនាម៉ូស្លីម ហើយពួកគេគឺជាអ្នកដែលរស់នៅមជ្ឈិមបូព៌ា ។ យើងបានធ្វើឱ្យប្រជាជនយ៉ាងច្រើនអស្ចារ្យមានការខឹងសម្បារ ។ ទោះបីជាមកដល់ថ្ងៃនេះក៏ដោយ អូសាម៉ាប៊ីនឡាដេន បានលើកហេតុផលពីអ្វីដែលបានកើតឡើងជាមួយនឹងគ្រួសារ Shah ថា តើយើងបានផ្តួលរំលំ Mossadeq ដោយរបៀបណា និងលើក Shah មកជំនួសដែលជាមូលហេតុមួយនៃកំហឹងរបស់គាត់ ។

AMY GOODMAN: ដូច្នេះ Mossadeq បានចេញមកនិយាយបន្ទាប់ពីក្រុមហ៊ុន Anglo American ដោយត្រឹមតែនិយាយថា នេះគឺជាប្រេងរបស់យើង ហើយយើងគួរតែត្រួតត្រាវា ។ ក្រុមហ៊ុន Anglo American រដ្ឋាភិបាលអង់គ្លេសមិនអនុញ្ញាតិឱ្យជនជាតិអ៊ីរ៉ង់ណាម្នាក់ធ្វើជាម្ចាស់កម្មសិទ្ធិឡើយ ប៉ុន្តែធ្វើការបង្ខិតបង្ខំ ហើយជាថៃ្ងដន្យ ក្រុមហ៊ុន Anglo American ក៏ក្លាយជាក្រុមហ៊ុនប្រេងអង់គ្លេស B.P ។

JOHN PERKINS: ត្រឹមត្រូវហើយ ។ នៅពេលនោះខ្ញុំជឿថា តួលេខនោះគឺថា រាល់ប្រាក់មួយដុល្លានៃប្រេងដែលបូមចេញពីប្រទេសអ៊ីរ៉ង់ ៨៥សេន ត្រូវហូរចូលទៅក្រុមហ៊ុន Anglo American ឬក្រុមហ៊ុនប្រេងអង់គ្លេស B.P ។ ជាការពិតណាស់លោក Mossadeq មានការខឹងសម្បារដោយសារតែរឿងនេះ ដូចដែលគាត់គួរតែខឹង ។ គ្មានហេតុផលណាមួយដែលថា ហេតុអ្វីបានជាប្រជាជនដែលជាអ្នកគ្រប់គ្រងលើធនធាន ដីធ្លីរបស់ពួកគេត្រូវជីកគាស់ដើម្បីបូមយកធនធានប្រេងនេះ ហើយមិនគួរទទួលបានចំណែកដ៏ធំរបស់សត្វតោដែលពួកគេត្រូវទទួលបាន ហើយនោះគឺជាអ្វីដែលលោក Mossadeq បានប្រយុទ្ធប្រឆាំងដើម្បីទាមទារ ដូចជាលោក Torrijos បានធ្វើមួយរយៈពេលក្រោយដូច

លោក Arbenz បានធ្វើនៅប្រទេសហ្គាតាម៉ាឡា (ដែលលោកបានលើកឡើង) ដូចលោក Allende បានធ្វើនៅក្នុងប្រទេសឈីលី ។

AMY GOODMAN: ប្រសិនបើខ្ញុំចាំច្បាស់ Truman បានបដិសេធក្នុងការចូលជាមួយរឿងនេះ ប៉ុន្តែក្រោយមកលោក Eisenhower បានចូលមក ហើយសំរេចចិត្តជួយគាំទ្រអង់គ្លេសលើរឿងនេះ ។

JOHN PERKINS: វាត្រឹមត្រូវហើយ ។ លោក Truman មានជំហរយ៉ាងស្មោះត្រង់ ។ គាត់បាននិយាយថាយើងនឹងមិនចូលលាយឡំនៅក្នុងកិច្ចការនេះទេ ។ លោក Mossadeq គឺជាប្រធានាធិបតីដែលទទួលការបោះឆ្នោតជ្រើសតាំងជាលក្ខណៈប្រជាធិបតេយ្យ ហើយគាត់កំពុងតែធ្វើអ្វីដែលគាត់ធ្វើ ហើយយើងមិនឈានជើងចូលទៅខាងផ្នែកឧស្សាហកម្មឯកជនទេ ។ ប៉ុន្តែមួយរយៈពេលយ៉ាងខ្លីក្រោយមក គាត់បានចេញទៅក្រៅការិយាល័យ ហើយលោក Eisenhower បានចូលមកការិយាល័យធ្វើតាមគំរោងរបស់ ស៊ី-អាយ-អេ ដើម្បីទម្លាក់លោក Mossadeq ចោល ហើយលើក Shah ដាក់ជំនួសវិញ ។

AMY GOODMAN: ប្រេងគឺជាប្រភពនៃការរងទុក្ខវេទនាយ៉ាងខ្លាំង ។

JOHN PERKINS: អូ លោកដឹងទេថា គ្រប់ប្រទេសនៅក្នុងពិភពលោកដែលមានការផ្គត់ផ្គង់ផ្នែកប្រេងចំបងបង្អស់ គ្រប់ប្រទេសតតិយៈលោក ប្រទេសខ្លះទៀតមិនមែនជាអ្នកផ្គត់ផ្គង់ចំបងទៀតទេ ដូចជាប្រទេស អារ៉ាប៊ីសាអូឌីត បានទទួលរងគ្រោះ ។ ប្រេងមិនមែនជាផលប្រយោជន៍សំរាប់ប្រទេសទាំងនេះទេ ។ វាផ្តល់ផលប្រយោជន៍សំរាប់មនុស្សដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភប៉ុន្មាននាក់ ដែលមានឋានៈខ្ពស់នៅចុងកំពូលនៃបង្គោលសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងនោះតែប៉ុណ្ណោះ ។ ប៉ុន្តែសំរាប់អ្នកផ្សេងទៀតនោះ វាគឺជាបណ្តាសារ ។ ប្រេងគឺជាបណ្តាសាររបស់ពិភពលោក ។ វាប្រហែលជាបណ្តាសារដ៏ខ្លាំងបំផុតដែលពិភពលោកធ្លាប់ជួបប្រទះ ។ វាបានបំផ្លាញបរិស្ថានរបស់យើង វាបានបំផ្លាញសេដ្ឋកិច្ចពិភពលោកជាច្រើន វាបានបំផ្លាញជនជាតិភាគតិចយ៉ាងច្រើនដែលទទួលរងគ្រោះដោយការថប់ដង្ហើមស្លាប់ពីលទ្ធផលនៃឧស្ម័នកាបូនឌីអុកស៊ីតដែលប្រេងបានបង្កើតឡើង ។ វាអស្ចារ្យយ៉ាងខ្លាំង ។ តើវាមិនអស្ចារ្យទេឬ Amy នៅពេលដែលប្រធានាធិបតី ប៊ូស ទី១ បានចូលទៅប្រទេសអ៊ីរ៉ាក់នៅឆ្នាំ ១៩៩០ យើងបាននាំចូលប្រេងប្រហែល ៨ លាន ធុងក្នុងមួយថ្ងៃ ។ នៅពេលដែលប្រធានាធិបតី ប៊ូស ទី២ ចូលទៅការនាំចូលប្រេងបានកើនឡើងពី ១២ លាន ធុង ទៅ ៥០% ក្នុងមួយថ្ងៃ ។ នៅក្នុងរយៈពេលនោះ ការនាំចូលរបស់យើងបានកើនឡើង ។

AMY GOODMAN: យើងកំពុងតែនិយាយជាមួយលោក John Perkins ។ លោកគឺអ្នកនិពន្ធសៀវភៅ *ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* ។ យើងកំពុងជជែកអំពី ប្រេង ចក្រពត្តិ អ្វីដែលលោកហៅថាក្រុមហ៊ុន

សាជីវកម្ម ហើយនឹងការក្លាយជាអ្នកវាយលុកសេដ្ឋកិច្ចម្នាក់ ។ ដូច្នេះលោកបានចូលរួមនៅក្នុងប្រទេសអ៊ីរ៉ង់ ។ លោកក៏បានជាប់នៅក្នុងប្រទេស អារ៉ាប៊ីសាអូឌីត ដែរ ។ សូមលោកជួយពន្យល់ ។

JOHN PERKINS: អឺ... ប្រទេសអារ៉ាប៊ីសាអូឌីតប្រហែលជា--មិនមែនប្រហែលជាទេ--គ្មានសំណួរទេ វាគឺជាជោគជ័យដ៏ធំធេងសំរាប់យើងដែលជាអ្នកវាយលុកសេដ្ឋកិច្ច ។ ខ្ញុំមានន័យថា នោះគឺជាការវិនិច្ឆ័យដោយខ្លួនឯង ។ នៅដើមទសវត្សឆ្នាំ ១៩៧០ អង្គការ OPEC ពិតជាបានតំឡើងសាច់ដុំរបស់ខ្លួន ។ គេមិនចូលចិត្តគោលនយោបាយនានារបស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសអ៊ីស្រាអែល ជួយគាំទ្រអ៊ីស្រាអែល ហើយបានសំរេចចិត្តថា នឹងធ្វើអ្វីមួយអំពីរឿងនេះ ។ ដូច្នេះអង្គការនេះបានបញ្ឈប់ការផលិតប្រេងដែលមានសារៈសំខាន់ ។ ជាលទ្ធផល សេដ្ឋកិច្ចអាមេរិកបានធ្លាក់ចូលប្រៀបដូចការរលាស់កន្ទុយ ។ មានរថយន្តតំរង់ជួរយ៉ាងវែងនៅស្ថានីយ៍ប្រេងឥន្ធនៈ ពួកយើងច្រើននាក់នៅតែចងចាំរឿងនោះ ។ យើងខ្លាចថា វានឹងមានការផ្ទុះឡើងដូចនៅឆ្នាំ ១៩២៩ ដោយសារតែលទ្ធផលរបស់អង្គការ OPEC ដូច្នេះហើយ នាយកដ្ឋានរតនាគារបានមកជួបខ្ញុំនិងអ្នកវាយលុកសេដ្ឋកិច្ចដទៃទៀត ហើយនិយាយថា បញ្ហានេះមិនអាចកើតឡើងទៀតបានទេ ។ អ្នកត្រូវតែបង្កើតផែនការមួយ ។ តើអ្នកនឹងធ្វើអ្វីចំពោះបញ្ហានេះ? តើអ្នកនឹងធ្វើដូចម្តេចដើម្បីឱ្យប្រាកដថា រឿងនេះវានឹងមិនកើតឡើងម្តងទៀត? យើងបានដឹងថា គន្លឹះរបស់វាគឺប្រទេស អារ៉ាប៊ីសាអូឌីត ។ ចំពោះវត្ថុមួយគឺប្រេង ប្រទេសនេះមានច្រើនជាងប្រទេសដទៃទៀត ។ ទោះបីជានៅត្រង់ចំណុចនេះនៅពេលនោះក៏ដោយគ្រួសារ Shah កំពុងតែមានការរង្គោះរង្គើបន្តិចបន្តួច ហើយយើងបានឃើញថា លោកប្រហែលជានឹងមិនកាន់កាប់អ្វីដែលសេសសល់ទាំងអស់នៅមជ្ឈឹមបូព៌ាទេ ។ យើងដឹងថា ដំណាក់របស់ Saud គ្រួសារព្រះរាជវង្សរបស់សាអូឌីត អាចសូកប៉ាន់ឱ្យពុករលួយបាន ។ ឥឡូវពួកគេពុករលួយ ហើយពួកគេអាចសូកប៉ាន់ឱ្យពុករលួយបាន ។ ដូច្នេះដើម្បីធ្វើឱ្យរឿងវែងនេះក្លាយជារឿងខ្លី យើងទាំងអស់គ្នាដាក់នូវការបែងចែកនេះដែលពួកគេ យល់ព្រមឱ្យក្រុមរាជវង្ស Saud ដើម្បីបញ្ជូនប្រាក់ដុល្លាដែលបានពីប្រេងដ៏ច្រើនរបស់ពួកគេ (ប្រាក់ដែលយើងបង់ថ្លៃប្រេង) ឱ្យចូលទៅសហរដ្ឋអាមេរិកវិញ ហើយវិនិយោគនៅក្នុងវិស័យសន្តិសុខ ។ ការប្រាក់ពីវិស័យសន្តិសុខទាំងនេះនឹងបែងចែកដោយនាយកដ្ឋានរតនាគារទៅកាន់ក្រុមហ៊ុនវិស្វកម្មសំណង់សហរដ្ឋអាមេរិកដើម្បីសាងសង់ប្រទេសអារ៉ាប៊ីសាអូឌីត នៅក្នុងស្រមោលលោកខាងលិច ដើម្បីសាងសង់ទីក្រុងធំៗជាច្រើនលើតំបន់សមុទ្រខ្សាច់ដែលយើងបានធ្វើរួច ហើយរោងចក្រថាមពល មហាវិថីធំៗ ក្រុមហ៊ុន McDonald’s ការងារទាំងមូល ដើម្បីធ្វើឱ្យប្រទេស អារ៉ាប៊ីសាអូឌីត ក្លាយជាបស្ចឹមប្រទេស ។ ហើយដំណាក់របស់ Saud នឹងធានារក្សាតំលៃប្រេងនៅត្រឹមតំលៃកំណត់មួយដែលអាចទទួលយកបាន ការកំណត់ដែលយើងអាចទទួលយកបាន ហើយយើងនឹងធានារក្សាដំណាក់របស់ Saud ឱ្យមានអំណាច ។ យើងបានធ្វើរឿងទាំងអស់នោះរហូតមក ចាប់តាំងពីដើមឆ្នាំ ១៩៧០ ។ គោលនយោបាយនៅតែប្រកាន់ខ្ជាប់ ។ ទោះបីជានៅក្នុងចំណុចមួយដែលលោកដឹងទេ ទោះបីជាយើងដឹងថាដំណាក់របស់ Saud គាំទ្រអូសាម៉ាប៊ីនឡាដេន បានគាំទ្រគាត់

ដោយការលើកទឹកចិត្តរបស់ពួកយើងពិតប្រាកដណាស់ នៅប្រទេសអាហ្គានីស្ថាននៅតែបន្តគាំទ្រគាត់និងចលនាភាវរជននានាជាច្រើន ។ យើងបានដឹងថា ដំណាក់របស់ Saud បានផ្តល់កន្លែងសម្ងាត់ដល់ Edie Amin ដែលជាអ៊ីត្លែរបស់អាហ្វ្រិក។ ការពិត នោះជាកន្លែងដែលគាត់បានចំណាយពេលប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតរបស់គាត់រស់នៅក្នុងគេហដ្ឋានមួយ ហើយទើបតែទទួលមរណៈភាពនៅទីនោះជាងមួយឆ្នាំកន្លងទៅ ។ យើងបានគាំទ្រដំណាក់របស់ Saud រហូតមកគ្រប់រឿងទាំងអស់នេះក្រៅពីអ្វីដែលពួកគេបានធ្វើនូវរឿងរ៉ាវជាច្រើនដែលពួកយើងមិនយល់ព្រមជាមួយ ។ ប៉ុន្តែពួកគេបានផ្តល់ដល់យើងនូវស្ថេរភាពនៃតំលៃប្រេងទាំងនេះ និងទីផ្សារដ៏ធំសម្បើមសំរាប់ក្រុមហ៊ុនវិស្វកកម្មសំណង់នានារបស់ពួកយើង ។

AMY GOODMAN: តើការចូលរួមផ្ទាល់ខ្លួនរបស់លោកនៅទីនោះគឺអ្វីដែរ?

JONH PERKINS: បាត គឺខ្ញុំបានធ្វើគ្រោងការណ៍ ខ្ញុំគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលបានធ្វើគ្រោងការណ៍នេះ ។ ខ្ញុំចូលចិត្តគិតថា ខ្ញុំគឺជាមនុស្សម្នាក់ក្នុងចំណោម--ខ្ញុំគឺជាមនុស្សដំបូងគេដែលបានធ្វើឱ្យគ្រោងការណ៍ហើយក៏អាចធ្វើទៅបានដែរ ។ ប៉ុន្តែមានមនុស្សមួយចំនួនប៉ុណ្ណោះដែលបានចូលរួម ។ ហើយបន្ទាប់មក ពួកយើងក៏បញ្ជូនបេសកជនទៅអារ៉ាប់ប៊ីសាអូឌីត--ខ្ញុំមិនដែលត្រូវគេប្រាប់ជាផ្លូវការណ៍ថា អ្នកណាជាអ្នកដែលត្រូវទៅនោះទេ តែខ្ញុំជឿជាក់យ៉ាងវិជ្ជមានថា អ្នកដែលធ្វើបាននោះគឺលោក Henry Kissinger--ដើម្បីបញ្ចុះបញ្ចូល ដំណាក់ Saud ឱ្យយល់ព្រមទទួលយកគំរោងរបស់យើង ។

AMY GOODMAN: តើអ្វីទៅដែលធ្វើឱ្យលោកគិតថា គឺជារូបគាត់?

JONH PERKINS: នោះគឺព្រោះតែការងារដែលគាត់បានធ្វើក្នុងពេលនោះ ហើយក្នុងពេលនោះ គាត់បានបាត់មុខពីកញ្ចក់ទូរទស្សន៍នានាមួយរយៈនិងរឿងរ៉ាវផ្សេងៗទៀត ហើយគាត់ក៏ជាប្រភេទមនុស្សម្នាក់ដែលនឹងធ្វើរឿងបែបនេះ។ ក្នុងករណីណាក៏ដោយ ពតិមានដែលត្រឡប់មកដល់ខ្ញុំវិញគឺថា ដំណាក់របស់ Saud បានយល់ព្រមលើគំរោងរបស់យើង ប៉ុន្តែឥឡូវនេះមានព្រះអង្គម្ចាស់មួយចំនួនត្រូវតែបញ្ចុះបញ្ចូល ព្រោះបើទោះជានៅប្រទេសអារ៉ាប់ប៊ីសាអូឌីតមិនមែនជាប្រទេសប្រជាធិបតេយ្យក៏ដោយ ថ្មីៗនេះមានការកើតនៃការសំរេចចិត្តបែបប្រជាធិបតេយ្យនៅក្នុងរាជ្យវង្សនេះ ។ ដូច្នេះ ខ្ញុំត្រូវបានគេចាត់តាំងឱ្យទៅធ្វើការទាក់ទងព្រះអង្គម្ចាស់មួយអង្គក្នុងចំណោមព្រះអង្គម្ចាស់ទាំងនោះហើយខ្ញុំតែងនាំទ្រង់ឱ្យមកជិតខ្ញុំ ។ ព្រះអង្គម្ចាស់នេះជាអ្នកដែលប្រកាន់គំនិតអភិរក្សនិយមយ៉ាងតឹងរឹង ទ្រង់មានព្រះនាមថា Wahabi ទ្រង់ពិតជាមិនចង់ឃើញប្រទេសរបស់ខ្លួនប្រែទៅជាបស្ចិមប្រទេសឡើយ ។ ទ្រង់បានឃើញព្រឹត្តិការណ៍នេះកំពុងតែមកដល់ ។ ដូច្នេះហើយខ្ញុំបានដឹងថា ការងាររបស់ខ្ញុំគឺត្រូវជំនះឧបសគ្គខ្លាំងណាស់ ។ ទ្រង់បានធ្វើឱ្យខ្ញុំមានភាព

ងាយស្រួលបន្តិចពីព្រោះតាំងពីដំបូងទ្រង់បានប្រាប់ឱ្យខ្ញុំដឹងថា រៀងរាល់ពេលដែលទ្រង់មកបូស្តុន ឬពេលដែលខ្ញុំបានទៅជួបទ្រង់នៅទីក្រុងញូយក ឬទីក្រុងវ៉ាស៊ីងតោន ទ្រង់តែងតែសង្ឃឹមថានឹងមានដៃគូរម្នាក់ គឺនារីមួយរូបដែលមានសក់ពណ៌ទង់ដែង ភ្នែកពណ៌ខៀវដ៏ស្រស់ស្អាត ។ ទ្រង់បានពិពណ៌នាយ៉ាងក្បោះក្បាយនូវអ្វីដែលទ្រង់កំពុងតែស្វែងរក ហើយប្រសិនបើខ្ញុំមិនអាចផ្តល់ឱ្យទ្រង់នូវរបស់ទាំងនេះទេ ខ្ញុំគួរតែបំភ្លេចនូវការប្រជុំនានាដែលត្រូវពិភាក្សាជាមួយទ្រង់ ។ វាក៏ជាសំណាងល្អដែលខ្ញុំបានជួបជាមួយនឹងស្ត្រីម្នាក់ដែលបានរៀបការជាមួយអាកាសយានិកអាមេរិកម្នាក់ ដែលអាពាហ៍ពិពាហ៍នេះមានភាពចូលរួមសប្បាយហ៊ឺហាកាលពីប៉ុន្មានឆ្នាំមុននេះ តែនាងមិនសប្បាយចិត្តនឹងប្តីនាងដែលតែងតែមានរឿងរ៉ាវស្នេហាជាមួយនឹងស្ត្រីខាងក្រៅជាច្រើន ហើយនាងបានប្រាប់ខ្ញុំថា នាងចង់បានលុយក្រៅបន្តិចបន្តួចបន្ថែម ។ ខ្ញុំនឹងធ្វើរឿងនេះបើសិនជាខ្ញុំចូលចិត្តបុរសនោះ ។ ជាភ័ព្វសំណាងរបស់ខ្ញុំ ដែលនាងចូលចិត្តទ្រង់ ។ AMY តើលោកដឹងទេ នេះគឺជារឿងមួយក្នុងចំណោមរឿងមិនស្របច្បាប់មួយចំនួនដែលខ្ញុំបានធ្វើ ។ ការងាររបស់ខ្ញុំជាច្រើនក្នុងនាមជាអ្នកវាយលុកសេដ្ឋកិច្ច ខ្ញុំប្រកាសយ៉ាងដាច់អហង្កាថា ជាការងារស្របច្បាប់ ។ វាមិនសមថាជារឿងស្របច្បាប់ឡើយ ពីអ្វីដែលពួកយើងបានធ្វើទៅលើប្រទេសជាច្រើន ប៉ុន្តែវាគឺស្របច្បាប់ ។ ការរកស្រីមកឱ្យមនុស្សដទៃមិនមែនជារឿងស្របច្បាប់នោះទេ ។ នៅពេលនោះ ខ្ញុំក៏រកបានស្រីនៅក្នុងរដ្ឋ Massachusetts ហើយវិធីដែលខ្ញុំអាចបង់លុយលើសេវាកម្មទាំងនេះបាន គឺដោយផ្អែកទៅលើខ្ទង់ចំណាយបន្ថែមរបស់ខ្ញុំ ហើយនេះក៏ជារឿងមិនស្របច្បាប់ដែរ ។ ដូច្នេះខ្ញុំបានលាតត្រដាងរឿងស្របច្បាប់នៅទីនេះ ហើយខ្ញុំសង្ឃឹមថា យើងនឹងអាចរួចផុតពីព្រំដែននៃបទឧក្រិដ្ឋទាំងនេះ ។ ខ្ញុំគិតថា ពួកយើងពិតជាអាចគេចរួច ។

AMY GOODMAN: អញ្ចឹង តើមានអ្វីកើតឡើងចំពោះរឿងនេះ?

JONH PERKINS: ជាយថាហេតុ ព្រះអង្គម្ចាស់នោះពេញចិត្តនឹងស្រីដែលមានភ្នែកពណ៌ខៀវសក់ទង់ដែងម្នាក់នោះខ្លាំងណាស់ នាងឈ្មោះ សាលី ហើយមកដល់ពេលមួយ ទ្រង់ចង់ឱ្យនាងទៅរស់នៅជាមួយទ្រង់ឯផ្ទះតូចមួយនៅឧបទ្វីបអារ៉ាប់ ដែលការពិតនោះគឺជាវិមានដ៏ធំមួយ ។ បញ្ហានេះបានធ្វើឱ្យខ្ញុំព្រួយបារម្ភយ៉ាងខ្លាំង ព្រោះខ្ញុំដឹងថា នាងនឹងមិនយល់ស្របតាមសំណើរនេះឡើយ ហើយខ្ញុំក៏គ្មានលទ្ធភាពចេញសោហ៊ុយទាំងអស់នោះដែរ ។ ប៉ុន្តែថៃដន្យយើងអាចដោះស្រាយបញ្ហានេះបានដោយយើងបានរៀបចំឱ្យទ្រង់នូវនារីដែលមានភ្នែកពណ៌ខៀវសក់ពណ៌ទង់ដែងម្នាក់ទៀត មកពីប្រទេសមួយរបស់ Scandinavia (ដូចជាដាណឺម៉ាក ណ័រវេ ស៊ុយអែត) ។ នៅពេលនោះ មានការជួញដូរស្ត្រីស្បែកសយ៉ាងច្រើនទៅកាន់តំបន់មជ្ឈិមបូពា ហើយយើងបានរៀបចំរឿងនោះសំរាប់ទ្រង់ ។ ព្រះអង្គម្ចាស់នោះសប្បាយព្រះទ័យឡើងវិញ ហើយទ្រង់ក៏យល់ព្រមនឹងគំរោងដែលយើងចង់បាន ។ ទ្រង់បានគាំទ្រក្នុងរឿងនេះ ។ ដំណាក់របស់ Saud គាំទ្រទាំងស្រុងលើគំរោងនេះ បន្ទាប់មកវាក៏ឈានទៅដល់គោលដៅ ។

AMY GOODMAN: យើងកំពុងតែជជែកជាមួយលោក Jonh Perkins ។ សៀវភៅរបស់គាត់មានចំណងជើងថា *ការសារភាពរបស់អ្នកសេដ្ឋកិច្ចម្នាក់*។ (*សំរាក*)

AMY GOODMAN: ដោយសារតែយើងបានឈានចូលមកដល់វគ្គចុងក្រោយនៃការសំភាសន៍របស់យើងជាមួយលោក Jonh Perkins ស្នាដៃរបស់គាត់គឺ*ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* ។ លោកធ្លាប់ជាប្រធានសេដ្ឋកិច្ចវិទូរបស់ក្រុមហ៊ុនអន្តរជាតិប្រឹក្សាយោបល់ក្នុងរដ្ឋ Massachusetts មានឈ្មោះថា Main ។ លោកបានធ្វើការទាក់ទងនៅប្រទេសឥណ្ឌូនេស៊ី អ៊ីរ៉ង់ អារ៉ាប់ប៊ីសាអូឌីត បានធ្វើដំណើរទៅប្រទេសអេក្វាឌ័រ ប៉ាណាម៉ា និងប្រទេសជាច្រើនទៀតផងដែរ ។ ការទាក់ទងនេះប្រាប់យើងឱ្យបានដឹងពីរឿងដ៏អស្ចារ្យមួយអំពីទំនាក់ទំនងរវាងក្រុមហ៊ុនអន្តរជាតិប្រឹក្សាយោបល់ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិនានា ដូចជាធនាគារពិភពលោកជាដើម ។ លោកបានព្យាយាមសរសេរសៀវភៅនេះអស់ជាច្រើនទស្សវត្សមកហើយ ។ តើមានអ្វីកើតឡើង?

JONH PERKINS: មែនហើយ អ្វីដែលខ្ញុំបានធ្វើ គឺវាតែងតែបានរំខានមនសិការរបស់ខ្ញុំ ហើយខ្ញុំពិតជាចង់បង្ហាញរឿងនោះឱ្យមនុស្សគ្រប់គ្នាបានដឹងព្រោះខ្ញុំមិនចូលចិត្តរឿងរ៉ាវដែលកំពុងតែកើតឡើងនៅក្នុងពិភពលោក និងអ្វីដែលខ្ញុំមើលឃើញប្រទេសរបស់ខ្ញុំកំពុងតែធ្វើ ។ ខ្ញុំជាមនុស្សមានភក្តីភាពជាមួយនឹងអាមេរិក ហើយខ្ញុំមានជំនឿយ៉ាងមុតមាំទៅលើគោលការណ៍របស់ប្រទេសនេះ បិតាស្ថាបនាជាតិ ។ ពេលវេលាកន្លងផុតទៅ ខ្ញុំចាប់ផ្តើមមើលឃើញពីការបោកប្រាស់ដែលយើងកំពុងតែធ្វើទៅលើគោលការណ៍ទាំងនោះថា តើយើងបានធ្វើឱ្យខូចគោលការណ៍នោះដោយវិធីណា តើពួកយើងកំពុងតែបាត់បង់ញ្ញាណលើលទ្ធិប្រជាធិបតេយ្យស្ទើរតែទាំងស្រុងដោយរបៀបណា ហើយបែរជាក្លាយទៅជាប្រទេសមូលធននិយមដែលងាកទៅរកក្រុមហ៊ុនសាជីវកម្ម គឺជាអាណាចក្រដ៏មហិមា គឺជាប្រទេសចក្រពត្តិនិយម ។ ដូចនេះខ្ញុំ មានអារម្មណ៍ថា បើសិនជាខ្ញុំសរសេរអំពីរបៀបដែលរឿងរ៉ាវទាំងអស់នោះកើតឡើង ពីព្រោះពួកយើងបានបង្កើតឱ្យមានអធិរាជនេះឡើង ក្នុងវិធីសាស្ត្រមួយយ៉ាងប៉ិនប្រសប់ដែលអាចធ្វើទៅបាន ។ អាណាចក្រផ្សេងៗបានបង្កើតឡើងដោយកំលាំងទ័ព ហើយមនុស្សគ្រប់គ្នានៅក្នុងប្រទេសនោះសុទ្ធតែដឹងថា កងទ័ពរបស់ខ្លួនកំពុងតែចេញទៅដើម្បីច្បាំងយកអាណាចក្រ ។ ប៉ុន្តែ ចំពោះអធិរាជមួយនេះវិញបានធ្វើឡើងយ៉ាងប៉ិនប្រសប់ ដែលប្រជាជនអាមេរិកភាគច្រើនមិនដឹងថាមានអ្វីកំពុងតែកើតឡើងនោះឡើយ ។

AMY GOODMAN: បើទោះជាឥឡូវនេះ វាមិនសូវជាប៉ិនប្រសប់ដូចមុនក៏ដោយ ដែលជារឿងគួរឱ្យចាប់អារម្មណ៍យ៉ាងហោចណាស់ក៏ពីដំបូង វាគឺជាមូលហេតុដែលសាជីវកម្មអាមេរិកមួយចំនួនបានជំទាស់ទៅនឹងការឈ្លានពានលើប្រទេសអ៊ីរ៉ាក់ ពីព្រោះវាមិនសូវប៉ិនប្រសប់ទៀតឡើយ ។

JONH PERKINS: ត្រូវហើយ។ វាបានបង្ហាញចេញមកបន្តិចម្តងៗ ។ ហើយនោះប្រហែលជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដែលខ្ញុំអាចនិពន្ធសៀវភៅនេះឡើងបាន ។ ព្រោះថា នៅពេលដំបូងពេលដែលខ្ញុំចាប់ផ្តើមសរសេរ ពាក្យពេចន៍មួយចំនួននឹងលេចចេញមក ពីព្រោះខ្ញុំនឹងជួបនិយាយជាមួយមនុស្សដែលចូលរួមការងារជាមួយខ្ញុំ។ ខ្ញុំត្រូវការឱ្យពួកគេជួយរំលឹកការចងចាំរបស់ខ្ញុំលើបញ្ហាជាក់លាក់មួយចំនួន ។ ខ្ញុំចង់ទៅសំភាសន៍និងនិយាយជាមួយពួកគេពីបញ្ហានេះ ។ ដូច្នេះខ្ញុំនឹងទទួលនូវការគំរាមកំហែងដ៏អស្ចារ្យ ប៉ុន្តែសំខាន់បំផុតនោះគឺសំណូក ។ ដូច្នេះហើយនៅដើមទស្សវត្សឆ្នាំ ១៩៩០ ឧទាហរណ៍ដូចជាពេលដែលខ្ញុំបានចាប់ផ្តើមសរសេរសៀវភៅ *មនសិការរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* មានក្រុមហ៊ុនវិស្វកម្មធំមួយឈ្មោះសាជីវកម្ម Stoner-Webster ដែលមានទីតាំងនៅបូស្តុនដែរ បានមករកខ្ញុំហើយឱ្យប្រាក់សំណូកខ្ញុំប្រហែលជាកន្លះលានដុល្លាដើម្បីឱ្យខ្ញុំបិទមាត់ និងមិនសរសេរសៀវភៅ ហើយខ្ញុំក៏មិនចាំបាច់ធ្វើការងារអ្វីច្រើនដែរ ។ ខ្ញុំនឹងមានឈ្មោះក្នុងបញ្ជីរបស់ពួកគេ ។

AMY GOODMAN: ហេតុអ្វីបានជាសាជីវកម្ម Stoner-Webster ខ្វល់អំពីរឿងនេះ?

JONH PERKINS: ពីព្រោះពួកគេក៏រួមចំណែកយ៉ាងច្រើនសម្បើមក្នុងជំនួញនេះផងដែរ ហើយបុគ្គលិកជាច្រើនដែលបានចាកចេញពីក្រុមហ៊ុន Charles T. Main នៅពេលនោះ គឺក្រុមហ៊ុនចាស់របស់ខ្ញុំដែលត្រូវបានទិញយកពួកគេចេញទៅធ្វើការឱ្យ Stoner Webster ។ ពួកគេចូលរួមក្នុងការងារបែបនេះជាច្រើន ។ វាសុទ្ធតែជាផ្នែករបស់គ្រួសារតែមួយ ។ ខ្ញុំហៅថាជាការសូកប៉ាន់ ប៉ុន្តែនិយាយតាមផ្លូវច្បាប់វាមិនមែនទេ ។ ខ្ញុំត្រូវបានគេជួលឱ្យធ្វើជាទីប្រឹក្សាពួកគេ ហើយតំលៃដែលផ្តល់ឱ្យទីប្រឹក្សាជាមួយនឹងការយល់ស្របយ៉ាងតឹងរឹងថា ខ្ញុំនឹងមិននិយាយពីជីវិតអតីតកាលរបស់ខ្ញុំក្នុងមុខជំនួញនេះ ឬក៏ជីវិតពេលបច្ចុប្បន្ននាពេលនោះ ។ ភាគច្រើននៃលុយទាំងនោះ ខ្ញុំបានប្រើប្រាស់ដើម្បីបង្កើតអង្គការមិនរកប្រាក់កម្រៃដែលមានឈ្មោះថា "Dream Change" (សុបិន្តនៃការផ្លាស់ប្តូរ) ដែលជួយដល់ជនជាតិភាគតិចនៅក្នុងប្រទេសជាច្រើនដែលខ្ញុំបានធ្វើឱ្យក្រឡាប់ចាក់ក្នុងនាមជាអ្នកវាយលុកសេដ្ឋកិច្ច ។ ខ្ញុំបានធ្វើដូចនេះ ខ្ញុំប្រើលុយទាំងនោះដើម្បីសំរាលនូវទោសកំហុសរបស់ខ្ញុំ នឹងធ្វើនូវអំពើល្អ អំពើដែលខ្ញុំមានមោទនភាពបំផុត ។

AMY GOODMAN: តើលោករកលុយបានប៉ុន្មាន?

JONH PERKINS: ខ្ញុំបានយកលុយប្រហែលកន្លះលានដុល្លាពីសាជីវកម្ម Stoner-Webster ក្នុងរយៈពេល ៧ឆ្នាំ ដោយគ្មានបានធ្វើអ្វីសោះ ។

AMY GOODMAN: ប៉ុន្តែលោកមិនបានសរសេរសៀវភៅទេឬ?

JONH PERKINS: ខ្ញុំមិនបានសរសេរសៀវភៅទេ ហើយខ្ញុំក៏បានចេញទៅញ៉ាំអាហារពេលយប់ពីរ-បីដងនៅ Rio de Janeiro រួមទាំងកន្លែងផ្សេងៗទៀតជាមួយនឹងអតិថិជនខ្លះរបស់ពួកគេ ។ ការធ្វើការងារដ៏លំបាក ។ ធ្វើដំណើរទៅមកតាមយន្តហោះសាជីវកម្មឯកជនប៉ុន្មានដង ។ ប៉ុន្តែជារៀងរាល់ពេល ទោះបីជាយ៉ាងណាក៏ដោយ លោកដឹងទេ ខ្ញុំមើលឃើញថា ខ្ញុំធ្វើតែរឿងត្រឹមត្រូវនៅក្នុងវិស័យការងារមិនរកប្រាក់កម្រៃរបស់ខ្ញុំ ដែលនោះគឺជារឿងពិត ខ្ញុំដឹងនៅក្នុងជំរៅចិត្តរបស់ខ្ញុំថា ខ្ញុំត្រូវតែសរសេរសៀវភៅនេះ ។ ខ្ញុំត្រូវតែបង្ហាញនូវការពិតពីក្រោយអ្វីដែលបានកើតឡើងនៅលើពិភពលោក ។ ខ្ញុំមានកូនស្រីវ័យក្មេងម្នាក់ នាងកើតក្នុងឆ្នាំ ១៩៨២ ។ ដូច្នេះនៅក្នុងកំឡុងទស្សវត្សទី ៩0 នាងពិតជានៅក្មេងខ្លាំងណាស់ ខ្ញុំមានសេចក្តីព្រួយបារម្ភអំពីសុវត្ថិភាពនិងភាពសុខស្រួលរបស់នាង តែខ្ញុំក៏ព្រួយបារម្ភពីអនាគតនាងផងដែរ ។ ប៉ុន្តែ ខ្ញុំអាចបង្ហាញពីភាពត្រឹមត្រូវជាទិច្ចក្នុងការមិនសរសេរសៀវភៅនេះនៅក្នុងកិរិតផ្សេងៗគ្នា ។ ខ្ញុំបានស្បថថានឹងរក្សាការណ៍សម្ងាត់នេះ ។ ប៉ុន្តែនៅពេលការវាយប្រហារថ្ងៃ ១១ កញ្ញា ពេលនោះខ្ញុំនៅឯព្រៃ Amazon ។ ប៉ុន្តែ មួយរយៈពេលខ្លីក្រោយមក ខ្ញុំក៏មកដល់ទីកើតហេតុនោះ មកជួបលោកនៅឯជាន់ផ្ទាល់ដី ហើយខ្ញុំបានស្នាក់នៅទីនោះពីរ-បីសប្តាហ៍ បន្ទាប់ពីអ្វីដែលលោកអ្នកបានសរសេរយ៉ាងក្បោះក្បាយនៅក្នុងសៀវភៅរបស់លោកពីមនុស្សមួយចំនួនដែលចេញពីបន្ទប់ជាន់ផ្ទាល់ដីហើយឡើងមកជាន់លើនេះដែលជាស្ថានីយ៍ Firehouse គឺកន្លែងដែលយើងកំពុងអង្គុយនេះឯង ។ ប៉ុន្មានសប្តាហ៍ក្រោយមក ខ្ញុំបានទៅអង្គុយនៅទីនោះ ហើយវាក៏នៅជិតៗនឹងពេលដែលខ្ញុំអាចនៅធុំក្លិនផ្សែងដែលចេញមកពីការដុតសាច់មនុស្ស ហើយមើលឃើញផ្សែងដែលហុយចេញមកពីរន្ធនោះ ខ្ញុំអង្គុយនៅទីនោះទាំងដឹងយ៉ាងច្បាស់ថា ខ្ញុំត្រូវទទួលខុសត្រូវលើអ្វីដែលបានកើតឡើងនេះ ។ ខ្ញុំដឹងថាខ្ញុំត្រូវបង្ហាញរឿងពិតព្រោះថាអ្វីដែលបានកើតឡើង នៅជាន់ផ្ទាល់ដីគឺជាលទ្ធផលនៃការបង្កើតចក្រពត្តិ គឺអ្វីដែលយើងជាអ្នកវាយលុកសេដ្ឋកិច្ចបានធ្វើ ។ ខ្ញុំដឹងពេលដែលខ្ញុំអង្គុយនៅទីនោះថា បើសិនជាយើងមិនធ្វើអ្វីមួយឱ្យមានការផ្លាស់ប្តូរក្នុងនាមយើងជាមនុស្សរស់នៅលើផែនដីទេនោះ កូនស្រីខ្ញុំច្បាស់ជាបាត់បង់អនាគត ហើយកូនចៅរបស់នាងនឹងគ្មានអនាគត ។ ហើយនោះគឺជាអ្វីដែលខ្ញុំបន្សល់ទុកឱ្យពួកគេ គឺវាអាក្រក់ជាងអ្វីដែលខ្ញុំទទួលបានទៅទៀត ។ ត្រង់ចំណុចនេះ ខ្ញុំដឹងថាទោះជាផលវិបាកអ្វីក៏ដោយ ទោះបីជាអន្ទាក់ដែលខ្ញុំបានដាក់ក្បាលចូលទៅនោះវាធំយ៉ាងណាក្តី ខ្ញុំត្រូវតែបង្ហាញពីអ្វីដែលបានកើតមានឡើងក្នុងពិភពលោក ។ ចក្រពត្តិដែលយើងបានបង្កើតឡើងនេះបានធ្វើឱ្យប្រជាជនជាច្រើននៅក្នុងពិភពលោកមានការខឹងសម្បារ ហើយស្តែងចេញលទ្ធផលជាទុរគតភាពលើប្រជាជនក្រីក្ររាប់ពាន់លាននាក់នៅលើផែនដីនេះ ។ មនុស្ស ២៤.000នាក់ ស្លាប់ជារៀងរាល់ថ្ងៃដោយភាពអត់ឃ្លាន ។ ក្មេង ៣0.000នាក់ ស្លាប់ជារៀងរាល់ថ្ងៃដោយសារខ្វះថ្នាំសំរាប់ព្យាបាលជំងឺ ហើយយើងត្រូវតែទទួលខុសត្រូវលើបញ្ហានេះ ។ យើងអាចផ្លាស់ប្តូរវាបានហើយយើងនឹងធ្វើការផ្លាស់ប្តូរវា ។ ប៉ុន្តែ យើងអាចប្តូរបានលុះត្រាតែយើងយល់ពីអ្វីដែលកំពុងតែកើតឡើងផងដែរ ។

AMY GOODMAN: ដូច្នេះលោកក៏និពន្ធសៀវភៅនេះ *ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់* ហើយស្វែងរកកន្លែងសំរាប់បោះពុម្ពផ្សាយ ហើយលោកសរសេរអំពីសារជីវកម្មបោះពុម្ពផ្សាយដ៏ធំមួយ ដែលចាប់អារម្មណ៍លើសៀវភៅសរសេរដៃនេះ ។

JONH PERKINS: ពេលអានអត្ថបទសរសេរដៃនេះហើយ នាយករោងពុម្ពដ៏ធំមួយបានអញ្ជើញខ្ញុំឱ្យទៅទីក្រុងញូយ៉ក យើងទទួលទានអាហារពេលល្ងាចជាមួយគ្នា ។ គាត់និយាយថា នេះគឺជាសៀវភៅមួយដ៏ល្អ វាជារឿងដែលអានហើយមិនអាចដាក់ចុះបាន សរសេរបានល្អឥតខ្ចោះ វាគឺជារឿងដែលត្រូវតែប្រាប់អ្នករាល់គ្នា តែគាត់មិនអាចបោះពុម្ពបានទេ ព្រោះក្រុមហ៊ុនគាត់គឺជាក្រុមហ៊ុនរបស់សាជីវកម្មអន្តរជាតិធំមួយ ដែលមិនចង់ឱ្យរឿងរ៉ាវប្រភេទនេះចេញផ្សាយទៅទីនេះ ។ Amy ខ្ញុំសូមប្រាប់លោកចុះថា ខ្ញុំមានភ្នាក់ងារដ៏ល្អម្នាក់នៅញូយ៉ក (មកទល់ពេលនេះក៏ដោយ) ហើយគាត់បញ្ជូនសៀវភៅនេះទៅកាន់រោងពុម្ពធំៗជាច្រើន ហើយទទួលបានលិខិតឆ្លើយតបវិញ ។ គាត់បានអានសំបុត្រទាំងនោះឱ្យខ្ញុំស្តាប់តាមទូរស័ព្ទ ។ សំបុត្រទាំងនេះនិយាយរឿងរ៉ាវជាច្រើនដូចៗគ្នា ។ នេះគឺជាសៀវភៅល្អ ពួកយើងរីករាយនឹងទទួលតែមិនមែនក្នុងពេលនេះទេ ។

AMY GOODMAN: អ៊ឹម--ដូច្នេះម្ចាស់ក្រុមហ៊ុនដែលលោកបានទទួលទានអាហារពេលល្ងាចជាមួយនេះ ទទួលបោះពុម្ពសៀវភៅមួយក្នុងចំណោមសៀវភៅជាច្រើនរបស់លោក ប៉ុន្តែគាត់ថាត្រូវតែប្រឌិតសៀវភៅនេះទៅជាសាច់រឿងប្រឌិតវិញ?

JONH PERKINS: ត្រឹមត្រូវ ។ គេនិយាយដូច្នេះមែន ។ គាត់ប្រាប់ខ្ញុំថា "ហេតុអ្វីក៏លោកមិនប្រឌិតរឿងនេះទៅជាតួអង្គ Jonh Le Carre ឬ Graham Green ឬ Dan Brown រួមជាមួយនឹងលេខសំគាល់ពី Da Vini សរសេរវាឱ្យទៅជារឿងប្រឌិត ដូច្នេះទៅយើងអាចនឹងពិចារណាបោះពុម្ពជូនបាន ។ ខ្ញុំក៏បានពិចារណាថា នឹងធ្វើវាឱ្យទៅជារឿងប្រឌិតដែរ ។ ខ្ញុំគិតថាវានឹងក្លាយជារឿងដ៏គួរឱ្យចាប់អារម្មណ៍មួយ ។ ប៉ុន្តែអ្វីដែលបានឱ្យបប្រាប់ខ្ញុំនោះគឺថា តើនេះជាប្រភេទប្រទេសអ្វីដែលយើងកំពុងតែរស់នៅ នៅខណៈដែលអ្នកសារព័ត៌មាន ក្រុមហ៊ុនបោះពុម្ពផ្សាយសំខាន់ៗមិនយល់ព្រមបោះពុម្ពផ្សាយការពិតនៅពេលដែលគេបានសរសេរចេញមកជាការពិតនោះ ។ ពួកគេនឹងបោះពុម្ពផ្សាយដរាបណាវាជារឿងប្រឌិត? តើនោះវាបង្ហាញពីសេរីភាពសារព័តមានដែរឬអ្វី? ការពិតក្រោយមកមានរោងពុម្ពដ៏ក្លាហានមួយដែលជាក្រុមហ៊ុនលក្ខណ:គ្រួសារនៅឯសាន់ហ្វ្រាន់ស៊ីស្កូ ជារោងពុម្ពដ៏អស្ចារ្យឈ្មោះ Berrett-Koehler បានបោះពុម្ពសៀវភៅនេះ ។ ក៏ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា រោងពុម្ពដែលមានឥទ្ធិពលខ្លាំងនៅតែមិនបោះពុម្ព

សៀវភៅខ្ញុំ ។ កម្មវិធី Kudlow និង Cramer រួមនឹងកម្មវិធីមួយចំនួនទៀតបានអញ្ជើញខ្ញុំឱ្យចូលរួម តែមួយរយៈក្រោយមកបានប្រាប់ខ្ញុំវិញថា ខ្ញុំមិនត្រូវបានអញ្ជើញទៀតឡើយ ។ ពួកគេមិនចូលចិត្តនយោបាយទេ ។ មានអ្នកខ្លះជាអ្នកផ្សាយពាណិជ្ជកម្មជាអ្នកជំទាស់ ។ ខ្ញុំមិនដឹងច្បាស់ពីអ្វីដែលនៅពីក្រោយរឿងនេះឡើយ តែខ្ញុំត្រូវបានគេទាត់ចោលនៅនាទីចុងក្រោយ ។

AMY GOODMAN: ហើយក្នុងនាមលោកជាប្រធានសេដ្ឋកិច្ចវិទូនៃក្រុមហ៊ុនប្រឹក្សាយោបល់អន្តរជាតិ Main លោកគឺជាប្រភេទមនុស្សដែលត្រូវឡើងក្នុងកម្មវិធីទាំងនេះ ។

JONH PERKINS: បាទ ពិតមែន ។ ប៉ុន្តែឥឡូវនេះ ខ្ញុំជាមនុស្សគ្រោះថ្នាក់ លោកដឹងទេ? ការពិតគឺកំពុងតែបង្ហាញចេញមក ។ ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺខ្ញុំបានបង្ហាញខ្លួននៅក្នុងកម្មវិធីរបស់លោកប្រហែលជាមួយខែមុន ហើយនៅថ្ងៃបន្ទាប់មក សៀវភៅនេះបានជាប់ចំណាត់ថ្នាក់លេខ ១ លើ Amazon.com ។ ឥឡូវនេះ វានៅក្នុងសៀវភៅដែលលក់ដាច់ជាងគេនៅកាសែត New York Time ។ នៅក្នុងសប្តាហ៍ ទី ៥ នៃការបោះពុម្ពផ្សាយ វាក៏ជាការបោះពុម្ពលើក ទី៥ ដែរ ។ មានន័យថា រោងពុម្ពមិនអាចបោះពុម្ពទាន់ឡើយ ។

AMY GOODMAN: ក្រៅពីបណ្តាញផ្សព្វផ្សាយឯករាជ្យដែលក៏ជាបណ្តាញធំ នៅមិនទាន់មានបណ្តាញសារជីវកម្មធំៗណាមួយអញ្ជើញលោកទៅសម្ភាសន៍ទេមែនទេ?

JONH PERKINS: ត្រឹមត្រូវហើយ ។ គ្មានបណ្តាញផ្សព្វផ្សាយណាមួយដែលនៅក្រោមបង្គាប់សារជីវកម្មធំ ឬដែលពឹងផ្អែកទៅលើការផ្សាយពាណិជ្ជកម្មរបស់សាជីវកម្មធំៗ អញ្ជើញខ្ញុំឱ្យចូលរួមក្នុងកម្មវិធីរបស់ពួកគេទេមកដល់ពេលនេះ វាគួរឱ្យចាប់អារម្មណ៍ណាស់មែនទេ?

AMY GOODMAN: យើងកំពុងជជែកជាមួយលោក Jonh Perkins ។ ចុះអ៊ីរ៉ាក់ ។ តើវាមានទំនាក់ទំនងយ៉ាងណាខ្លះ ទៅនឹងរឿងរ៉ាវដែលលោកបានរៀបរាប់ប្រាប់យើងនៅក្នុងខណៈនេះ?

JONH PERKINS: អ៊ីរ៉ាក់កំពុងតែដើរតាមគន្លងរបស់ប្រទេសអារ៉ាប៊ីសាអូឌីត ។ បន្ទាប់ពីជោគជ័យដ៏សម្បើមរបស់ពួកយើងនៅអារ៉ាប៊ីសាអូឌីតមក យើងបានសំរេចថា យើងនឹងធ្វើរឿងដូចគ្នានៅអ៊ីរ៉ាក់ ។ ពួកយើងបានរកឃើញថាលោក សាដាំ ហ៊ូសេន គឺអាចសូកប៉ាន់ឱ្យពុករលួយបាន ។ វាជារឿងពិត មានពេលខ្លះយើងបានចូលរួមជាមួយនឹងលោកសាដាំ ហ៊ូសេន មួយរយៈមកហើយផងដែរ ។ ដូច្នេះ អ្នកវាយលុកសេដ្ឋកិច្ចក៏បានចូលទៅ ហើយព្យាយាមទាក់ទាញ

លោក សាដាំ ហ៊ូសេន គឺព្យាយាមធ្វើឱ្យគាត់យល់ព្រមទៅការបែងចែកដូចករណីដំណាក់ Saud នៅអារ៉ាប់ប៊ីសាអ៊ូឌីត បានយល់ព្រម ។ ប៉ុន្តែគាត់មិនយល់ព្រមទេ ។ ដូចនេះពួកយើងក៏បញ្ជូនក្រុម Jackals ដើម្បីព្យាយាមទម្លាក់គាត់ចេញពីដំណែង ឬក៏ធ្វើឃាដគាត់ ។ ពួកគេមិនអាចធ្វើអ្វីបានទេ ។ គាត់មានកងរក្សាសន្តិសុខរបស់គាត់ដែលស្មោះត្រង់នឹងគាត់ខ្លាំងណាស់ ហើយកងរក្សាសន្តិសុខនេះមានជាច្រើនដំណាក់ទៀតផង ។ ពួកយើងមិនអាចធ្វើអ្វីបានទាំងអស់ ។ ដូចនេះ បើសិនជាអ្នកវាយលុកសេដ្ឋកិច្ច និង Jackals សុទ្ធតែបរាជយ័នោះ ជំហ៊ានចុងក្រោយដែលរដ្ឋាភិបាលអាមេរិកដែលជាចក្រពត្តិតែងតែធ្វើនៅពេលបច្ចុប្បន្ននេះគឺប្រើកម្លាំងទ័ព ។ ពួកយើងបានបញ្ជូនយុវជន យុវនារី របស់យើងឱ្យទៅស្លាប់និងទៅសម្លាប់ ហើយយើងបានធ្វើដូច្នេះកាលពីសង្គ្រាមឈូងសមុទ្រនៅអ៊ីរ៉ាក់នាទស្សវត្សឆ្នាំ ១៩៩០ តែទទួលបរាជ័យ ។ យើងបានគិតថា នៅពេលនោះលោក សាដាំ ហ៊ូសេន គឺគ្រប់គ្រាន់ហើយនឹងការទទួលទណ្ឌកម្ម ហើយពេលនេះគាត់នឹងមកជិតៗយើង ដូច្នេះយើងដែលជាអ្នកវាយលុកសេដ្ឋកិច្ចត្រឡប់ទៅវិញនៅឆ្នាំ ១៩៩០ ។ ក្រុម Jackals ចូលមកម្តងទៀត ហើយទទួលបរាជ័យដដែល ដូចនេះហើយកម្លាំងទ័ពបានត្រូវប្រើប្រាស់ឱ្យចូលទៅ ហើយរឿងរ៉ាវនេះយើងសុទ្ធតែបានដឹងពីព្រោះយើងមិនអាចនាំ សាដាំ ហ៊ូសេន មកចូលរួមជាមួយយើងតាមវិធីផ្សេងទៀតបាន ក្រៅពីធ្វើតាមវិធីនេះ ។ ប្រទេសអ៊ីរ៉ាក់ជាប្រទេសដ៏សំខាន់សំរាប់យើង យោងលើហេតុផលជាច្រើន ។ វាគឺជាទីតាំងយុទ្ធសាស្រ្ត ការពិតប្រទេសនេះគ្រប់គ្រងដែនទឹកដ៏ច្រើនសម្បើមនៅមជ្ឈិមបូពា៌ ទន្លេ Tigris និងទន្លេ Euphrates សុទ្ធតែហូរកាត់និងហូរចេញពីអ៊ីរ៉ាក់ ហើយជាការពិតណាស់គ គឺប្រេងឆៅរបស់ប្រទេសនេះ ។ ឥឡូវនេះ ពួកយើងមិនសូវប្រាកដក្នុងចិត្តទេថា យើងនៅអាចត្រួតត្រាលើដំណាក់ស្តេច Saud បាន ។ វាបានក្លាយទៅជារឿងមិនពេញនិយមខ្លាំងណាស់ណាទេចំពោះប្រជាជនរបស់ប្រទេសនេះ ។ ក្នុងឆ្នាំនេះ មានការធ្វើឃាតកើត ឡើងជាង ១០០ ករណី។ ថ្មីៗនេះ យើងបានអានរឿងរ៉ាវដែលស្ថានកុងស៊ុលអាមេរិកកំពុងរងការវាយប្រហារនៅ អារ៉ាប់ប៊ីសាអូឌីត។ ដំណាក់ Saud កំពុងតែបាត់បង់អំណាចរបស់ខ្លួន ។ ដំណាក់នេះកាន់តែមិនមានប្រជាប្រិយភាពមួយផ្នែក គឺដោយសារតែការទទួលយកការបែងចែកនេះពីលោកខាងលិច ។ ដំណាក់នេះបានធ្វើរឿងជាច្រើនដូចគ្នានឹងអ្វីដែលស្តេច Shah នៃប្រទេសអ៊ីរ៉ង់បានធ្វើ ហើយ អូសាម៉ា ប៊ីនឡាដេន ជាក់ស្តែងគឺប្រឆាំងនឹងរឿងនេះយ៉ាងខ្លាំង ក៏ដូចជាប្រជាជនដែលកាន់សាសនាមូស្លីមដ៏ច្រើនសន្ធឹកសន្ធាប់នៅលើពិភពលោកប្រឆាំងដូច្នោះដែរ ។ កៅអីនៃជំនឿរបស់អ្នកកាន់សាសនាមូស្លីម Mecca ដែលមាននៅក្នុងប្រទេសអារ៉ាប់ប៊ីសាអូឌីត មានការខកចិត្តនឹងអ្វីដែលដំណាក់ស្តេច Saud បានធ្វើខ្លាំងណាស់ ។ ដូច្នេះយើងមានការភ័យខ្លាចថា យើងនឹងបាត់បង់ការក្តោបក្តាប់របស់យើងលើដំណាក់ស្តេច Saud ។ ផ្លូវតែមួយដើម្បីការពារប្រឆាំងនឹងរឿងនេះ គឺដណ្តើមឱ្យបាននូវតំបន់ប្រេងនៅអ៊ីរ៉ាក់ ដែលប្រេងនៅទីនោះអាចនឹងច្រើនជាងនៅ អារ៉ាប់ប៊ីសាអូឌីត ទៅទៀត ។ ពួកយើងដឹងមិនច្បាស់ទេថា វាច្រើនដល់កំរិតណា ។

AMY GOODMAN: នៅលើក្របសៀវភៅរបស់លោក បានសរសេរថា ការងាររបស់លោកដែលជាអ្នកវាយលុកសេដ្ឋកិច្ច គឺបញ្ចុះបញ្ចូលប្រទេសដែលជាយុទ្ធសាស្ត្រសំខាន់សំរាប់អាមេរិក តាំងពី ឥណ្ឌូនេស៊ី ប៉ាណាម៉ា ដើម្បីឱ្យទទួលយកប្រាក់កម្ចីយ៉ាងច្រើនសម្បើមសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធ្វើឱ្យប្រាកដថា រាល់កម្មវិធីដែលទទួលបានប្រាក់កម្រៃច្រើនគឺសុទ្ធតែត្រូវចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនសាជីវកម្មរបស់អាមេរិក ។ ដោយសារតែមានជាប់បំណុលដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ទើបប្រទេសទាំងនេះធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលអាមេរិក ធនាគារពិភពលោក និងភ្នាក់ងារផ្តល់ជំនួយអាមេរិកផ្សេងៗទៀត ដែលគ្រប់គ្រងដោយសហរដ្ឋអាមេរិកដែលដើរតួជាអ្នកផ្តល់ជំនួយដែលផ្តាច់ការលើល័ក្ខខ័ណ្ឌសងប្រាក់កម្ចី និងគំរាមរដ្ឋាភិបាលបរទេសឱ្យចូលជាចំណុះរបស់ខ្លួន ។ លោកធ្វើការជាមួយនឹងមនុស្សជាច្រើននៅតាមបណ្តាប្រទេសផ្សេងៗ ហើយនៅទីនេះ គឺស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឧទាហរណ៍ដូចជា ធនាគារពិភពលោក ។ តើពួកគេនិយាយថាយ៉ាងម៉េចដែរ? តើពួកគេមានការយល់ឃើញយ៉ាងណា? តើមានមនុស្សច្រើនគិតដូចជារូបលោកដែរទេ?

JONH PERKINS: នេះគឺជាសំណួរមួយដ៏ល្អមួយ ។ វាជាសំណួរដែលមានការលំបាកនឹងឆ្លើយសំរាប់មនុស្សជាច្រើនផ្សេងទៀត ។ នៅក្នុងស្ថាប័នទាំងនោះមានមនុស្សច្រើនណាស់ដែលមិនបានដឹងថា តើជាក់ស្តែងមានអ្វីកំពុងកើតឡើង ។ វិស្វករដែលធ្វើការនៅ Bechtel និង Halliburton ព្រមទាំងអ្នកជំនាញការហិរញ្ញវត្ថុនៅធនាគារពិភពលោក និងនៅកន្លែងផ្សេងៗទៀតគឺពិតជាមិនដឹងថា ជាក់ស្តែងនឹងមានអ្វីកើតឡើងឡើយ ។ ពួកគេគួរតែដឹង ។ ពួកគេគួរតែសំឡឹងមើលរឿងរ៉ាវដែលពួកគេបានធ្វើហើយស្វែងរកការពិត ។ ប៉ុន្តែមានលេសជាច្រើន ដែលគេមិនស្វែងរកការពិត ។ ពួកគេធ្វើការងាររបស់ពួកគេ ។ ឪពុកក្មេករបស់ខ្ញុំជាអតីតប្រធានវិស្វករនៅឯសាជីវកម្ម Bechtel ។ គាត់បានចូលនិវត្តន៍ ហើយលោកដឹងទេថា គាត់បានកសាងទីក្រុងធំៗជាច្រើននៅអារ៉ាប់ប៊ីសាអូឌីត ។ គាត់គឺជាអ្នកទទួលខុសត្រូវលើគំរោងទាំងនោះ ។ សំរាប់គាត់វាគឺជារឿងដ៏ល្អមួយ ។ គាត់គឺជាវិស្វករ ។ លោកដឹងទេ ការដែលត្រូវគេឱ្យប្រាក់យ៉ាងច្រើនដែលគាត់ចង់បាន ដើម្បីសាងសង់ទីក្រុងធំៗទាំងនោះនៅលើសមុទ្រខ្សាច់ គឺជាការស្រមើស្រមៃរបស់វិស្វករម្នាក់ ។ គាត់មិនដែលគិតទេថា តើមានអ្វីកើតឡើងនៅខាងក្រោមរូបភាពខាងក្រៅនោះឡើយ ហើយជាអកុសលពួកយើងជាច្រើនក៏មិនបានគិតពីបញ្ហានេះដែរ ។ ខ្ញុំត្រូវបានវាយបកដោយសារថា ខ្ញុំបានធ្វើដំណើរជុំវិញពិភពលោក ហើយខ្ញុំទើបតែត្រឡប់មកពីប្រទេស នេប៉ាល់ និងទីបេ ក្នុងពេលថ្មីៗនេះ ខ្ញុំបានធ្វើដំណើរជាច្រើនដងទៅអាមេរិចខាងត្បូង មិនដឹងជាមានមនុស្សប៉ុន្មាននាក់ទេ រួមទាំងអ្នកដែលពួកយើងគិតថាជាអនក្ខរជនផង ពួកគេបានចោទសួរទៅរដ្ឋាភិបាលរបស់គេ ។ ពួកគេប៉ាន់ស្មានថា រដ្ឋាភិបាលរបស់ខ្លួនពុករលួយ ពួកគេប៉ាន់ស្មានថា រដ្ឋាភិបាលរបស់ពួកយើងពុករលួយ តែពួកយើងមិនគិតដូច្នេះទេ ។ វាជារឿងគួរឱ្យឆ្ងល់សំរាប់ខ្ញុំ ដែលថាមានពួកយើងជាច្រើនដែលមិនគិតបែបនេះ យ៉ាងហោចណាស់ដោយមិនបើកចំហរ ។ ហើយដូចដែលខ្ញុំបាននិយាយរួចមកហើយ ខ្ញុំបានធ្វើដំណើរទៅជាច្រើនកន្លែងជាមួយនឹង

សៀវភៅនេះកាលពីខែមុន ប្រជាជននៅតែនិយាយថា យី! ខ្ញុំបានដឹងថាមានអ្វីកើតឡើងឡើយ ។ មានកន្លែងខ្លះនៅក្នុងចិត្តខ្ញុំ ខ្ញុំដឹងថាមានអ្វីបានកើតឡើង តែខ្ញុំនៅតែមិនយល់ ។ ការពិតគឺថាប្រជាជនអាមេរិកជាច្រើន ពួកយើងមិនសូវជាចង់ដឹងប៉ុន្មានទេ ខ្ញុំបារម្ភថាអ្វីដែលនឹងកើតមានឡើង ។ តែពួកយើងត្រូវការដឹង ។ ពួកយើងពិតជាត្រូវតែចោទសួរលើបញ្ហានេះ ។ ដូច្នេះនៅក្នុងស្ថាប័ននេះលោកអាចដឹងថា មានមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ដែលកំពុងតែដើរតាមប្រព័ន្ធនេះ ទទួលបានកម្រៃយ៉ាងច្រើនសំរាប់បំពេញការងារនេះ ហើយនឹងទទួលបាននូវការងារដែលពួកគេត្រូវបានបំពាក់បំប៉នឱ្យធ្វើ ។ ហើយវាគួរឱ្យអស្ចារ្យណាស់ ។ ប៉ុន្តែបន្ទាប់មក តែងតែមានមនុស្សមួយចំនួនដូចជាខ្ញុំដែលនៅគ្រប់គ្រងលើគេបំផុតក្នុងស្ថាប័នដែលដឹងថា នឹងមានអ្វីកំពុងកើតឡើង ។ ពួកគេជាចំណែកមួយក្នុងបញ្ហានេះ ហើយពួកគេប្រើគ្រប់មធ្យោបាយដែលអាចធ្វើបានដើម្បីរក្សាឱ្យប្រព័ន្ធនេះបន្តដំណើរការបានល្អ ។

AMY GOODMAN: ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក John Perkins សំរាប់ការចូលរួមរបស់លោកជាមួយពួកយើង ។ សៀវភៅរបស់លោកគឺមានចំណងជើងថា "*ការសារភាពរបស់អ្នកវាយលុកសេដ្ឋកិច្ចម្នាក់*" ។